# ព្រះរាជាណាចក្រកម្ពុជា

# ជាតិ សាសនា ព្រះមហាក្សត្រ

## រាជរដ្ឋាភិបាលកម្ពុជា

# ក្របខណ្ឌគោលនយោបាយជាតិ
# ផលិតភាពសេដ្ឋកិច្ចកម្ពុជា ២០២២ - ២០៣៥

*ផលិតភាពសេដ្ឋកិច្ច ដើម្បីសន្តិសុខសេដ្ឋកិច្ចនិងសុខុមាលភាពសង្គមជាតិ*



**រៀបចំដោយ គណៈកម្មាធិការជាតិផលិតភាពសេដ្ឋកិច្ចកម្ពុជា**

**ឆ្នាំ២០២២**

# បុព្វកថា

ចាប់ពីពាក់កណ្ដាលទសវត្សរ៍ឆ្នាំ១៩៨០មក, កម្ពុជា ចាប់ផ្ដើមធ្វើបរិវត្តកម្មសេដ្ឋកិច្ចរបស់ខ្លួនជាបន្តបន្ទាប់ឆ្ពោះទៅសេដ្ឋកិច្ចទីផ្សារ និង ធ្វើសេរីភាវូបនីយកម្មសេដ្ឋកិច្ចដោយបើកចំហយ៉ាងទូលំទូលាយលើគ្រប់វិស័យនៃសេដ្ឋកិច្ច សម្រាប់ការវិនិយោគផ្ទាល់ពីបរទេសនិងពាណិជ្ជកម្មអន្តរជាតិជាមួយដៃគូពាណិជ្ជកម្មនៅទូទាំងតំបន់និងសកលលោក ខណៈដែលសេដ្ឋកិច្ចកម្ពុជានៅបន្តរងការហ៊ុមព័ទ្ធដោយបស្ចិមប្រទេសមួយចំនួន ។ ដោយមានកិច្ចខិតខំប្រឹងប្រែងក្នុងស្មារតីភាពជាម្ចាស់និងការលះបង់ខ្ពស់, កម្ពុជា សម្រេចបានសុខសន្តិភាពទាំងស្រុងនៅទូទាំងប្រទេសនៅចុងឆ្នាំ ១៩៩៨ តាមរយៈ**នយោបាយឈ្នះ-ឈ្នះ** របស់រាជរដ្ឋាភិបាល ដែលនេះជាសមិទ្ធផលដ៏ធំធេងមិនអាចកាត់ថ្លៃបាននិងមិនធ្លាប់សម្រេចបានក្នុងរយៈពេលជាង ៥០០ឆ្នាំ ក្នុងប្រវត្តិសាស្ត្រកម្ពុជា ។

ជាការពិត សន្តិភាពពេញលេញ គឺជាបុរេលក្ខខណ្ឌដ៏ចាំបាច់ និង ជាមូលដ្ឋានគ្រឹះដែលមិនអាចខ្វះបាន សម្រាប់ការអភិវឌ្ឍប្រទេសនិងវិបុលភាពសង្គម ។ ជាមួយនឹងសុខសន្តិភាព បូរណភាពទឹកដីសាមគ្គីភាព ស្ថិរភាពនយោបាយ និង ការកែទម្រង់ជាប្រចាំ, កម្ពុជា សម្រេចបានកំណើនសេដ្ឋកិច្ចខ្ពស់ក្នុងរយៈពេលវែងជាប្រវត្តិសាស្ត្រ ស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច អត្រានិកម្មភាពទាប ការកាត់បន្ថយភាពក្រីក្រនិងការបង្រួមវិសមភាពសេដ្ឋកិច្ច ប្រកបដោយជវភាពនិងបរិយាបន្ន ។ សមិទ្ធផលធំៗទាំងនេះបង្កើតសក្ដានុពលសេដ្ឋកិច្ចខ្ពស់និងបរិស្ថានធុរកិច្ចអំណោយផល សម្រាប់ទាក់ទាញការវិនិយោគផ្ទាល់ពីបរទេសនិងការវិនិយោគក្នុងស្រុក ដែលជាឃ្នាស់ជំរុញបន្ថែមកំណើនសេដ្ឋកិច្ច, បង្កើនប្រាក់ចំណូលសម្រាប់ប្រជាជនម្នាក់ៗ, បសិដ្ឋភាពនៃកម្រិតជីវភាព និង ការអភិវឌ្ឍសេដ្ឋកិច្ច ដែលគ្រប់តួអង្គសេដ្ឋកិច្ចទទួលបានផលប្រយោជន៍ពីការអភិវឌ្ឍ ប្រកបដោយបរិយាបន្ននិងចីរភាព ។ ជាក់ស្ដែង កម្ពុជា សម្រេចបានកំណើនជាមធ្យមប្រមាណ ៧% ក្នុងមួយឆ្នាំ ក្នុងរយៈពេលជាង២ទសវត្សរ៍រហូតដល់ការផ្ទុះឡើងនៃវិបត្តិនៃជំងឺកូវីដ-១៩ ។ ដោយសារកំណើនដ៏ខ្ពស់នេះ កម្ពុជា បានប្រែក្លាយពីប្រទេសមាន ចំណូលកម្រិតទាប ទៅជាប្រទេសមានចំណូលមធ្យមកម្រិតទាបនៅឆ្នាំ២០១៥ ហើយបន្ទាប់មក ត្រូវបានចាត់ទុកថាជាខ្លាសេដ្ឋកិច្ចថ្មីរបស់អាស៊ីនៅឆ្នាំ២០១៦ ។ ជាមួយនឹងភាពជោគជ័យទាំងនេះ និង ដោយមានចក្ខុវិស័យវែងឆ្ងាយច្បាស់លាស់, រាជរដ្ឋាភិបាលកម្ពុជា បានដាក់ចេញគោលនយោបាយគន្លឹះមួយចំនួន សម្រាប់ជំរុញបន្ថែមល្បឿននៃការអភិវឌ្ឍសេដ្ឋកិច្ចនិងសង្គមជាតិ ដើម្បីសម្រេចបានចក្ខុវិស័យ ២០៥០ ដែលកម្ពុជានឹងក្លាយទៅជាប្រទេសមានចំណូលខ្ពស់ ។

ការប្រែប្រួលជាអវិជ្ជមាននៃនិន្នាការពិភពលោក ដែលបង្កើតឡើងដោយវិបត្តិនៃជំងឺកូវីដ-១៩, ការកើនឡើងនៃការគាំពារនិយមនិងការប្រកួតប្រជែង, សង្គ្រាមពាណិជ្ជកម្ម និងភាពមិនច្បាស់នៃ

សណ្ដាប់ធ្នាប់ពិភពលោក ជះឥទ្ធិពលអវិជ្ជមានដល់កំណើនសេដ្ឋកិច្ច និងប៉ះទង្គិចដល់គន្លងការអភិវឌ្ឍសេដ្ឋកិច្ចក្នុងរយៈពេលមធ្យម ។ ការណ៍នេះ ទាមទារឱ្យមានការគិតគូរច្បាស់លាស់ក្នុងការរៀបចំម៉ូដែលកំណើនសេដ្ឋកិច្ចថ្មី ដែលមានភាពធន់និងភាពប្រកួតប្រជែងខ្ពស់ ។ ជាមួយនឹងការរីកចម្រើននៃបច្ចេកវិទ្យា ដែលជំរុញដោយបដិវត្តន៍ឧស្សាហកម្មទី៤, រាជរដ្ឋាភិបាលកម្ពុជា បានដាក់ចេញ “ **ក្របខណ្ឌគោលនយោបាយជាតិផលិតភាពសេដ្ឋកិច្ចកម្ពុជា ២០២២-២០៣៥**” ដោយមានចក្ខុវិស័យច្បាស់លាស់ គឺកសាង និង លើកកម្ពស់ផលិតភាពសេដ្ឋកិច្ចជាតិ ដោយផ្អែកលើកម្លាំងពលកម្មជំនាញខ្ពស់និងនវានុវត្តន៍ ដើម្បីជំរុញសន្ទុះការអភិវឌ្ឍសង្គម-សេដ្ឋកិច្ច ឱ្យកាន់តែប្រសើរ ។ ការកសាងកម្លាំងពលកម្មមានជំនាញខ្ពស់ និងនវានុវត្តន៍ ជាកូនសោដ៏សំខាន់ក្នុងការសម្រេចបានផលិតភាពសេដ្ឋកិច្ចខ្ពស់, លើកកម្ពស់ភាពប្រកួតប្រជែងរបស់កម្ពុជា និងរក្សាបានចីរភាពកំណើនសេដ្ឋកិច្ច សំដៅបង្កើនប្រាក់ចំណូលសម្រាប់ប្រជាជនម្នាក់ៗ ដើម្បីបង្កើនសន្តិសុខសេដ្ឋកិច្ចនិងសុខុមាលភាពសង្គម ប្រកបដោយចីរភាព ភាពធន់ និងបរិយាបន្ន ។ ដើម្បីសម្រេចបាន ភាពជោគជ័យខ្ពស់ក្នុងការអនុវត្តក្របខណ្ឌគោលនយោបាយនេះ, គ្រប់ក្រសួង-ស្ថាប័ន ត្រូវសហការគ្នាក្នុងស្មារតីបុរេសកម្មនិងអន្តរសកម្មបំផុត ព្រមទាំងប្រកាន់ខ្ជាប់នូវអភិក្រម “**ជីវភាពនៃប្រព័ន្ធតួអង្គតែមួយ**” ។

ក្នុងនាមរាជរដ្ឋាភិបាលកម្ពុជា ខ្ញុំសូមកោតសរសើរនិងវាយតម្លៃខ្ពស់ ចំពោះកិច្ចខិតខំប្រឹងប្រែងរបស់ **ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ និង ជាប្រធានគណៈកម្មាធិការជាតិផលិតភាពសេដ្ឋកិច្ចកម្ពុជា** និង **ឯកឧត្តមបណ្ឌិតសភាចារ្យ ម៉ាន សាហ៊ីម រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ និង ជាសមាជិកគណៈកម្មាធិការជាតិផលិតភាពសេដ្ឋកិច្ចកម្ពុជា** ដែលបានដឹកនាំការរៀបចំក្របខណ្ឌគោលនយោបាយនេះ រហូតសម្រេចបានជោគជ័យ ។ ទន្ទឹមនឹងនេះ ខ្ញុំក៏សូមថ្លែងអំណរគុណចំពោះ ឯកឧត្តម លោកជំទាវ ដែលជាអនុប្រធាន ព្រមទាំងសមាជិកសមាជិកានៃគណៈកម្មាធិការអន្តរក្រសួង និង ក្រុមការងារបច្ចេកទេសរៀបចំក្របខណ្ឌគោលនយោបាយនេះ ចំពោះការចូលរួមយ៉ាងសកម្ម ប្រកបដោយការទទួលខុសត្រូវខ្ពស់ ។

ថ្ងៃ ... ខែ ... ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ... ខែ ... ឆ្នាំ២០២២

**នាយករដ្ឋមន្ត្រី**

**សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

## អារម្ភកថា

ក្នុងរយៈពេលជាង៤០ឆ្នាំនៃការអភិវឌ្ឍសេដ្ឋកិច្ចជាតិពីបាតដៃទទេ, រាជរដ្ឋាភិបាលកម្ពុជា សម្រេចបានសមិទ្ធផលជាច្រើនគួរឱ្យកត់សម្គាល់ ដោយទទួលបានកំណើនសេដ្ឋកិច្ចខ្ពស់ប្រកបដោយបរិយាបន្នក្នុងរយៈពេលដ៏វែង, រក្សាបានស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច, កាត់បន្ថយភាពក្រីក្រពី ១០០% ក្នុងឆ្នាំ១៩៧៩ មកត្រឹមប្រមាណ ១០% នៅមុនពេលមានការរីករាលដាលនៃជំងឺកូវីដ-១៩ និងកាត់បន្ថយគម្លាតវិសមភាពសេដ្ឋកិច្ចជាបន្តបន្ទាប់ ។ សមិទ្ធផលសេដ្ឋកិច្ចទាំងនេះសម្រេចបាន តាមរយៈកម្មវិធីកែទម្រង់ជាប្រចាំនិងការដាក់ចេញគោលនយោបាយសេដ្ឋកិច្ចច្បាស់លាស់ ដែលត្រូវបានអនុវត្តក្នុងស្មារតីបុរេសកម្ម សកម្មអន្តរសកម្ម ភាពស៊ីចង្វាក់គ្នា និងការទទួលខុសត្រូវខ្ពស់ សំដៅជំរុញទាំងការអភិវឌ្ឍសេដ្ឋកិច្ចនិងសង្គមដើម្បីសម្រេចបានចក្ខុវិស័យកម្ពុជាឆ្នាំ២០៥០ ។

ផលិតភាពសេដ្ឋកិច្ច ដើរតួនាទីជាកម្លាំងចលករយ៉ាងសំខាន់និងដោយផ្ទាល់ ក្នុងការជំរុញកំណើនសេដ្ឋកិច្ចនិងលើកកម្ពស់ភាពប្រកួតប្រជែងកម្ពុជា តាមរយៈការបង្កើតប្រសិទ្ធផល ប្រសិទ្ធភាព និងគុណតម្លៃ ។ ក្នុងទិសដៅយុទ្ធសាស្ត្រកំណើនថ្មីដោយផ្អែកលើផលិតភាព, **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** បានប្រគល់ភារកិច្ចជូន គណៈកម្មាធិការជាតិផលិតភាពសេដ្ឋកិច្ចកម្ពុជា ដឹកនាំ សម្របសម្រួល និងរៀបចំក្របខណ្ឌគោលនយោបាយជាតិផលិតភាពសេដ្ឋកិច្ចកម្ពុជា សម្រាប់ជាមគ្គុទ្ទេសក៍ក្នុងការលើកកម្ពស់ផលិតភាពសេដ្ឋកិច្ច សំដៅជំរុញបន្ថែមល្បឿននៃការអភិវឌ្ឍសង្គម-សេដ្ឋកិច្ច ។ ក្របខណ្ឌគោលនយោបាយជាតិផលិតភាពសេដ្ឋកិច្ចកម្ពុជា បានកំណត់ចក្ខុវិស័យ **"កសាង និង លើកកម្ពស់ផលិតភាពសេដ្ឋកិច្ចជាតិដោយផ្អែកលើកម្លាំងពលកម្មជំនាញខ្ពស់ និង នវានុវត្តន៍ ដើម្បីជំរុញ សន្ទុះការអភិវឌ្ឍសង្គម-សេដ្ឋកិច្ច ឱ្យកាន់តែប្រសើរ"** និង មានគោលបំណងបង្កើនប្រាក់ចំណូលសម្រាប់ប្រជាជនម្នាក់ៗ ដើម្បីបង្កើនសន្តិសុខសេដ្ឋកិច្ចនិងសុខុមាលភាពសង្គមប្រកបដោយចីរភាពនិងបរិយាបន្ន ។ ចក្ខុវិស័យនិងគោលបំណងខាងលើនឹងត្រូវសម្រេចក្នុងរយៈពេល ១៤ឆ្នាំ ដោយឈរលើគោលការណ៍អនុវត្តចំនួន ៣គឺ "កិច្ចសហប្រតិបត្តិការនៃគ្រប់តួអង្គសេដ្ឋកិច្ច ការបែងចែកដោយសមធម៌នៃផលប្រយោជន៍ ផលិតភាព និងការបង្កើតការងារសម្រាប់រយៈពេលវែង"។

ក្របខណ្ឌគោលនយោបាយនេះ ផ្តោតលើគោលដៅយុទ្ធសាស្ត្រអាទិភាពចំនួន ៤ រួមមាន÷ (១). ការអប់រំ និង ការបណ្តុះបណ្តាលបច្ចេកទេសវិជ្ជាជីវៈ ដោយផ្តោតលើការបង្កើនបរិមាណនិងគុណភាពនៃការអភិវឌ្ឍមូលធនមនុស្សដែលមានជំនាញខ្ពស់, ការអភិវឌ្ឍមូលធនមនុស្សកម្រិតឧត្តមសិក្សា និង ផលិតភាពកម្លាំងពលកម្មជាតិ, (២). ការជំរុញផ្នែកបច្ចេកវិទ្យា និង នវានុវត្តន៍ ដោយផ្តោតលើការអភិវឌ្ឍជំនាញផ្នែកបច្ចេកវិទ្យា, ការគាំទ្រនិងលើកទឹកចិត្តសហគ្រាសលើផ្នែកបច្ចេកវិទ្យានិងនវានុវត្តន៍ និងការពង្រឹងប្រសិទ្ធភាពនៃកិច្ចសហប្រតិបត្តិការរវាងស្ថាប័នគាំទ្របច្ចេកវិទ្យានិងនវានុវត្តន៍ ដោយឈរលើ

អភិក្រម"ទទួលយក បន្សាំ និង នវានុវត្ត", (៣). ការអភិវឌ្ឍសមត្ថភាពស្ថាប័នសាធារណៈ ដោយផ្តោតលើការជំរុញអភិបាលកិច្ចល្អ, ការកែលម្អបទប្បញ្ញត្តិទីផ្សារ និងការលើកកម្ពស់ស្ថាប័នទីផ្សារការងារ, និង (៤). ការអភិវឌ្ឍប្រព័ន្ធហេដ្ឋារចនាសម្ព័ន្ធ ដោយផ្តោតលើការកែលម្អគុណភាពនិងស័ក្តិសិទ្ធភាពនៃប្រព័ន្ធដឹកជញ្ជូន ប្រព័ន្ធភស្តុភារកម្ម ប្រព័ន្ធទឹកស្អាត ប្រព័ន្ធថាមពល និងប្រព័ន្ធហេដ្ឋារចនាសម្ព័ន្ធឌីជីថល ។

ជាទីបញ្ចប់ ក្នុងនាម**គណៈកម្មាធិការជាតិផលិតភាពសេដ្ឋកិច្ចកម្ពុជា** និង រូបខ្ញុំផ្ទាល់ ខ្ញុំសូមសម្តែងនូវកតញ្ញុតាធម៌យ៉ាងជ្រាលជ្រៅជូនចំពោះ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** ដែលជាអគ្គមគ្គុទ្ទេសក៍ដ៏ឆ្នើម ប្រកបដោយឆន្ទៈនយោបាយមុតស្រួចក្នុងការងារកែទម្រង់និងការដឹកនាំការអភិវឌ្ឍកម្ពុជាប្រកបដោយចក្ខុវិស័យវែងឆ្ងាយ ។ ខ្ញុំសូមថ្លែងអំណរគុណចំពោះក្រសួង-ស្ថាប័នពាក់ព័ន្ធទាំងអស់ ដែលបានចូលរួមយ៉ាងសកម្មនិងផ្តល់កិច្ចសហការជាមួយនឹង **អគ្គលេខាធិការដ្ឋានគណៈកម្មាធិការជាតិផលិតភាពសេដ្ឋកិច្ចកម្ពុជា** ក្នុងកិច្ចការតាក់តែងក្របខណ្ឌគោលនយោបាយនេះ ។ ខ្ញុំសូមថ្លែងអំណរគុណចំពោះ **ឯកឧត្តមបណ្ឌិតសភាចារ្យ ហ៊ាន សាហ៊ីប រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ និង ជាសមាជិកគណៈកម្មាធិការជាតិផលិតភាពសេដ្ឋកិច្ចកម្ពុជា** និង **ឯកឧត្តម ស៊ីសុវត្ថិ ដួងចំនួនតោ អគ្គលេខាធិការនៃអគ្គលេខាធិការដ្ឋានគណៈកម្មាធិការជាតិផលិតភាពសេដ្ឋកិច្ចកម្ពុជា** ដែលបានដឹកនាំនិងសម្របសម្រួលរៀបចំក្របខណ្ឌគោលនយោបាយនេះ រហូតសម្រេចជាស្ថាពរនិងមានលក្ខណៈគ្រប់ជ្រុងជ្រោយ ។

ថ្ងៃព្រហស្បតិ៍ ១៤កើត ខែស្រាពណ៍ ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី១១ ខែសីហា ឆ្នាំ២០២២

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**

**និង ជាប្រធានគណៈកម្មាធិការជាតិផលិតភាពសេដ្ឋកិច្ចកម្ពុជា**

**អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន**

# មាតិកា


បុព្វកថា ........ i

អារម្ភកថា ........ iii

បញ្ជីពាក្យកាត់ ........ vii

ខ្លឹមសារសង្ខេប ........ viii

១. សេចក្តីផ្តើម ........ ១

១.១. បរិការណ៍ និង ទស្សនាទាននៃការរៀបចំក្របខណ្ឌគោលនយោបាយ ........ ១

១.២. ទស្សនាទាន និង និយមន័យនៃផលិតភាពសេដ្ឋកិច្ច ........ ២

១.៣. វិបាកនៃក្របខណ្ឌគោលនយោបាយផលិតភាពសេដ្ឋកិច្ច ........ ៦

២. ស្ថានភាព និង ការត្រៀមខ្លួន ក្នុងការកសាង និង ជំរុញផលិតភាពសេដ្ឋកិច្ចកម្ពុជា ........ ៨

២.១. ស្ថានភាពនៃផលិតភាពសេដ្ឋកិច្ចកម្ពុជា ........ ៩

២.២. ការត្រៀមខ្លួនក្នុងការកសាង និង ជំរុញផលិតភាពសេដ្ឋកិច្ចកម្ពុជា ........ ១០

២.២.១. ការអប់រំ និង ការបណ្តុះបណ្តាលបច្ចេកទេសវិជ្ជាជីវៈ ........ ១១

២.២.២. បច្ចេកវិទ្យា និង នវានុវត្តន៍ ........ ១៣

២.២.៣. ស្ថាប័នសាធារណៈ ........ ១៤

២.២.៤. ហេដ្ឋារចនាសម្ព័ន្ធ ........ ១៦

៣. ក្របខណ្ឌគោលនយោបាយ ........ ២០

៣.១. ចក្ខុវិស័យ គោលបំណង និង គោលដៅ ........ ២០

៣.២. គោលការណ៍ក្នុងការជំរុញផលិតភាពសេដ្ឋកិច្ច ........ ២១

៣.៣. វិធានការគោលនយោបាយគន្លឹះ ........ ២២

៣.៣.១. ការកែលម្អការអប់រំ និង ការបណ្តុះបណ្តាលបច្ចេកទេសវិជ្ជាជីវៈ ........ ២៣

៣.៣.២. ការជំរុញផ្នែកបច្ចេកវិទ្យា និង នវានុវត្តន៍ ........ ២៦

៣.៣.៣. ការអភិវឌ្ឍសមត្ថភាពស្ថាប័នសាធារណៈ ........ ២៨

៣.៣.៤. ការអភិវឌ្ឍប្រព័ន្ធហេដ្ឋារចនាសម្ព័ន្ធ ........ ៣១

៤. ក្របខណ្ឌអនុវត្ត និង យន្តការសម្របសម្រួល តាមដាន និង វាយតម្លៃ .................... ៣៦
៤.១. ការរៀបចំក្របខណ្ឌស្ថាប័ន និង យន្តការសម្របសម្រួល ................................ ៣៦
៤.២. យន្តការតាមដាន និង វាយតម្លៃលើការអនុវត្តក្របខណ្ឌគោលនយោបាយ............ ៣៨
៤.២.១. ការរៀបចំផែនការសកម្មភាព និង សូចនាករ .................................. ៣៩
៤.២.២. ការតាមដាន.................................................................... ៣៩
៤.២.៣. ក្របខណ្ឌវាយតម្លៃ............................................................ ៤០
៤.២.៤. ការវាស់វែង និង ផ្សព្វផ្សាយអំពីផលិតភាពសេដ្ឋកិច្ច............................ ៤១
៥. សេចក្តីសន្និដ្ឋាន.................................................................................. ៤១
ឧបសម្ព័ន្ធ៖ តារាងម៉ាទ្រីសវិធានការគោលនយោបាយ .............................................. ៤៣

# បញ្ជីពាក្យកាត់

| | |
|---|---|
| គ.ជ.ផ.ក. | គណៈកម្មាធិការជាតិផលិតភាពសេដ្ឋកិច្ចកម្ពុជា |
| ផ.ស.ស. | ផលិតផលក្នុងស្រុកសរុប |
| APO | Asian Productivity Organization<br>អង្គការផលិតភាពអាស៊ី |
| CLMV | Cambodia, Laos, Myanmar and Vietnam<br>កម្ពុជា ឡាវ មីយ៉ាន់ម៉ា និង វៀតណាម |
| ICT | Information and Communication Technology<br>បច្ចេកវិទ្យាទូរគមនាគមន៍ និង ព័ត៌មាន |
| OECD | Organization for Economic Co-operation and Development<br>អង្គការសម្រាប់កិច្ចសហប្រតិបត្តិការសេដ្ឋកិច្ច និង ការអភិវឌ្ឍ |
| R&D | Research and Development<br>ការស្រាវជ្រាវ និង ការអភិវឌ្ឍ |
| SMEs | Small and Medium Enterprises<br>សហគ្រាសធុនតូច និង មធ្យម |
| TVET | Technical and Vocational Education and Training<br>ការអប់រំបណ្តុះបណ្តាលបច្ចេកទេស និង វិជ្ជាជីវៈ |
| WEF | World Economic Forum<br>វេទិកាសេដ្ឋកិច្ចពិភពលោក |

# ខ្លឹមសារសង្ខេប

ដោយមានមគ្គុទ្ទេសក៍ពីចក្ខុវិស័យកម្ពុជាឆ្នាំ២០៥០ ក្នុងការប្រែក្លាយកម្ពុជាជាប្រទេសមានចំណូលខ្ពស់ និង យុទ្ធសាស្ត្រចតុកោណ ព្រមទាំងតាមការចង្អុលបង្ហាញពីក្របខណ្ឌគោលនយោបាយសេដ្ឋកិច្ច និង សង្គមឌីជីថល ២០២១-២០៣៥ ដែលកំណត់ចន្ទល់កំណើនសេដ្ឋកិច្ចថ្មី, **ក្របខណ្ឌគោលនយោបាយជាតិផលិតភាពសេដ្ឋកិច្ចកម្ពុជា ២០២២-២០៣៥** ត្រូវបានរៀបចំឡើង ដើម្បីធ្វើបរិវត្តកម្មនិងពិពិធកម្មសេដ្ឋកិច្ច និងជំរុញកំណើនតាមរយៈផលិតភាព សំដៅលើកកម្ពស់ជីវភាព បង្កើនសន្តិសុខសេដ្ឋកិច្ច និង លើកកម្ពស់សុខុមាលភាពសង្គម ។ កំណើនផលិតភាពសេដ្ឋកិច្ចនាំមកនូវផលវិជ្ជមានជាច្រើនដល់តួអង្គពាក់ព័ន្ធទាំងអស់ ដូចជា និយោជិត និយោជក ធុរជន រាជរដ្ឋាភិបាល និងសង្គមជាតិទាំងមូល តាមរយៈការដាក់ចេញគោលការណ៍អនុវត្តនិងវិធានការគោលនយោបាយគន្លឹះច្បាស់លាស់ ប្រកបដោយបរិយាបន្ន ។ ជាមួយនឹងការសម្រេចបានកំណើនសេដ្ឋកិច្ចខ្ពស់ ក្នុងរយៈពេលជាង២ទសវត្សរ៍ ដែលជារយៈពេលវែងជាប្រវត្តិសាស្ត្រ, ចន្ទល់ទ្រទ្រង់កំណើនសេដ្ឋកិច្ចរបស់កម្ពុជាមានភាពតូចចង្អៀត ជាហេតុធ្វើឱ្យកម្ពុជាងាយរងផលអវិជ្ជមានពីការប្រែប្រួលយ៉ាងឆាប់រហ័សនៃបញ្ហាសេដ្ឋកិច្ចពិភពលោក ។ ជាមួយគ្នានេះ ដោយធ្វើការប្រៀបធៀបជាមួយនឹងប្រទេសមានចំណូលមធ្យមកម្រិតទាប និងការអភិវឌ្ឍប្រហាក់ប្រហែលនឹងកម្ពុជា, ផលិតភាពសេដ្ឋកិច្ចកម្ពុជានៅមានកម្រិតទាប ទោះបីជាមានកំណើនរឹងមាំក៏ដោយ ។ ផលិតភាពសេដ្ឋកិច្ចខ្ពស់នាំមកនូវវិបុលភាពសង្គម លើកកម្ពស់កម្រិតជីវភាពរបស់ប្រជាជន ពង្រីកវិមាត្រសេដ្ឋកិច្ច ព្រមទាំងបង្កើនភាពប្រកួតប្រជែងយកឈ្នះរបស់កម្ពុជា ។ ការណ៍នេះបង្ហាញនូវភាពចាំបាច់និងបន្ទាន់ក្នុងការជំរុញល្បឿនផលិតភាពសេដ្ឋកិច្ចនៅកម្ពុជា សំដៅលើកកម្ពស់ឱ្យបានកាន់តែខ្លាំងក្លានិងប្រសើរឡើងថែមទៀតនូវកម្រិតជីវភាពរបស់ប្រជាជននិងការអភិវឌ្ឍសង្គម-សេដ្ឋកិច្ច, ចូលរួមចំណែកដល់ការជំរុញកំណើនសេដ្ឋកិច្ចផ្អែកតាមម៉ូដែលកំណើនថ្មី ដែលបានកំណត់នៅក្នុងក្របខណ្ឌគោលនយោបាយសេដ្ឋកិច្ច និង សង្គមឌីជីថលកម្ពុជា ២០២១-២០៣៥ និងរួមចំណែកដល់ការសម្រេចបានចក្ខុវិស័យកម្ពុជាឆ្នាំ២០៥០ ។

ក្នុងស្មារតីគិតគូរវែងឆ្ងាយ រាជរដ្ឋាភិបាលកម្ពុជាសម្រេចដាក់ចេញក្របខណ្ឌគោលនយោបាយជាតិផលិតភាពសេដ្ឋកិច្ចកម្ពុជា ២០២២-២០៣៥ ដែលមានចក្ខុវិស័យច្បាស់លាស់គឺ *កសាង និង លើកកម្ពស់ផលិតភាពសេដ្ឋកិច្ចជាតិដោយផ្អែកលើកម្លាំងពលកម្មជំនាញខ្ពស់ និង នវានុវត្តន៍ ដើម្បីជំរុញសន្ទុះការអភិវឌ្ឍសង្គម-សេដ្ឋកិច្ច ឱ្យកាន់តែប្រសើរ* ។ ក្របខណ្ឌគោលនយោបាយនេះ មានគោលបំណងជំរុញកំណើនផលិតភាពសេដ្ឋកិច្ចនិងបង្កើនប្រាក់ចំណូលសម្រាប់ប្រជាជនម្នាក់ៗ សំដៅបង្កើនសន្តិសុខសេដ្ឋកិច្ចនិងសុខុមាលភាពសង្គម ប្រកបដោយចីរភាពនិងបរិយាបន្ន ។ ដើម្បីសម្រេចបានចក្ខុវិស័យនិង

គោលបំណងខាងលើ, រាជរដ្ឋាភិបាល កំណត់គោលដៅយុទ្ធសាស្ត្រអាទិភាពចំនួន៤ ដែលជាកត្តាកំណត់ផលិតភាពសេដ្ឋកិច្ចគន្លឹះក្នុងក្របខណ្ឌពេលវេលា ១៤ឆ្នាំ សម្រាប់អនុវត្តជា ៣ដំណាក់កាល ប្រកបដោយភាពប្រទាក់ក្រឡា ដោយចាប់ផ្តើមពីការបញ្ជ្រាបការយល់ដឹង, ការកែលម្អកត្តាកំណត់ផលិតភាពសេដ្ឋកិច្ចទាំង៤ និងការតាមដាននិងការវាយតម្លៃជាប្រចាំ សំដៅធ្វើបសិដ្ឋកម្ម (improvement) បន្ថែមតាមការចាំបាច់ ដើម្បីចាប់យកកាលានុវត្តភាពពេញលេញក្នុងការលើកកម្ពស់ផលិតភាពសេដ្ឋកិច្ចកម្ពុជា ។ គោលដៅយុទ្ធសាស្ត្រអាទិភាពទាំង៤ ដែលបានដាក់ចេញ រួមមាន÷(១).ការអប់រំ និង ការបណ្តុះបណ្តាលបច្ចេកទេសវិជ្ជាជីវៈ ដោយផ្តោតលើការបង្កើនបរិមាណនិងគុណភាពនៃការអភិវឌ្ឍមូលធនមនុស្សដែលមានជំនាញខ្ពស់, ការអភិវឌ្ឍមូលធនមនុស្សកម្រិតឧត្តមសិក្សា និងផលិតភាពកម្លាំងពលកម្មជាតិ, (២).ការជំរុញផ្នែកបច្ចេកវិទ្យា និង នវានុវត្តន៍ ដោយផ្តោតលើការអភិវឌ្ឍជំនាញផ្នែកបច្ចេកវិទ្យា, ការគាំទ្រនិងលើកទឹកចិត្តសហគ្រាសលើផ្នែកបច្ចេកវិទ្យា និង នវានុវត្តន៍ និងការពង្រឹងប្រសិទ្ធភាពនៃកិច្ចសហប្រតិបត្តិការរវាងស្ថាប័នគាំទ្របច្ចេកវិទ្យា និង នវានុវត្តន៍ ឈរលើអភិក្រម "**ទទួលយក បន្សាំ និង នវានុវត្ត**", (៣).ការអភិវឌ្ឍសមត្ថភាពស្ថាប័នសាធារណៈ ដោយផ្តោតលើការជំរុញអភិបាលកិច្ចល្អ, ការកែលម្អបទប្បញ្ញត្តិទីផ្សារ និងការលើកកម្ពស់ស្ថាប័នទីផ្សារការងារ និង (៤).ការអភិវឌ្ឍប្រព័ន្ធហេដ្ឋារចនាសម្ព័ន្ធ ដោយផ្តោតលើការកែលម្អគុណភាពនិងស័ក្តិសិទ្ធភាពនៃប្រព័ន្ធដឹកជញ្ជូន ប្រព័ន្ធភស្តុភារកម្ម ប្រព័ន្ធទឹកស្អាត ប្រព័ន្ធថាមពល និងប្រព័ន្ធហេដ្ឋារចនាសម្ព័ន្ធឌីជីថល ។

ដើម្បីធានាបាននូវការអនុវត្តប្រកបដោយការចូលរួមពីគ្រប់ក្រសួង-ស្ថាប័នពាក់ព័ន្ធ, ក្របខណ្ឌគោលនយោបាយនេះ បង្កើតប្រព័ន្ធអេកូផលិតភាពសេដ្ឋកិច្ច ដោយឈរលើគោលការណ៍អនុវត្តគន្លឹះចំនួន ៣ គឺ÷(១).កិច្ចសហប្រតិបត្តិការនៃគ្រប់តួអង្គសេដ្ឋកិច្ច, (២).ការបែងចែកដោយសមធម៌នៃផលប្រយោជន៍ផលិតភាព និង (៣).ការបង្កើតការងារសម្រាប់រយៈពេលវែង ដើម្បីធានាបានជោគជ័យខ្ពស់ចីរភាពនៃការលើកកម្ពស់ផលិតភាព និងការពង្រឹងសន្តិសុខការងារនិងប្រាក់ចំណូល ។ ទន្ទឹមនេះ គ្រប់ភាគីពាក់ព័ន្ធទាំងអស់ចាំបាច់ត្រូវពន្លឿនការធ្វើបរិវត្តកម្ម ពង្រឹងពង្រីកសមត្ថភាព និងធ្វើបសិដ្ឋកម្មជាប្រចាំដើម្បីអនុវត្តវិធានការគោលនយោបាយនិងផែនការសកម្មភាព ឱ្យសម្រេចបានប្រសិទ្ធភាព ប្រសិទ្ធផលភាពប្រាកដនិយម និងភាពជោគជ័យខ្ពស់ និង ទាន់ពេល ។ ក្របខណ្ឌគោលនយោបាយជាតិផលិតភាពសេដ្ឋកិច្ចកម្ពុជា ២០២២-២០៣៥ ត្រូវបានរៀបចំឡើងដោយផ្អែកលើគោលនយោបាយចម្បងៗរបស់ជាតិ រួមមាន ចក្ខុវិស័យកម្ពុជាឆ្នាំ២០៥០, យុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤, ក្របខណ្ឌគោលនយោបាយសេដ្ឋកិច្ច និង សង្គមឌីជីថលកម្ពុជា ២០២១-២០៣៥ និងគោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្មកម្ពុជាឆ្នាំ២០១៥-២០២៥ ជាដើម ។

ជាមួយគ្នានេះ ដើម្បីដឹកនាំ ជំរុញការអនុវត្ត តាមដាន ត្រួតពិនិត្យជាប្រចាំ និងវាយតម្លៃវិធានការគោលនយោបាយទាំងអស់ដែលបានដាក់ចេញ សំដៅធានាបានការអនុវត្តប្រកបដោយស័ក្តិសិទ្ធភាព គណនេយ្យភាព ការទទួលខុសត្រូវ ភាពជោគជ័យ និង មានការចូលរួមពីគ្រប់ក្រសួង-ស្ថាប័នពាក់ព័ន្ធ, ក្របខណ្ឌគោលនយោបាយជាតិផលិតភាពសេដ្ឋកិច្ចកម្ពុជា កំណត់យន្តការស្ថាប័នជា ៣កម្រិត រួមមាន÷ (១). គណៈកម្មាធិការជាតិផលិតភាពសេដ្ឋកិច្ចកម្ពុជា (**គ.ជ.ផ.ក.**) ដែលជាស្ថាប័នដឹកនាំ តម្រង់ទិស ផ្តល់យុទ្ធសាស្ត្រ ពិនិត្យសម្រេច តាមដាន និងវាយតម្លៃ ដើម្បីធានាបានប្រសិទ្ធភាពក្នុងការអនុវត្តវិធានការគោលនយោបាយដែលបានដាក់ចេញ, (២). អគ្គលេខាធិការដ្ឋាន **គ.ជ.ផ.ក.** ដែលជាសេនាធិការគាំទ្រផ្នែករដ្ឋបាលនិងបច្ចេកទេស ដើម្បីសម្របសម្រួលនិងធ្វើកិច្ចសហប្រតិបត្តិការជាមួយក្រសួង-ស្ថាប័នពាក់ព័ន្ធ និង (៣).ក្រសួង-ស្ថាប័នពាក់ព័ន្ធ ដែលជាអ្នកអនុវត្តគោលនយោបាយត្រូវទទួលបន្ទុកនិងទទួលខុសត្រូវលើការរៀបចំកម្មវិធី គម្រោង និងផែនការសកម្មភាពលម្អិតឱ្យឆ្លើយតបនឹងវិធានការគោលនយោបាយស្របតាមមុខងារ តួនាទី ភារកិច្ច និងឯកទេសកម្មរបស់ខ្លួន ។ ជាមួយគ្នានេះ ក្រសួង-ស្ថាប័នពាក់ព័ន្ធ ត្រូវបញ្ជ្រាបសញ្ញាណផលិតភាពសេដ្ឋកិច្ច (notion of productive economy) ទៅក្នុងគ្រប់ឯកសារគោលនយោបាយ យុទ្ធសាស្ត្រ និងកម្មវិធី នៅតាមវិស័យរបស់ខ្លួន ។ លើសពីនេះ ដើម្បីសម្រេចបានជោគជ័យតាមក្របខណ្ឌពេលវេលាកំណត់, ការអនុវត្តក្របខណ្ឌគោលនយោបាយនេះទាមទារឱ្យមានការចូលរួមយ៉ាងសកម្ម ប្រកបដោយស្មារតីសហការ ភាពជាម្ចាស់ និងការទទួលខុសត្រូវខ្ពស់ ស្របតាមអភិក្រម “***ជីវភាពនៃប្រព័ន្ធតួអង្គតែមួយ*** ។

ជារួម ក្របខណ្ឌគោលនយោបាយនេះមានចក្ខុវិស័យ គោលបំណង និងយន្តការអនុវត្តច្បាស់លាស់ ព្រមទាំងមានថ្នាក់ដឹកនាំកំពូលរបស់ស្ថាប័នជាអ្នកដឹកនាំនិងសម្របសម្រួល ដើម្បីធានាបានភាពជោគជ័យខ្ពស់ក្នុងដំណើរនៃការអនុវត្តជាក់ស្តែង ។ ដើម្បីបង្កលក្ខណៈងាយស្រួលក្នុងការគ្រប់គ្រងនិងតាមដាន ប្រកបដោយប្រសិទ្ធផលនិងប្រសិទ្ធភាព, គ្រប់សកម្មភាពអាទិភាពត្រូវមានសូចនាករ ដែលអាចវាស់វែងបានដោយទិន្នន័យនៃសកម្មភាពអាទិភាពនីមួយៗ នឹងត្រូវប្រមូលនិងចងក្រង ដើម្បីយល់ដឹងពេញលេញអំពីវឌ្ឍនភាពនិងលទ្ធភាព ដែលអាចសម្រេចបានតាមក្របខណ្ឌពេលវេលាកំណត់ ។ ក្របខណ្ឌគោលនយោបាយនេះ ត្រូវចាត់ទុកថាជា **ឯកសាររស់** ដែលអាចនឹងត្រូវកែសម្រួលជាយថាហេតុ ដើម្បីទាញយកផលប្រយោជន៍ជាអតិបរមា ព្រមទាំងសម្របទៅនឹងបរិការណ៍ជាក់ស្តែងនិងការវិវត្តនៃសង្គម-សេដ្ឋកិច្ចទាំងនៅក្នុងប្រទេស តំបន់ និងសកលលោក ។

## ១. សេចក្ដីផ្ដើម

### ១.១. បរិការណ៍ និង ឧស្សាហាទានភាពនៃការរៀបចំក្របខណ្ឌគោលនយោបាយ

កម្ពុជា សម្រេចបានសមិទ្ធផលធំៗជាច្រើន ក្នុងការអភិវឌ្ឍសង្គម-សេដ្ឋកិច្ច និង ការរក្សាបាននូវស្ថិរភាពកំណើនម៉ាក្រូសេដ្ឋកិច្ច ដែលឆ្លុះបញ្ចាំងតាមរយៈអត្រាអតិផរណានិងអត្រានិកម្មភាពទាប ព្រមទាំងរក្សាបាននូវកំណើនសេដ្ឋកិច្ចខ្ពស់ប្រមាណ ៧% ក្នុងមួយឆ្នាំ ក្នុងរយៈពេលជាង២ទសវត្សរ៍កន្លងមកនេះ រហូតដល់មុនការផ្ទុះឡើងនៃជំងឺកូវីដ-១៩ ដែលបានរុញច្រានសេដ្ឋកិច្ចពិភពលោក រួមទាំងសេដ្ឋកិច្ចកម្ពុជាផងដែរ ឱ្យធ្លាក់ក្នុងកំណើនអវិជ្ជមាន ។ ដោយផ្អែកលើកំណើនដ៏ខ្ពស់កន្លងមកនេះ, កម្ពុជា បានប្រែក្លាយពីប្រទេសមានចំណូលទាប ទៅជាប្រទេសមានចំណូលមធ្យមកម្រិតទាបនៅឆ្នាំ២០១៥ ដោយសារមានការកើនឡើងបន្តបន្ទាប់គួរឱ្យកត់សម្គាល់នៃផលិតផលក្នុងស្រុកសរុបសម្រាប់ប្រជាជនកម្ពុជាម្នាក់ៗ ។ កំណើនខ្ពស់និងវិបុលភាពសេដ្ឋកិច្ចទាំងនេះ ពឹងផ្អែកជាចម្បងលើមូលដ្ឋានសេដ្ឋកិច្ចតូចចង្អៀត ដែលមានតម្លៃបន្ថែមទាបចំនួន៤ប៉ុណ្ណោះ រួមមាន វិស័យវាយនភណ្ឌ កាត់ដេរសម្លៀកបំពាក់ និងផលិតស្បែកជើង វិស័យកសិកម្ម វិស័យសំណង់ និងវិស័យទេសចរណ៍ ។ ការណ៍នេះធ្វើឱ្យសេដ្ឋកិច្ចកម្ពុជាងាយទទួលរងហានិភ័យនានាពីខាងក្រៅ ជាពិសេសការប្រែប្រួលយ៉ាងឆាប់រហ័សនៃស្ថានភាពសេដ្ឋកិច្ចសកលនិងវិបត្តិផ្សេងៗ ដូចជា វិបត្តិហិរញ្ញវត្ថុនិងសេដ្ឋកិច្ចសកល, ការរីករាលដាលនៃជំងឺកូវីដ-១៩, ភាពតានតឹងនៃភូមិសាស្ត្រនយោបាយ និងសង្គ្រាមពាណិជ្ជកម្មពិភពលោកជាដើម ។

ដើម្បីសម្រេចបានចក្ខុវិស័យក្នុងការប្រែក្លាយកម្ពុជា ទៅជាប្រទេសចំណូលមធ្យមកម្រិតខ្ពស់នៅឆ្នាំ២០៣០ និង ជាប្រទេសចំណូលខ្ពស់នៅឆ្នាំ២០៥០, រាជរដ្ឋាភិបាលកម្ពុជា បានដាក់ចេញនូវគោលនយោបាយជាតិធំៗមួយចំនួន ជាអាទិ៍ យុទ្ធសាស្ត្រចតុកោណ, គោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្មកម្ពុជា ២០១៥-២០២៥, ក្របខណ្ឌគោលនយោបាយសេដ្ឋកិច្ច និង សង្គមឌីជីថលកម្ពុជា ២០២១-២០៣៥ និង គោលនយោបាយរដ្ឋាភិបាលឌីជីថលកម្ពុជា ២០២២-២០៣៥ សម្រាប់ធ្វើបរិវត្តកម្មនិងពិពិធកម្មសេដ្ឋកិច្ច ព្រមទាំងធ្វើបរិវត្តកម្មឌីជីថល ដើម្បីជំរុញបន្ថែមការកែទម្រង់ចាំបាច់នានា ការកសាងស្ថាប័នរឹងមាំ និង អភិបាលកិច្ចល្អក្នុងគោលបំណងបង្កើតបរិយាកាសទាក់ទាញការវិនិយោគ និងជំរុញការអភិវឌ្ឍសេដ្ឋកិច្ច និងសង្គម ប្រកបដោយចីរភាព ភាពធន់ និងបរិយាបន្ន ។ ក្របខណ្ឌគោលនយោបាយជាតិផលិតភាពសេដ្ឋកិច្ចកម្ពុជា គឺជាមគ្គុទ្ទេសក៍ ដើម្បីកសាងនិងលើកកម្ពស់ផលិតភាពសេដ្ឋកិច្ច សម្រាប់បង្កើនភាពប្រកួតប្រជែង ព្រមទាំងជំរុញកំណើននិងសន្ទុះនៃការអភិវឌ្ឍសង្គម-សេដ្ឋកិច្ច សំដៅរួមចំណែកដល់ការកសាងម៉ូដែលកំណើនថ្មីផ្អែកលើផលិតភាព, ការអភិវឌ្ឍបៃតង និងការសម្រេចបានចក្ខុវិស័យកម្ពុជាឆ្នាំ២០៥០ ។ ក្របខណ្ឌគោលនយោបាយនេះ នឹងរួមចំណែកផងដែរដល់ភាពជោគជ័យនៃការធ្វើបរិវត្តកម្ម

រចនាសម្ព័ន្ធសេដ្ឋកិច្ចកម្ពុជា ចេញពីសេដ្ឋកិច្ចផ្អែកលើអតិពលកម្មដែលមានតម្លៃបន្ថែមទាប ទៅជាសេដ្ឋកិច្ចផ្អែកលើជំនាញនិងនវានុវត្តន៍ដែលមានតម្លៃបន្ថែមខ្ពស់ ។

ការកសាងនិងជំរុញផលិតភាពសេដ្ឋកិច្ចខ្ពស់ មានសារៈសំខាន់ក្នុងការបង្កើនវិបុលភាពសង្គម និងកម្រិតជីវភាពរបស់ប្រជាជន ព្រមទាំងលើកកម្ពស់ភាពប្រកួតប្រជែងរបស់កម្ពុជា នៅក្នុងបរិការណ៍នៃការកើនឡើងកាន់តែខ្លាំងនៃការប្រកួតប្រជែងនៅក្នុងតំបន់និងសកលលោក ទាំងផ្នែកសេដ្ឋកិច្ចនិងភូមិសាស្ត្រនយោបាយ ព្រមទាំងការរីករាលដាលនៃវិបត្តិជំងឺកូវីដ-១៩ និងសង្គ្រាមពាណិជ្ជកម្ម ដើម្បីប្រែក្លាយបញ្ហាប្រឈមទាំងនេះ ទៅជាកាលានុវត្តភាពក្នុងការកសាងមូលដ្ឋានគ្រឹះសេដ្ឋកិច្ចជាតិឱ្យបានកាន់តែរឹងមាំ សម្រាប់លើកកម្ពស់សន្តិសុខសេដ្ឋកិច្ចនិងសុខុមាលភាពសង្គមជាតិ ។ ដូចនេះ ការរៀបចំក្របខណ្ឌគោលនយោបាយជាតិផលិតភាពសេដ្ឋកិច្ចកម្ពុជា គឺមានភាពចាំបាច់និងបន្ទាន់ ដើម្បីជំរុញការកែទម្រង់បន្ថែមទៀត និងដាក់ចេញវិធានការគោលនយោបាយ សំដៅបង្កើនសមត្ថភាពកម្លាំងពលកម្មឱ្យមានជំនាញខ្ពស់, ពង្រឹងបទប្បញ្ញត្តិទីផ្សារ, ជំរុញការប្រកួតប្រជែងស្មើភាព, ដោះស្រាយភាពអសកម្មទីផ្សារ, កសាងបរិស្ថានធុរកិច្ចនិងស្ថាប័នល្អ និង បង្កើនការវិនិយោគលើហេដ្ឋារចនាសម្ព័ន្ធគាំទ្រកំណើនដែលមានគុណភាពខ្ពស់ ដើម្បីដាក់វិថីកំណើនសេដ្ឋកិច្ចកម្ពុជាលើគន្លងកំណើនប្រកបដោយចីរភាពភាពធន់ និងបរិយាបន្ន ។

ក្នុងន័យនេះ រាជរដ្ឋាភិបាលកម្ពុជា ដាក់ចេញក្របខណ្ឌគោលនយោបាយជាតិផលិតភាពសេដ្ឋកិច្ចកម្ពុជា ២០២២-២០៣៥ ដើម្បីតម្រង់ទិសដៅសេដ្ឋកិច្ចកម្ពុជា ឆ្ពោះទៅសេដ្ឋកិច្ចផ្អែកលើជំនាញ នវានុវត្តន៍ និងតម្លៃបន្ថែមខ្ពស់ ដោយឈរលើអភិក្រម “**ទទួលយក បន្សាំ និង នវានុវត្ត**”។ ក្របខណ្ឌគោលនយោបាយនេះ មាន៥ផ្នែក ។ ផ្នែកទី១ គឺសេចក្តីផ្តើម ដែលពិពណ៌នាអំពីបរិការណ៍ និងទស្សនាទាននៃការរៀបចំក្របខណ្ឌគោលនយោបាយជាតិផលិតភាពសេដ្ឋកិច្ចកម្ពុជា, និយមន័យនៃផលិតភាពសេដ្ឋកិច្ច និងវិបាកនៃផលិតភាពសេដ្ឋកិច្ច ។ ផ្នែកទី២ ពិពណ៌នាអំពីទិដ្ឋភាពរួម ការត្រៀមខ្លួនក្នុងការកសាង និងជំរុញផលិតភាពសេដ្ឋកិច្ចកម្ពុជា ។ ផ្នែកទី៣ គឺជាក្របខណ្ឌគោលនយោបាយ ដែលកំណត់ពីចក្ខុវិស័យ គោលបំណង គោលដៅ គោលការណ៍ក្នុងការជំរុញផលិតភាពសេដ្ឋកិច្ច និងវិធានការគោលនយោបាយគន្លឹះ ។ ផ្នែកទី៤ កំណត់ក្របខណ្ឌអនុវត្ត និង យន្តការសម្របសម្រួល តាមដាន និងវាយតម្លៃ ។ ផ្នែកទី៥ គឺជាសេចក្តីសន្និដ្ឋានរួម ។

## ១.២. ទស្សនាទាន និង និយមន័យនៃផលិតភាពសេដ្ឋកិច្ច

ទស្សនាទាននៃផលិតភាព មានប្រភពចេញមកពីម៉ូដែលកំណើនសេដ្ឋកិច្ចដែលបង្កើតឡើងនៅឆ្នាំ១៩៥៧ ដោយសាស្ត្រាចារ្យ **រ៉ូបឺត សូឡូ** (Robert Solow) ដែលជាអ្នកទទួលបានពានរង្វាន់សេដ្ឋកិច្ច

តាមរយៈការរួមចំណែក ក្នុងការពន្យល់និងបញ្ជ្រាបការយល់ដឹងអំពីកត្តាជំរុញកំណើនសេដ្ឋកិច្ចជាតិ និង ភាពខុសគ្នានៃវិបុលភាពសង្គម-សេដ្ឋកិច្ចនៃបណ្តាប្រទេសនៅក្នុងសកលលោក ។ ផ្អែកលើម៉ូដែលកំណើននេះ ផលិតភាពសេដ្ឋកិច្ច ត្រូវជះឥទ្ធិពលដោយមូលធនជាក់ស្តែង (physical capital) ក្នុងកម្លាំងពលកម្មម្នាក់ៗ និងមូលធនមនុស្ស ពោលគឺការកើនឡើងនៃមូលធនជាក់ស្តែង សម្រាប់កម្លាំងពលកម្មម្នាក់ៗ និងការកើនឡើង នៃមូលធនមនុស្សមានផលវិជ្ជមានក្នុងការជំរុញកំណើនផលិតភាពសេដ្ឋកិច្ច ។ បន្ទាប់មក ម៉ូដែលផលិតភាព សេដ្ឋកិច្ចត្រូវបានអភិវឌ្ឍជាបន្តបន្ទាប់ កែលម្អ និងធ្វើតេស្តជាច្រើន ដើម្បីបញ្ជាក់សុពលភាពនិងភាពដែល អាចអនុវត្តបាននៃម៉ូដែលថ្មីនេះ ។ សម្រាប់ម៉ូដែលផលិតភាពសេដ្ឋកិច្ចថ្មីនេះ, កត្តាជំរុញផលិតភាពសេដ្ឋកិច្ច ត្រូវបានបង្កើនបន្ថែមមួយចំនួន ដូចជា កត្តាបច្ចេកទេសនិងនវានុវត្តន៍បច្ចេកវិទ្យា, កត្តាមូលធនមនុស្ស, កត្តាពាក់ព័ន្ធនឹងការគ្រប់គ្រងនិងប្រព័ន្ធលើកទឹកចិត្ត, កត្តាសេដ្ឋកិច្ច, កត្តាស្ថាប័ន និងកត្តាសុខភាព ។

- **កត្តាបច្ចេកទេស និង នវានុវត្តន៍បច្ចេកវិទ្យា÷** ផលិតភាពសេដ្ឋកិច្ច អាចជះឥទ្ធិពលជាវិជ្ជមាន ដោយការកើនឡើងនៃការវិនិយោគលើមូលធនជាក់ស្តែង ដូចជា យន្តសារព័ន្ធ (machinery) និង ឧបករណ៍សម្រាប់ដំណើរការផលិតកម្ម, នវានុវត្តន៍បច្ចេកវិទ្យា និងការស្រាវជ្រាវនិងការអភិវឌ្ឍ (R&D) ។ ការវិនិយោគលើមូលធនជាក់ស្តែង នឹងបង្កើនមូលធនសម្រាប់កម្លាំងពលកម្មម្នាក់ៗ ដែលអនុញ្ញាតឱ្យ កម្លាំងពលកម្មមានយន្តសារព័ន្ធនិងឧបករណ៍ផលិតកម្មគ្រប់គ្រាន់ ក្នុងការអនុវត្តការងារផលិតកម្មដែល នឹងបង្កើនផលិតភាពសម្រាប់កម្លាំងពលកម្មម្នាក់ៗ ។ ដូចគ្នាដែរ ការសិក្សាស្រាវជ្រាវជាច្រើនបានរកឃើញថា នវានុវត្តន៍បច្ចេកវិទ្យា និងការស្រាវជ្រាវនិងការអភិវឌ្ឍ មានផលវិជ្ជមានទៅលើផលិតភាពសេដ្ឋកិច្ច ។

- **កត្តាមូលធនមនុស្ស÷** គុណភាពនៃមូលធនមនុស្ស ដើរតួនាទីសំខាន់ក្នុងការបង្កើនផលិតភាព តាមរយៈសមត្ថភាព កិច្ចខិតខំប្រឹងប្រែង និងគំនិតច្នៃប្រតិដ្ឋ ក្នុងការអនុវត្តការងារ ។ ការលើកកម្ពស់ សមត្ថភាព ដែលត្រូវជំរុញដោយគុណភាពនៃការអប់រំនិងបណ្តុះបណ្តាល ជះឥទ្ធិពលវិជ្ជមានទៅលើ ផលិតភាព តាមរយៈសមត្ថភាពក្នុងការចាប់យកបច្ចេកវិទ្យានិងនវានុវត្តន៍ ព្រមទាំងការបញ្ជ្រាបបច្ចេកវិទ្យា និងនវានុវត្តន៍ ទៅក្នុងកន្លែងការងារ ។ ជាមួយគ្នានេះ កិច្ចខិតខំប្រឹងប្រែងក្នុងការអនុវត្តការងារដែល ជំរុញដោយយន្តការលើកទឹកចិត្តល្អ និងការពង្រឹងគុណាធិបតេយ្យ (meritocracy) ត្រូវបានរកឃើញថា មានផលវិជ្ជមានលើកំណើនផលិតភាពសេដ្ឋកិច្ច ។

- **កត្តាពាក់ព័ន្ធនឹងការគ្រប់គ្រង និង ប្រព័ន្ធលើកទឹកចិត្ត÷** កត្តានេះមានទំនាក់ទំនងជាមួយកត្តា ផលិតភាពខាងលើ ដោយហេតុថាការគ្រប់គ្រងល្អប្រកបដោយប្រសិទ្ធផលនិងប្រសិទ្ធភាព ត្រូវការមូលធន មនុស្សដែលមានសមត្ថភាពខ្ពស់ ទាំងជំនាញរឹងនិងជំនាញទន់ ព្រមទាំងប្រកាន់ខ្ជាប់នូវគុណធម៌និង យុត្តិធម៌ក្នុងការអនុវត្តប្រព័ន្ធលើកទឹកចិត្ត ស្របតាមគោលការណ៍គុណាធិបតេយ្យ ដែលទាំងនេះផ្តល់នូវ

ក្តីសង្ឃឹមនិងភាពច្បាស់លាស់ក្នុងការអនុវត្តការងារ ។ ជាងនេះទៀត ការបង្កើនផលិតភាពអាចសម្រេចបាន តាមរយៈការបែងចែកកម្លាំងពលកម្មទៅតាមជំនាញ និងយន្តការចំនួន ៣ គឺការកើនឡើងនៃជំនាញរបស់កម្លាំងពលកម្មម្នាក់ៗ ការសន្សំពេលក្នុងការអនុវត្តការងារ និងការប្រើប្រាស់ម៉ាស៊ីនដើម្បីជំនួសកម្លាំងពលកម្ម ។

- **កត្តាសេដ្ឋកិច្ច÷** ផលិតភាពសេដ្ឋកិច្ចត្រូវបានជំរុញដោយកត្តាសេដ្ឋកិច្ចមួយចំនួន ដូចជា តម្រូវការសរុប ពាណិជ្ជកម្មអន្តរជាតិ និងការវិនិយោគផ្ទាល់ពីបរទេស ។ កំណើនតម្រូវការសរុប នាំឱ្យមានការកើនឡើងនៃផលិតកម្មនិងផលិតភាព តាមរយៈសេដ្ឋកិច្ចមាត្រដ្ឋាននិងឥទ្ធិពលនៃការយល់ដឹងអំពីការអនុវត្តការងារ ។ លើសពីនេះ ពាណិជ្ជកម្មអន្តរជាតិនិងការវិនិយោគផ្ទាល់ពីបរទេសនាំមកនូវបច្ចេកវិទ្យាថ្មីៗ ចំណេះដឹង និងចំណេះធ្វើជាច្រើន ដែលជាកត្តាជំរុញផលិតភាពពលកម្ម ។ ក្នុងរយៈពេលប្រមាណ ៥ ទសវត្សរ៍ចុងក្រោយនេះ, ការសិក្សាស្រាវជ្រាវជាច្រើនបានរកឃើញថា ពាណិជ្ជកម្មអន្តរជាតិនិងការវិនិយោគផ្ទាល់ពីបរទេស រួមចំណែកយ៉ាងសំខាន់ដល់ការផ្ទេរបច្ចេកវិទ្យានិងចំណេះដឹង ព្រមទាំងការលើកកម្ពស់ផលិតភាពពលកម្ម ។

- **កត្តាស្ថាប័ន÷** ស្ថាប័ន ដើរតួនាទីយ៉ាងសំខាន់ក្នុងការអភិវឌ្ឍធុរកិច្ច, ការលើកកម្ពស់ពាណិជ្ជកម្មអន្តរជាតិ, ការទាក់ទាញការវិនិយោគផ្ទាល់ពីបរទេស, ការលើកទឹកចិត្តដល់គ្រប់តួអង្គសេដ្ឋកិច្ច និងការប្រកួតប្រជែងស្មើភាព ដែលសកម្មភាពទាំងនេះមានផលវិជ្ជមានលើផលិតភាពសេដ្ឋកិច្ច ។ ការសិក្សាស្រាវជ្រាវជាច្រើនបានគូសបញ្ជាក់ថា ស្ថាប័ននយោបាយនិងសេដ្ឋកិច្ច ដែលមានលក្ខណៈបរិយាបន្នមានទំនាក់ទំនងវិជ្ជមានទៅនឹងផលិតភាព និងកំណើនសេដ្ឋកិច្ចក្នុងរយៈពេលវែង ពោលគឺ ប្រទេសដែលមានគុណភាពស្ថាប័នខ្ពស់សម្រេចបានកំណើនផលិតភាពនិងកំណើនសេដ្ឋកិច្ចខ្ពស់ ប្រកបដោយចីរភាព ភាពធន់ និងបរិយាបន្ន ។

- **កត្តាសុខភាព÷** សុខភាព គឺជាកត្តាកំណត់ដ៏សំខាន់មួយនៃផលិតភាពសេដ្ឋកិច្ច ។ និយោជិតដែលមានសុខភាពល្អសម្រេចបានប្រសិទ្ធផលខ្ពស់, ងាយចាប់យកចំណេះដឹងនិងបច្ចេកវិទ្យាថ្មីៗ និងមានការតាំងចិត្តខ្ពស់ក្នុងការបង្កើនមូលធនមនុស្ស ។ សុខភាពល្អមានឥទ្ធិពលវិជ្ជមានទៅលើការអប់រំ និងការបណ្តុះបណ្តាលបច្ចេកទេសវិជ្ជាជីវៈ ហើយរួមចំណែកដល់ការផ្គត់ផ្គង់កម្លាំងពលកម្មដែលមានគុណភាពខ្ពស់ ។ លើសពីនេះ សុខភាពល្អមានទំនាក់ទំនងយ៉ាងជិតស្និទ្ធទៅនឹងភាពសប្បាយចិត្ត ដែលត្រូវបានរកឃើញថាមានឥទ្ធិពលវិជ្ជមានទៅលើផលិតភាពសេដ្ឋកិច្ច ។

ផ្អែកលើការសិក្សាស្រាវជ្រាវ ទស្សនាទាននៃផលិតភាពមានការវិវត្តជាបន្តបន្ទាប់ ដោយវិសាលភាពរបស់ផលិតភាពត្រូវបានពង្រីកចាប់ពីបញ្ហាសង្គម ដូចជា ការបង្កើតការងារ សន្តិសុខការងារ និងការកាត់

បន្ថយភាពក្រីក្រ រហូតដល់ការការពារបរិស្ថាន ។ បច្ចុប្បន្ននេះ ទស្សនាទានផលិតភាពមួយចំនួនទៀតក៏ត្រូវបានប្រើប្រាស់ផងដែរ ដូចជា ផលិតភាពសង្គមនិងផលិតភាពចំណេះដឹង ។ ទោះជាយ៉ាងណាក៏ដោយ អង្គការផលិតភាពអាស៊ី (APO) បានកំណត់និយមន័យផលិតភាពថា ជាទំនាក់ទំនងរវាងបរិមាណនៃទិន្នផល (ទំនិញនិងសេវាកម្មដែលផលិតបាន) និងបរិមាណនៃធាតុចូល (កម្លាំងពលកម្ម មូលធន ថាមពល) ដែលបានប្រើប្រាស់ក្នុងផលិតកម្ម ។ ចំណែកឯ ផលិតភាពសេដ្ឋកិច្ច គឺជាអនុបាតនៃបរិមាណទិន្នផលធៀបទៅនឹងបរិមាណធាតុចូល ដោយរួមបញ្ចូលទាំងប្រសិទ្ធផលនិងស័ក្តិសិទ្ធភាពនៃការផលិតទំនិញនិងសេវាកម្ម ផងដែរ ។

ប្រសិទ្ធផលក្នុងការផលិតដើរតួនាទីយ៉ាងសំខាន់ ក្នុងការធានាថាផលិតកម្មត្រូវបានធ្វើឡើងដោយប្រើប្រាស់ធនធានដែលជាធាតុចូលបានប្រសើរបំផុត ។ ដើម្បីបង្កើនប្រសិទ្ធផល, បសិដ្ឋកម្មនៃដំណើរការផលិតកម្ម គឺមានភាពចាំបាច់ ដែលត្រូវជំរុញដោយកត្តាសំខាន់ៗមួយចំនួន ដូចជា ការប្រកួតប្រជែងស្មើភាពទំហំទីផ្សារធំ មាត្រដ្ឋានផលិតកម្មធំ កម្លាំងពលកម្មមានគុណភាព និងវប្បធម៌នៃការធ្វើបសិដ្ឋកម្មជាប់ជានិច្ច ។ ជាមួយគ្នានេះ ស័ក្តិសិទ្ធភាពនៃផលិតកម្ម គឺធានាថាផលិតផលដែលមានតម្រូវការក្នុងទីផ្សារត្រូវបានផលិតដើម្បីបង្កើនតម្លៃបន្ថែមឱ្យបានជាអតិបរមា ។ ដើម្បីធានាបានស័ក្តិសិទ្ធភាព, បសិដ្ឋកម្មសម្រាប់ផលិតផលត្រូវជំរុញជាបន្តបន្ទាប់ សំដៅធានានូវនិរន្តរភាពនៃតម្រូវការសម្រាប់ផលិតផលទាំងនេះ ។ ជាការសំខាន់ ផលិតផលថ្មី ឬ ម៉ូដែលធុរកិច្ចថ្មីគួរត្រូវបង្កើតឡើងដើម្បីបម្រើទីផ្សារដែលមានស្រាប់និងទីផ្សារថ្មី ដោយសារមានការផ្លាស់ប្តូរនៃតម្រូវការរបស់អ្នកប្រើប្រាស់ និងការលេចឡើងនៃតម្រូវការថ្មីៗ ។ ជាងនេះទៀត នវានុវត្តន៍មានតួនាទីសំខាន់ក្នុងការជំរុញបសិដ្ឋកម្មផលិតផលនិងនវានុវត្តន៍ ដើម្បីបង្កើនស័ក្តិសិទ្ធភាព និងលើកកម្ពស់កំណើនផលិតភាពសេដ្ឋកិច្ច ។ កត្តាសំខាន់ៗសម្រាប់ជំរុញនវានុវត្តន៍ មានដូចជា ការវិនិយោគលើការស្រាវជ្រាវនិងការអភិវឌ្ឍ, យន្តការជំរុញការទទួលយកបច្ចេកវិទ្យាថ្មី, កម្លាំងពលកម្មមានជំនាញខ្ពស់, ប្រព័ន្ធគ្រប់គ្រងល្អ និងវប្បធម៌នៃការធ្វើនវានុវត្តន៍ ។

ជាទូទៅ ផលិតភាពសេដ្ឋកិច្ចត្រូវបានបែងចែកជា ២ប្រភេទ ដូចខាងក្រោម÷

**(១). ផលិតភាពនៃកត្តាផលិតកម្មតែមួយ÷** ផលិតភាពនៃកត្តាផលិតកម្មតែមួយ ដែលជាទូទៅសំដៅទៅលើផលិតភាពពលកម្មមានលក្ខណៈងាយស្រួលក្នុងការវាស់វែងនិងគ្រប់គ្រង ហើយត្រូវបានប្រើប្រាស់យ៉ាងទូលំទូលាយ ដោយអង្គការផលិតភាពអាស៊ីនិងប្រទេសជាច្រើននៅក្នុងពិភពលោក ។ នៅកម្រិតថ្នាក់ជាតិ, ផលិតភាពនៃកម្លាំងពលកម្មមួយឯកតា គឺជាអនុបាតនៃតម្លៃបន្ថែមធៀបទៅនឹងចំនួនការងារសរុប ។ ការកើនឡើងនៃផលិតភាពសម្រាប់កម្លាំងពលកម្មមួយឯកតា មានសារៈសំខាន់បំផុតសម្រាប់ប្រទេសជាច្រើន ដោយហេតុថានៅក្នុងរយៈពេលវែង ផលិតភាពគឺជាអ្វីៗទាំងអស់ ហើយសមត្ថភាព

របស់ប្រទេសក្នុងការធ្វើឱ្យប្រសើរឡើងនូវកម្រិតជីវភាពរបស់ប្រជាជន គឺពឹងផ្អែកស្ទើរតែទាំងស្រុងទៅលើសមត្ថភាពក្នុងការបង្កើនផលិតភាពសម្រាប់កម្លាំងពលកម្មម្នាក់ៗ ។ ការណ៍នេះគឺដោយសារកំណើននៃផលិតភាពសម្រាប់កម្លាំងពលកម្មម្នាក់ៗ មានទំនាក់ទំនងយ៉ាងជិតស្និទ្ធទៅនឹងការកើនឡើងនៃប្រាក់ឈ្នួល, ការធ្លាក់ចុះនៃថ្លៃទំនិញនិងសេវាកម្ម, ការកើនឡើងនៃប្រាក់ចំណេញនិងការរីកលូតលាស់របស់ធុរកិច្ច, ការបង្កើតការងារថ្មី និងការធ្លាក់ចុះនៃកម្រិតភាពក្រីក្រនិងគម្លាតវិសមភាព ។

**(២).ផលិតភាពនៃពហុកត្តាផលិតកម្ម÷** ការវាស់វែងផលិតភាពនៃពហុកត្តាផលិតកម្មគឺមានភាពស្មុគស្មាញ ដោយសារការវាស់វែងតាមវិធីសាស្ត្រនេះជាប់ពាក់ព័ន្ធនឹងធាតុចូលច្រើនប្រភេទនិងមានតម្រូវការទិន្នន័យខ្ពស់ ។ ផលិតភាពនៃពហុកត្តាផលិតកម្ម គឺជាអនុបាតនៃតម្លៃបន្ថែមធៀបនឹងធាតុចូលសរុបទាំងអស់ ដែលជាទូទៅសំដៅទៅលើកម្លាំងពលកម្ម មូលធន និងថាមពល ។ ការកើនឡើងនៃប្រពលភាពមូលធន (capital intensive) គឺជាមធ្យោបាយទូទៅក្នុងការបង្កើនផលិតភាពពលកម្ម ដែលការណ៍នេះជំរុញឱ្យមានការផ្លាស់ប្តូរពីឧស្សាហូបនីយកម្ម ផ្អែកលើកម្លាំងពលកម្មមានជំនាញទាបទៅជាឧស្សាហូបនីយកម្មផ្អែកលើប្រពលភាពមូលធន ។ ការប្រែប្រួលនៃការប្រើប្រាស់ធាតុចូល នឹងជះឥទ្ធិពលទៅលើផលិតភាពសេដ្ឋកិច្ច ។ ជាឧទាហរណ៍ ការកើនឡើងនៃមូលធន ឬ បសិដ្ឋកម្មនៃបច្ចេកវិទ្យាអាចបង្កើនតម្លៃបន្ថែម ដោយកម្លាំងពលកម្មត្រូវបានរក្សានៅដដែល ។ កំណើនផលិតភាពខ្ពស់ ជួយលើកកម្ពស់ភាពប្រកួតប្រជែងយកឈ្នះលើថ្លៃលក់នៃទំនិញនិងសេវាកម្ម ព្រមទាំងជួយពង្រីកចំណែកទីផ្សារកាន់តែធំ ។ ក្នុងរយៈពេលវែង, ផលិតភាពសេដ្ឋកិច្ចអាចរក្សាបានចីរភាព តាមរយៈការកើនឡើងនៃកំណើនរបស់ផលិតភាពពហុកត្តាផលិតកម្ម ដែលឆ្លុះបញ្ចាំងដោយប្រសិទ្ធផលនិងស័ក្តិសិទ្ធភាពនៃការប្រើប្រាស់ធនធានពលកម្ម មូលធន បច្ចេកវិទ្យាថ្មី និងនវានុវត្តន៍ ។

## ១.៣. វិបាកនៃក្របខណ្ឌគោលនយោបាយផលិតភាពសេដ្ឋកិច្ច

ក្របខណ្ឌគោលនយោបាយជាតិផលិតភាពសេដ្ឋកិច្ចកម្ពុជា គឺជាកម្លាំងចលករសម្រាប់ជំរុញកំណើនសេដ្ឋកិច្ចកម្ពុជាឱ្យមានប្រសិទ្ធផល ស័ក្តិសិទ្ធភាព ភាពប្រកួតប្រជែងខ្ពស់ និង លើកកម្ពស់កម្រិតជីវភាព វិបុលភាព និងសុខុមាលភាពសង្គម ។ ការសិក្សាជាច្រើនបានបង្ហាញនូវវិបាកវិជ្ជមាននៃផលិតភាពសេដ្ឋកិច្ច ដូចខាងក្រោម÷

- **ផលិតភាព និង កំណើនសេដ្ឋកិច្ច÷** ផលិតភាពមានទំនាក់ទំនងយ៉ាងជិតស្និទ្ធជាមួយនឹងសមិទ្ធកម្មសេដ្ឋកិច្ច ពោលគឺការកើនឡើងនៃផលិតភាពនឹងជំរុញកំណើនសេដ្ឋកិច្ចជាតិ ។ កំណើនផលិតភាពទទួលបានមកពីការប្រើប្រាស់សក្តានុពលសេដ្ឋកិច្ច ប្រកបដោយប្រសិទ្ធផលខ្ពស់និងចំទិសដៅ ។ ការសិក្សា

ស្រាវជ្រាវជាច្រើនក៏បានបង្ហាញផងដែរថា ក្នុងរយៈប៉ុន្មានទសវត្សរ៍ថ្មីៗ កំណើនសេដ្ឋកិច្ចមានភាពថមថយដោយសារមានការធ្លាក់ចុះនៃកំណើនផលិតភាពសេដ្ឋកិច្ច ។

- **ផលិតភាព និង ការបង្កើតការងារ÷** ផលិតភាព ជួយបង្កើនសមត្ថភាពនិងលទ្ធភាពឱ្យសហគ្រាស ឬ ក្រុមហ៊ុន មានធនធាននិងមូលធនសម្រាប់ជួលកម្លាំងពលកម្មបន្ថែម ដើម្បីបំពេញការងារនិងតម្រូវការទីផ្សារ ។ ជាលទ្ធផល និយោជកបង្កើនការងារសម្រាប់ការអភិវឌ្ឍនិងការរីកចម្រើនអាជីវកម្មរបស់ខ្លួន ។ ដូច្នេះ នៅពេលដែលសហគ្រាសសម្រេចបានកំណើនផលិតភាព, សហគ្រាសនឹងមានសមត្ថភាពនិងលទ្ធភាពក្នុងការធ្វើពិពិធកម្មសេដ្ឋកិច្ច ដើម្បីចាប់យកតម្លៃបន្ថែមនៃខ្សែច្រវាក់ផ្គត់ផ្គង់និងខ្សែច្រវាក់តម្លៃ ។ ការណ៍នេះនាំឱ្យបង្កើត ឬ បង្កើនការងារតាមតម្រូវការនៃវិស័យសេដ្ឋកិច្ចនីមួយៗ ។

- **ផលិតភាព និង ប្រាក់ឈ្នួល÷** ការកំណត់ប្រាក់ឈ្នួល គឺអាស្រ័យលើកត្តាសេដ្ឋកិច្ចមួយចំនួនជាពិសេសកម្រិតផលិតភាពសេដ្ឋកិច្ច ដោយហេតុថាការកើនឡើងនៃផលិតភាពអនុញ្ញាតឱ្យស្ថាប័នធុរកិច្ចមានលទ្ធភាពនិងសមត្ថភាពហិរញ្ញវត្ថុ ក្នុងការបង្កើនប្រាក់ឈ្នួលសម្រាប់បុគ្គលិករបស់ខ្លួន ។ ការសិក្សាស្រាវជ្រាវជាច្រើន បានផ្តល់ភស្តុតាងជាក់លាក់អំពីទំនាក់ទំនងយ៉ាងជិតស្និទ្ធរវាងផលិតភាពនិងប្រាក់ឈ្នួលសម្រាប់ប្រទេសជាច្រើននៅក្នុងសកលលោក ។ ជាក់ស្តែង ការសិក្សារបស់អង្គការអន្តរជាតិខាងការងារ (ILO) បានរកឃើញថា ការកើនឡើងផលិតភាព ១% ជំរុញប្រាក់ឈ្នួលឱ្យកើនឡើងចំនួន ០,៧៤% ។

ជាមួយគ្នានេះ ក្របខណ្ឌគោលនយោបាយនេះផ្តល់គុណតម្លៃដល់គ្រប់តួអង្គសេដ្ឋកិច្ច រួមមានរាជរដ្ឋាភិបាល ធុរកិច្ច និងសង្គមជាតិ ដូចខាងក្រោម÷

- **វិបាកសម្រាប់រាជរដ្ឋាភិបាល÷** រាជរដ្ឋាភិបាល នឹងទទួលបានអត្ថប្រយោជន៍ពីក្របខណ្ឌគោលនយោបាយជាតិផលិតភាពសេដ្ឋកិច្ចកម្ពុជា ដូចជាការរក្សាស្ថិរភាពកំណើនសេដ្ឋកិច្ច, ការជំរុញបរិវត្តកម្មសង្គម-សេដ្ឋកិច្ច នៅគ្រប់កម្រិត, ប្រសិទ្ធផលនិងប្រសិទ្ធភាពនៃការផ្តល់សេវាសាធារណៈ, ការលើកតម្កើងគុណតម្លៃស្ថាប័ន, ការទទួលស្គាល់ធម្មានុរូបភាព (legitimacy) និងទំនុកចិត្តកាន់តែខ្ពស់ពីប្រជាជន និងការកើនឡើងនៃចំណូលពន្ធគ្រប់ប្រភេទ ដែលជួយពង្រឹងបន្ថែមដល់សមត្ថភាពរបស់រាជរដ្ឋាភិបាលក្នុងការជំរុញការអភិវឌ្ឍលើគ្រប់វិស័យ សម្រាប់លើកកម្ពស់សុខុមាលភាពសង្គមឱ្យកាន់តែខ្ពស់ថែមទៀត ។ ជាលទ្ធផល ប្រសិទ្ធផលនិងស័ក្តិសិទ្ធភាពដែលសម្រេចបានពីក្របខណ្ឌគោលនយោបាយនេះ ជួយបង្កើនចំណូលជាតិសម្រាប់ជំរុញការអភិវឌ្ឍ, ទាក់ទាញការវិនិយោគក្នុងវិស័យដែលមានតម្លៃបន្ថែមខ្ពស់, បង្កើនភាពប្រកួតប្រជែងរបស់កម្ពុជា និងបង្កើតបរិយាបន្នកម្មសង្គម-សេដ្ឋកិច្ចជាតិទាំងមូល ។

- **វិបាកសម្រាប់ធុរកិច្ច÷** ធុរកិច្ច នឹងទទួលបានអត្ថប្រយោជន៍ពីក្របខណ្ឌគោលនយោបាយជាតិផលិតភាពសេដ្ឋកិច្ចកម្ពុជា ដូចជា ការលើកកម្ពស់ការអភិវឌ្ឍធុរកិច្ច, ការចែករំលែកព័ត៌មាន ទិន្នន័យ ធនធាន ចំណេះដឹង បទពិសោធ និងយុទ្ធសាស្ត្រ ដើម្បីពង្រឹងភាពជាដៃគូនៃការអភិវឌ្ឍជាតិ, ការទទួលបាននូវកម្មវិធីនិងការគាំទ្រផ្នែកបច្ចេកទេស ដើម្បីបង្កើនសមត្ថភាពនិងស័ក្តិសិទ្ធភាពនៃដំណើរការលើប្រតិបត្តិការរបស់សហគ្រាស រួមទាំងសហគ្រាសធុនតូចនិងមធ្យម, ការបង្កើនការប្រកួតប្រជែងស្មើភាព, ការលើកកម្ពស់អភិបាលកិច្ចនិងស្ថាប័នល្អ និងការពង្រឹងបទប្បញ្ញត្តិគាំទ្រទីផ្សារសម្រាប់ជំរុញកំណើនធុរកិច្ច ប្រកបដោយចីរភាពនិងភាពធន់ ។

- **វិបាកសម្រាប់សង្គមជាតិ÷** ក្របខណ្ឌគោលនយោបាយជាតិផលិតភាពសេដ្ឋកិច្ចកម្ពុជា កំណត់ទិសដៅក្នុងការជំរុញផលិតភាព ដើម្បីបង្កើនសន្តិសុខសេដ្ឋកិច្ចនិងលើកកម្ពស់សុខុមាលភាពសង្គម ។ ក្នុងក្របខណ្ឌបង្កើនសន្តិសុខសេដ្ឋកិច្ច, ផលិតភាពសេដ្ឋកិច្ច នឹងបង្កើនឱកាសការងារដែលមានតម្លៃបន្ថែមខ្ពស់, បង្កើនប្រាក់ចំណូល, បង្កើតការងារបន្ថែម, បង្កើនប្រាក់សន្សំសម្រាប់វិនិយោគ និងលើកកម្ពស់ប្រសិទ្ធភាពក្នុងការបែងចែកភាគលាភសេដ្ឋកិច្ច ប្រកបដោយសមធម៌និងបរិយាបន្ន ។ ក្នុងក្របខណ្ឌលើកកម្ពស់សុខុមាលភាពសង្គម, ប្រជាជននឹងទទួលបានផលិតផលដែលមានគុណភាពខ្ពស់, ស្តង់ដារជីវភាពនិងគុណភាពជីវិតល្អប្រសើរ, សេវាសាធារណៈប្រកបដោយគុណភាព ស័ក្តិសិទ្ធភាព តម្លាភាព និងគណនេយ្យភាព, បរិយាបន្នកម្មសេដ្ឋកិច្ច និងគុណភាពអប់រំល្អប្រសើរ សម្រាប់ជំរុញការអនុវត្តអភិក្រម "**ទទួលយក បន្សាំ និង នវានុវត្ត**" ដើម្បីរួមចំណែកដល់បរិវត្តកម្មឌីជីថល សំដៅសម្រេចបានម៉ូដែលកំណើនថ្មី ដែលបានដាក់ចេញនៅក្នុងក្របខណ្ឌគោលនយោបាយសេដ្ឋកិច្ច និង សង្គមឌីជីថលកម្ពុជា ២០២១-២០៣៥ ។

## ២. ស្ថានភាព និង ការត្រៀមខ្លួនក្នុងការកសាង និង ការជំរុញផលិតភាពសេដ្ឋកិច្ចកម្ពុជា

សេដ្ឋកិច្ចកម្ពុជា បាននិងកំពុងវិវឌ្ឍនៅលើគន្លងកំណើនដែលមានលំនឹងនិងស្ថិរភាព ដែលជាថ្នាលមូលដ្ឋានសម្រាប់បន្តជំរុញការអភិវឌ្ឍប្រទេសជាតិ ឆ្ពោះទៅសម្រេចបានសេដ្ឋកិច្ចផ្អែកលើជំនាញដែលមានតម្លៃបន្ថែមខ្ពស់ ។ ការណ៍នេះសម្រេចបានតាមរយៈកិច្ចខិតខំប្រឹងប្រែងជាប្រចាំរបស់រាជរដ្ឋាភិបាលកម្ពុជា ដែលបានដាក់ចេញយុទ្ធសាស្ត្រគោលនយោបាយគន្លឹះជាច្រើន ដើម្បីបង្កើតការងារនិងធុរកិច្ចសម្រាប់លើកកម្ពស់កម្រិតជីវភាពប្រជាជន កៀរគរចំណូលជាតិ ជំរុញផលិតភាព និងបង្កើនភាពប្រកួតប្រជែងសេដ្ឋកិច្ច ។ ជាមួយគ្នានេះ ភាពអំណោយផលនៃគោលនយោបាយម៉ាក្រូសេដ្ឋកិច្ច គឺជាមូលដ្ឋានគ្រឹះជួយបង្កើនទំនុកចិត្ត សមត្ថភាព និងលទ្ធភាពក្នុងការពង្រីកវិសាលភាពនិងសក្តានុពលសេដ្ឋកិច្ច សម្រាប់ជាគុណប្រយោជន៍ដល់សង្គមជាតិទាំងមូល ។ ដូចនេះ ប្រទេសកម្ពុជាសម្រេចបាន

សុខសន្តិភាពពេញលេញនៅទូទាំងប្រទេស, កំណើនសេដ្ឋកិច្ចខ្ពស់ និងការអភិវឌ្ឍលើគ្រប់វិស័យគួរឱ្យកត់សម្គាល់ ។ បន្ថែមពីនេះ កម្ពុជា ត្រូវបន្តគិតគូរនិងយកចិត្តទុកដាក់បន្ថែមលើវិស័យសង្គម-សេដ្ឋកិច្ច ដូចជា វិស័យអប់រំ វិស័យសុខាភិបាល ស្ថាប័ន ការគាំពារសង្គម និងបរិយាបន្នកម្មសេដ្ឋកិច្ច ដើម្បីធានាបានតុល្យភាពរវាងវិស័យសេដ្ឋកិច្ចនិងវិស័យសង្គម ។

ទន្ទឹមនឹងការទទួលបានភាពជោគជ័យលើការជំរុញកំណើននិងការអភិវឌ្ឍសេដ្ឋកិច្ច, កម្ពុជា នៅតែរងសម្ពាធពីការបំពេញតម្រូវការរបស់សង្គម ដោយសារការកើនឡើងនៃតម្រូវការរបស់ប្រជាជន ដែលជំរុញដោយកំណើនសេដ្ឋកិច្ចខ្ពស់និងការកើនឡើងប្រាក់ចំណូល នាំឱ្យប្រជាជនផ្លាស់ប្តូររបៀបរស់នៅឥរិយាបថក្នុងការរស់នៅ និងការលេចឡើងនូវតម្រូវការថ្មីៗ, ការរំពឹងទុកកាន់តែខ្ពស់ក្នុងការផ្តល់ទំនិញនិងសេវាកម្មឱ្យបានទាន់ពេលប្រកបដោយគុណភាព សុវត្ថិភាព ថ្លៃសមរម្យ ទំនុកចិត្តខ្ពស់ គណនេយ្យភាពនិងស័ក្តិសិទ្ធភាព ។ ក្រៅពីនេះ មូលដ្ឋានសេដ្ឋកិច្ចមួយភាគធំរបស់កម្ពុជា ពឹងផ្អែកជាចម្បងលើអតិពលកម្ម នាំឱ្យកម្ពុជាមិនទាន់អាចទាញយកសក្តានុពលពេញលេញពីសកម្មភាពសេដ្ឋកិច្ច ដែលមានតម្លៃបន្ថែមខ្ពស់នៅឡើយ ដោយសារបញ្ហាប្រឈមនៃកត្តាជំរុញផលិតភាពគន្លឹះ ដូចជា គុណភាពនៃការអប់រំ និងការបណ្តុះបណ្តាលបច្ចេកទេសវិជ្ជាជីវៈ, ហេដ្ឋារចនាសម្ព័ន្ធគាំទ្រសកម្មភាពសេដ្ឋកិច្ច, ស្ថាប័នសាធារណៈ និងបច្ចេកវិទ្យានិងនវានុវត្តន៍ មិនទាន់ឆ្លើយតបទាំងស្រុងទៅនឹងតម្រូវការនៃការអភិវឌ្ឍសេដ្ឋកិច្ចក្នុងពេលបច្ចុប្បន្ននិងអនាគត ។

## ២.១. ស្ថានភាពនៃផលិតភាពសេដ្ឋកិច្ចកម្ពុជា

ដោយមានភាគលាភសន្តិភាព ស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច និងប្រជាសាស្ត្រ, កម្ពុជា សម្រេចបានកំណើនសេដ្ឋកិច្ចខ្ពស់ជាមធ្យម ៧% ក្នុងមួយឆ្នាំ ក្នុងអំឡុងឆ្នាំ១៩៩៥ ដល់ ២០១៩ ។ ប៉ុន្តែ កំណើនដ៏ខ្ពស់នេះ បានធ្លាក់ចុះយ៉ាងខ្លាំងរហូតដល់ -៣,១០% នៅឆ្នាំ២០២០ មុនពេលកើនឡើងវិញប្រមាណ ៣% នៅឆ្នាំ២០២១ ដោយសារកំណើនផលិតភាព ការធ្វើពិពិធកម្មការនាំចេញ និងការកើនឡើងការវិនិយោគក្នុងស្រុក ។ យោងតាមអង្គការផលិតភាពអាស៊ី និងផែនការមេផលិតភាពជាតិកម្ពុជា ២០២០-២០៣០, ចាប់ពីឆ្នាំ១៩៩៥ ដល់ ២០១៦ ផលិតភាពសេដ្ឋកិច្ចកម្ពុជាមានអត្រាកើនឡើង ៤,៧១% ក្នុងមួយឆ្នាំ ដែលជាអត្រាខ្ពស់ជាងអត្រាកំណើនផលិតភាពជាមធ្យមដែលមានចំនួន ៣,៤៣% នៃសមាជិករបស់អង្គការផលិតភាពអាស៊ីទាំង២០ប្រទេស ។ បើប្រៀបធៀបជាមួយប្រទេស ដែលមានចំណូលមធ្យមកម្រិតទាបផ្សេងទៀត, ផលិតភាពសេដ្ឋកិច្ចកម្ពុជា មានសភាពយឺតយ៉ាវក្នុងដំណាក់កាលដំបូង ប៉ុន្តែអត្រានេះ បានកើនឡើងដល់ប្រមាណ ៥% ក្នុងអំឡុងឆ្នាំ២០១០-២០១៥ ។ ដោយសារកំណើនរឹងមាំនេះ ផលិតភាពសេដ្ឋកិច្ចកម្ពុជាកើនឡើងចំនួន ២ដង ក្នុងអំឡុងឆ្នាំ២០០០-២០១៩ ចាប់ពី ៣៦៥០ ដុល្លារ

អាម៉េរិក សម្រាប់មនុស្សម្នាក់ នៅឆ្នាំ២០០០ ដល់ ៧២៩០ ដុល្លារអាម៉េរិកសម្រាប់មនុស្សម្នាក់ នៅឆ្នាំ ២០១៩ ។

ទោះជាយ៉ាងណាក៏ដោយ កម្ពុជា ជាប្រទេសមានផលិតភាពទាបក្នុងចំណោមបណ្តាប្រទេសជាសមាជិកអាស៊ាន ដែលផលិតភាពសេដ្ឋកិច្ចកម្ពុជាមានតែប្រមាណ ២៩% នៃកម្រិតផលិតភាពនៃប្រទេសជាសមាជិកអាស៊ាន នៅឆ្នាំ២០១៩ ។ អង្គការផលិតភាពអាស៊ី គូសបញ្ជាក់ថាកត្តាជំរុញផលិតភាពរបស់កម្ពុជា គឺការកើនឡើងនៃចំណែកចូលរួមពីការប្រើប្រាស់មូលធនកាន់តែខ្ពស់ដល់ផលិតភាពពលកម្ម ។ ការកើនឡើងនៃការប្រើប្រាស់មូលធនភាគច្រើន បានមកពីការវិនិយោគមិនមែនក្នុងវិស័យបច្ចេកវិទ្យា ។ ជាមួយគ្នានេះ ផលិតភាពនៃពហុកត្តាផលិតកម្មមានចលនាឡើងចុះគួរឱ្យកត់សម្គាល់ ។ ផ្អែកលើផែនការមេផលិតភាពជាតិរបស់កម្ពុជា ២០២០-២០៣០, ផលិតភាពសេដ្ឋកិច្ចតាមវិស័យ គឺនាំមុខដោយវិស័យឧស្សាហកម្មពីឆ្នាំ១៩៩៥ រហូតដល់ ឆ្នាំ២០០៨ ។ ក្នុងអំឡុងឆ្នាំនេះ ផលិតភាពកសិកម្មមានកម្រិតទាបជាងគេបំផុត ខណៈដែលផលិតភាពឧស្សាហកម្មនិងសេវាកម្មមានការកើនឡើង ។ យ៉ាងណាក៏ដោយ ចាប់ពីឆ្នាំ២០០៨មក វិបត្តិសេដ្ឋកិច្ចពិភពលោកមានឥទ្ធិពលអវិជ្ជមានមកលើវិស័យឧស្សាហកម្មនិងវិស័យសេវាកម្ម ខណៈដែលផលិតភាពវិស័យកសិកម្មមានការកើនឡើង ។ ជាងនេះទៀត ចាប់ពីឆ្នាំ២០១២មក កម្រិតផលិតភាពវិស័យកសិកម្មស្ថិតនៅខ្ពស់ជាងវិស័យសេវាកម្ម ។

ផ្អែកតាមវេទិកាសេដ្ឋកិច្ចពិភពលោកឆ្នាំ២០១៨-២០១៩, ភាពប្រកួតប្រជែងរួមជាសកលរបស់កម្ពុជាបានកើនឡើងប្រមាណ ២ ពិន្ទុ ពី ៥០,២០ ក្នុងឆ្នាំ២០១៨ ដល់ ៥២,១០ ក្នុងឆ្នាំ២០១៩ ដោយទទួលបានចំណាត់ថ្នាក់ទី១១០ ក្នុងចំណោម ១៤០ប្រទេស ក្នុងឆ្នាំ២០១៨ និង ចំណាត់ថ្នាក់ទី១០៦ ក្នុងចំណោម ១៤១ប្រទេស ក្នុងឆ្នាំ២០១៩ ។ ភាពប្រសើរឡើងនេះ ត្រូវបានជំរុញដោយការកើនឡើងនៃបសិដ្ឋកម្មរបស់សសរស្តម្ភនៃភាពប្រកួតប្រជែងមួយចំនួន ដូចជា ហេដ្ឋារចនាសម្ព័ន្ធ ស្ថាប័ន ជំនាញ ទីផ្សារការងារ និងថាមវភាពធុរកិច្ច ។

## ២.២. ការត្រៀមខ្លួនក្នុងការកសាង និង ជំរុញផលិតភាពសេដ្ឋកិច្ច

កម្ពុជា មានកាលានុវត្តភាពខ្ពស់ក្នុងការជំរុញកំណើននិងការអភិវឌ្ឍសេដ្ឋកិច្ចជាតិ ដោយសារកត្តាអំណោយផលជាច្រើន ទាំងផ្នែកនយោបាយនិងផ្នែកប្រជាសាស្ត្រ ។ ចាប់តាំងពីចុងឆ្នាំ២០០៨មក, កម្ពុជា ទទួលបានសុខសន្តិភាពពេលលេញ ដែលជាមូលដ្ឋានគ្រឹះមិនអាចខ្វះបានសម្រាប់ការអភិវឌ្ឍជាតិ និងលើកកម្ពស់វិបុលភាពសង្គម ដែលឆ្លុះបញ្ចាំងតាមរយៈកំណើនសេដ្ឋកិច្ចខ្ពស់ក្នុងរយៈពេលជាង២ ទសវត្សរ៍កន្លងមកនេះ ។ ជាមួយគ្នានេះ កម្ពុជា គឺជាប្រទេសមានភាគលាភប្រជាសាស្ត្រខ្ពស់ ដោយមាន

ប្រជាជនវ័យក្មេងច្រើន ដែលមានគំនិតច្នៃប្រតិដ្ឋនិងមានសមត្ថភាពសម្រាប់ចាប់យកបច្ចេកវិទ្យាថ្មីៗ បន្សាំបច្ចេកវិទ្យា និងនវានុវត្ត ដើម្បីជំរុញផលិតភាពសេដ្ឋកិច្ច ប្រកបដោយចីរភាពនិងភាពធន់ ។ យោងតាម ក្របខណ្ឌគោលនយោបាយសេដ្ឋកិច្ច និង សង្គមឌីជីថលកម្ពុជា ២០២១-២០៣៥, គិតត្រឹមឆ្នាំ២០១៩ កម្ពុជា មានប្រជាជនវ័យក្មេងដែលមានអាយុ ១៥-៣៥ឆ្នាំ ចំនួនប្រមាណ ៥,៦៩ លាននាក់ ស្មើនឹងប្រមាណ ៣៦,៦០% នៃប្រជាជនសរុប និងប្រមាណ ៥៦% នៃប្រជាជនគ្រប់អាយុបំពេញការងារក្នុងសកម្មភាព សេដ្ឋកិច្ចដែលមានអាយុ ១៥-៦៤ ឆ្នាំ ។

ជាមួយនឹងបញ្ហាប្រឈមមួយចំនួនដែលត្រូវដោះស្រាយ, ការត្រៀមខ្លួន គឺមានសារៈសំខាន់ និងចាំបាច់ក្នុងការរៀបចំនិងដាក់ចេញគោលនយោបាយ ដើម្បីលើកកម្ពស់ផលិតភាពសេដ្ឋកិច្ចកម្ពុជា ប្រកបដោយចីរភាព ភាពធន់ បរិយាបន្ន និងជោគជ័យខ្ពស់ ។ ផ្អែកលើទ្រឹស្តីនិងការសិក្សាស្រាវជ្រាវ តាមបណ្តាប្រទេសជាច្រើន, កត្តាជំរុញផលិតភាពសេដ្ឋកិច្ចមានច្រើន ដូចបានរៀបរាប់ដោយសង្ខេប ខាងលើ រួមមាន កត្តាពាក់ព័ន្ធនឹងបច្ចេកទេសនិងនវានុវត្តន៍បច្ចេកវិទ្យា, មូលធនមនុស្ស, ការគ្រប់គ្រងនិង ប្រព័ន្ធលើកទឹកចិត្ត, កត្តាសេដ្ឋកិច្ច, ស្ថាប័ននិងអភិបាលកិច្ចល្អ និងកត្តាសុខភាព ។ ដោយសារភាពខុសៗគ្នា នៃស្ថានភាពសេដ្ឋកិច្ច សង្គម ស្ថាប័ន និងនយោបាយ, ការសិក្សាស្រាវជ្រាវនិងការអនុវត្តជាក់ស្តែង បង្ហាញថា កត្តាជំរុញផលិតភាពសេដ្ឋកិច្ចនៃប្រទេសនីមួយៗមានភាពខុសគ្នា ។ ផ្អែកលើឧត្តមានុវត្តន៍ និងបទពិសោធរបស់ប្រទេសមួយចំនួន ព្រមទាំងយោងតាមបរិការណ៍ជាក់ស្តែងរបស់កម្ពុជា, ការជំរុញ ផលិតភាពសេដ្ឋកិច្ចផ្តោតចម្បងលើការកែលម្អកត្តាកំណត់ផលិតភាពធំៗចំនួន ៤ រួមមាន÷ **(១). ការអប់រំ និង ការបណ្តុះបណ្តាលបច្ចេកទេសវិជ្ជាជីវៈ, (២). បច្ចេកវិទ្យា និង នវានុវត្តន៍, (៣). ស្ថាប័នសាធារណៈ** និង **(៤).ហេដ្ឋារចនាសម្ព័ន្ធ** ។ កត្តាកំណត់ផលិតភាពនីមួយៗ តម្រូវឱ្យមានអន្តរកម្មនិងបំពេញគ្នាទៅ វិញទៅមក ដើម្បីលើកកម្ពស់ផលិតភាពសេដ្ឋកិច្ចកម្ពុជា ជាប្រព័ន្ធនិងមានភាពប្រទាក់ក្រឡា ។

### ២.២.១. ការអប់រំ និង ការបណ្តុះបណ្តាលបច្ចេកទេសវិជ្ជាជីវៈ

ការអប់រំ និង ការបណ្តុះបណ្តាលបច្ចេកទេសវិជ្ជាជីវៈដែលមានគុណភាពខ្ពស់ គឺជាកូនសោគន្លឹះ សម្រាប់សេដ្ឋកិច្ចរឹងមាំ, ជាឧបករណ៍ដ៏មានប្រសិទ្ធផលនិងស័ក្តិសិទ្ធភាពក្នុងការលើកកម្ពស់ផលិតភាព សេដ្ឋកិច្ច និងជាដំណោះស្រាយដ៏មានប្រសិទ្ធភាពសម្រាប់រាល់បញ្ហាសង្គម ។ ក្នុងការលើកកម្ពស់ផលិត ភាពសេដ្ឋកិច្ច, កម្ពុជាត្រូវការប្រព័ន្ធអប់រំរឹងមាំ និងការអប់រំបណ្តុះបណ្តាលដែលមានទាំងគុណភាព និង បរិមាណ ដើម្បីអភិវឌ្ឍមូលធនមនុស្ស ប្រកបដោយចំណេះដឹង ជំនាញវិជ្ជាជីវៈ និងឯកទេសកម្មខ្ពស់ ។ នាបច្ចុប្បន្ន ការអប់រំ និង ការបណ្តុះបណ្តាលបច្ចេកទេសវិជ្ជាជីវៈនៅកម្ពុជា កំពុងត្រូវបានកែទម្រង់ជា បន្តបន្ទាប់ និង មាននវឌ្ឍនភាពគួរឱ្យកត់សម្គាល់ តាមរយៈការដាក់ចេញគោលនយោបាយអប់រំ និងផែនការ

យុទ្ធសាស្ត្រជាច្រើន ។ ប៉ុន្តែ គុណភាពនិងការអភិវឌ្ឍវិស័យនេះនៅមានកម្រិត ដើម្បីបំពេញតម្រូវការនៃការអភិវឌ្ឍនិងជំរុញផលិតភាពសេដ្ឋកិច្ចជាតិ ប្រកបដោយប្រសិទ្ធផល ស័ក្តិសិទ្ធភាព និងភាពប្រកួតប្រជែងខ្ពស់ ។ បើប្រៀបធៀបជាមួយប្រទេសក្នុងតំបន់, ការចូលរៀនរបស់សិស្សមានកំណើនខ្ពស់, អត្រាអក្ខរកម្មរបស់ប្រជាជនកម្ពុជាចាប់ពីអាយុ ១៥ឆ្នាំឡើងទៅមានចំនួនប្រមាណ ៧៩,៩០% នៅឆ្នាំ២០១២ និងកើនឡើងដល់ ៨៧,៧០% នៅឆ្នាំ២០២០ តែលទ្ធផលនៃការអភិវឌ្ឍចំណេះដឹងដែលអាចងាយចាប់យកជំនាញវិជ្ជាជីវៈ ទាំងផ្នែករឹងនិងផ្នែកទន់នៅមានកម្រិត ដែលចាំបាច់ត្រូវកែលម្អឱ្យបានទាន់ពេលសម្រាប់ជំរុញបន្ថែមការអភិវឌ្ឍសង្គម-សេដ្ឋកិច្ច ។

ដោយសារមូលធនមនុស្សមានសារៈសំខាន់សម្រាប់រាល់ការអភិវឌ្ឍ, រាជរដ្ឋាភិបាលកម្ពុជាផ្តល់អាទិភាពលើមនុស្ស ជាមុខព្រួញចម្បងទីមួយ ដើម្បីទ្រទ្រង់កំណើន ការងារ សមធម៌ និងប្រសិទ្ធភាពដែលបានរំលេចនៅក្នុងយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៣និងទី៤ ។ ជាក់ស្តែង រាជរដ្ឋាភិបាលបានបង្កើនការវិនិយោគជាបន្តបន្ទាប់ ដែលមានទំហំទឹកប្រាក់ប្រមាណ ១,២០% នៃ ផ.ស.ស. នៅឆ្នាំ១៩៩៨ និងកើនដល់ ២,២០% នៃ ផ.ស.ស. នៅឆ្នាំ២០១៨ ដើម្បីកែទម្រង់វិស័យអប់រំជាតិ ។ ដើម្បីជំរុញបន្ថែមការលើកកម្ពស់ផលិតភាពសេដ្ឋកិច្ច, រាជរដ្ឋាភិបាល យកចិត្តទុកដាក់ខ្ពស់លើការអភិវឌ្ឍចំណេះដឹងចំណេះធ្វើ និងជំនាញមានតម្លៃបន្ថែមខ្ពស់ ដោយកំណត់ទិសដៅជាក់លាក់ចំនួន ២ ដូចខាងក្រោម÷

- **ការអភិវឌ្ឍមូលធនមនុស្ស÷** មូលធនមនុស្ស គឺជាកត្តាសំខាន់ជំរុញការអភិវឌ្ឍសេដ្ឋកិច្ច និងទាមទារឱ្យមានការលើកកម្ពស់កម្រិតជំនាញវិជ្ជាជីវៈឱ្យបានល្អប្រសើរ ។ វឌ្ឍនភាពនៃការអភិវឌ្ឍមូលធនមនុស្សនៅកម្ពុជា មិនទាន់ធានាបាននូវតុល្យភាពរវាងការចូលរៀននិងការបញ្ចប់ថ្នាក់សិក្សា ដែលនាំឱ្យការកសាងមូលធនមនុស្ស នៅមិនទាន់សម្រេចបានប្រសិទ្ធភាពខ្ពស់ ។ អត្រាចូលរៀននិងអត្រាបញ្ចប់ការសិក្សាពីគ្រប់កម្រិតសិក្សា ចាប់ពីឆ្នាំ២០១២ ដល់ ឆ្នាំ២០២០ មាននិន្នាការថយចុះ ដែលបង្អាក់និងរាំងស្ទះដល់ដំណើរការលើកកម្ពស់និងការធ្វើបរិវត្តកម្មលើវិស័យអប់រំ ប្រកបដោយនិរន្តរភាព ។ ការសិក្សាយ៉ាងតិចត្រឹមកម្រិតមធ្យមសិក្សាទុតិយភូមិ គឺជាកត្តាចាំបាច់សម្រាប់ការកសាងគុណភាពមូលធនមនុស្ស, ការចាប់យកចំណេះដឹងនិងជំនាញវិជ្ជាជីវៈមានតម្លៃខ្ពស់នាពេលអនាគត និងការកសាងជំនាញសម្រាប់ទីផ្សារពលកម្ម ។ ការអភិវឌ្ឍមូលធនមនុស្ស នឹងលើកកម្ពស់សមត្ថភាពរបស់កម្ពុជាក្នុងការបង្កើនសក្តានុពលសេដ្ឋកិច្ចពេញលេញនិងភាពប្រកួតប្រជែងសេដ្ឋកិច្ចខ្ពស់ ។

- **ការអភិវឌ្ឍផលិតភាពពលកម្ម÷** កម្លាំងពលកម្មដែលមានជំនាញខ្ពស់ គឺជាសមាសធាតុសំខាន់ក្នុងដំណើរការផលិតទំនិញនិងសេវាកម្ម ព្រមទាំងចូលរួមចំណែកជាចម្បងក្នុងការលើកកម្ពស់ផលិតភាពសេដ្ឋកិច្ចនិងភាពប្រកួតប្រជែងនៅគ្រប់វិស័យ ។ កម្លាំងពលកម្មប្រកបដោយផលិតភាព ចាំបាច់ត្រូវមាន

សមត្ថភាព ភាពប៉ិនប្រសប់ និងឯកទេសកម្មខ្ពស់ ដើម្បីធ្វើបរិវត្តកម្មសេដ្ឋកិច្ច ឆ្ពោះទៅការផលិតទំនិញ និងសេវាកម្ម ដែលមានគុណភាពនិងតម្លៃបន្ថែមខ្ពស់ ។ ដើម្បីសម្រេចគោលដៅនេះ, ការលើកកម្ពស់ផលិតភាពពលកម្មនៅកម្ពុជា ត្រូវមានលក្ខណៈប្រទាក់ក្រឡានិងជាប្រព័ន្ធ ។ ទោះបីជាកម្លាំងពលកម្មវ័យក្មេងភាគច្រើនកំពុងតែបំពេញការងារក្តី, កម្លាំងពលកម្មទាំងនេះភាគច្រើនមានកម្រិតជំនាញទាប និងបម្រើការងារនៅក្នុងវិស័យដែលមានតម្លៃបន្ថែមទាប ។ ជាក់ស្តែង កម្លាំងពលកម្មកម្ពុជាចំនួន ១២% គ្មាន ឬ មានការអប់រំតិចតួច, ៣២% មិនបានបញ្ចប់បឋមសិក្សា, ២៧% បានបញ្ចប់បឋមសិក្សា, ១៥% បានបញ្ចប់មធ្យមសិក្សាបឋមភូមិ, ៧% បញ្ចប់មធ្យមសិក្សាទុតិយភូមិ និង ៧% ក្រោយមធ្យមសិក្សា ។

### ២.២.២. បច្ចេកវិទ្យា និង នវានុវត្តន៍

នវានុវត្តន៍ គឺជាកត្តាយ៉ាងសំខាន់ក្នុងការជំរុញផលិតភាពសេដ្ឋកិច្ច តាមរយៈការអភិវឌ្ឍនិងការប្រើប្រាស់គំនិត ចំណេះដឹង និងបច្ចេកវិទ្យា ដើម្បីផលិតទំនិញនិងសេវាកម្មថ្មី ប្រកបដោយប្រសិទ្ធផលខ្ពស់ ក៏ដូចជាលើកកម្ពស់គុណភាពផលិតផលទាំងនេះ ។ ចំពោះស្ថាប័នធុរកិច្ច, នវានុវត្តន៍ មានឥទ្ធិពលលើផលិតភាពសេដ្ឋកិច្ចតាមរយៈមធ្យោបាយ ២យ៉ាង គឺ÷ (១). នវានុវត្តន៍ បង្កើតផលិតផលថ្មី ដែលបង្កើនតម្រូវការសម្រាប់ផលិតផលទាំងនេះ, និង (២). នវានុវត្តន៍ បង្កើនប្រសិទ្ធផលសម្រាប់ផលិតកម្មនិងកាត់បន្ថយថ្លៃដើមនៃផលិតកម្ម ។ ជារួម នវានុវត្តន៍ បង្កើតតម្លៃបន្ថែមសេដ្ឋកិច្ចខ្ពស់ បង្កើនភាពប្រកួតប្រជែង និងស័ក្តិសិទ្ធភាពសេដ្ឋកិច្ច សំដៅធានាបានចីរភាពកំណើនរយៈពេលវែង ផ្អែកលើអភិក្រម **"ទទួលយកបច្ចេកវិទ្យា បន្សាំបច្ចេកវិទ្យា និង នវានុវត្ត"** ។ ផ្អែកលើក្របខណ្ឌគោលនយោបាយសេដ្ឋកិច្ច និង សង្គមឌីជីថល, កម្ពុជា មានសក្តានុពល និងអំណោយផលពីភាគលាភប្រជាសាស្ត្រខ្ពស់ ដែលងាយចាប់យកបច្ចេកវិទ្យាថ្មីៗ, ធ្វើនវានុវត្តន៍ និងជំរុញល្បឿនបរិវត្តកម្មឌីជីថល ដើម្បីប្រែក្លាយសេដ្ឋកិច្ចប្រពៃណីដែលផ្អែកលើអតិពលកម្មទៅជាសេដ្ឋកិច្ចឌីជីថលនិងសេដ្ឋកិច្ចថ្មីៗដទៃទៀត ។

ទោះជាយ៉ាងនេះក្តី នវានុវត្តន៍របស់កម្ពុជានៅមានកម្រិត ដោយសារកង្វះខាតមូលធនមនុស្ស, ការវិនិយោគទាបលើការស្រាវជ្រាវនិងការអភិវឌ្ឍ និងសមត្ថភាពរបស់សហគ្រាសធុនតូចនិងមធ្យមនៅមានកម្រិត ។ យោងតាមអង្គការកម្មសិទ្ធិបញ្ញាពិភពលោក (WIPO), នវានុវត្តន៍កម្ពុជា ទទួលបានចំណាត់ថ្នាក់លេខ ៩៨ ក្នុងចំណោម ១៣១ប្រទេស នៅឆ្នាំ២០១៩ ហើយបានធ្លាក់ចុះដល់ចំណាត់ថ្នាក់លេខ ១០៩ នៅឆ្នាំ២០២១ ។ ហេតុនេះ កម្ពុជាត្រូវជំរុញ កសាង និងពង្រឹងមូលដ្ឋានគ្រឹះសម្រាប់នវានុវត្តន៍ ដើម្បីទ្រទ្រង់និងលើកកម្ពស់ផលិតភាពសេដ្ឋកិច្ចសម្រាប់រយៈពេលវែង ប្រកបដោយនិរន្តរភាព ។ ក្នុងន័យនេះ កម្ពុជា ត្រូវលើកកម្ពស់គុណភាពនៃការអប់រំ និង ការបណ្តុះបណ្តាលចំណេះដឹងបែបវិទ្យាសាស្ត្រ ចំណេះដឹងពហុវិស័យ និងឯកទេសកម្ម ដើម្បីសម្រេចបានប្រសិទ្ធផលសេដ្ឋកិច្ចនិងតម្លៃបន្ថែមខ្ពស់ ។ រាជរដ្ឋាភិបាល

និងវិស័យឯកជន ត្រូវចូលរួមសហការដោះស្រាយបញ្ហាប្រឈមនានា និងបង្កើនសមត្ថភាពសម្រាប់ការធ្វើនវានុវត្តន៍ ដោយកំណត់អាទិភាពលើការអភិវឌ្ឍជំនាញបច្ចេកវិទ្យា, ការគាំទ្រនិងលើកទឹកចិត្តដល់សហគ្រាសលើបច្ចេកវិទ្យានិងនវានុវត្តន៍ និងការពង្រឹងប្រសិទ្ធភាពនៃកិច្ចសហប្រតិបត្តិការរវាងស្ថាប័នគាំទ្របច្ចេកវិទ្យានិងនវានុវត្តន៍ ។

### ២.២.៣. ស្ថាប័នសាធារណៈ

ស្ថាប័នសាធារណៈ គឺជាហេដ្ឋារចនាសម្ព័ន្ធទន់ ដែលដើរតួនាទីសំខាន់ក្នុងការសម្របសម្រួល គាំទ្រ និងពង្រឹងវឌ្ឍនភាពនៃការអនុវត្តផលិតភាពសេដ្ឋកិច្ច ដោយសារគុណភាពស្ថាប័នសាធារណៈល្អ នឹងកំណត់វិធាននៃច្បាប់និងបទប្បញ្ញត្តិនានាបានច្បាស់លាស់ សម្រាប់បង្កើតបរិស្ថានជំរុញការវិនិយោគ ធុរកិច្ច និងសកម្មភាពសេដ្ឋកិច្ច ប្រកបដោយប្រសិទ្ធផលនិងស័ក្តិសិទ្ធភាព ដើម្បីធានានូវភាពប្រកួតប្រជែងស្មើភាព និងលើកកម្ពស់ផលិតភាពសេដ្ឋកិច្ច ។ ហេតុនេះ រាជរដ្ឋាភិបាលកម្ពុជា បានដាក់ចេញនូវគោលនយោបាយ យុទ្ធសាស្ត្រ ផែនការសកម្មភាព និងកម្មវិធីកែទម្រង់ជាបន្តបន្ទាប់ ដើម្បីបង្កើនល្បឿនការលើកកម្ពស់សមត្ថភាពប្រព័ន្ធរដ្ឋបាលសាធារណៈ សំដៅធ្វើទំនើបកម្មអភិបាលកិច្ចល្អ ពង្រឹងគុណភាពបទប្បញ្ញត្តិ កែលម្អបរិយាកាសធុរកិច្ច បង្កើនប្រសិទ្ធភាពរដ្ឋាភិបាល លើកកម្ពស់ភាពប្រកួតប្រជែង និងអភិវឌ្ឍមូលធនមនុស្ស ក្នុងការឆ្លើយតបទៅនឹងតម្រូវការនៃការអភិវឌ្ឍសេដ្ឋកិច្ចនិងសង្គម ។ ដើម្បីលើកកម្ពស់គុណភាពនៃស្ថាប័នសាធារណៈសម្រាប់ជំរុញផលិតភាពសេដ្ឋកិច្ច, រាជរដ្ឋាភិបាល កំណត់ទិសដៅអាទិភាពចម្បងចំនួន ៣ ដូចខាងក្រោម÷

**- ការជំរុញអភិបាលកិច្ចល្អ÷** អភិបាលកិច្ចល្អរួមចំណែកក្នុងការបង្កើតបរិស្ថានដែលមានស្ថិរភាពនិងជឿទុកចិត្តសម្រាប់ធុរកិច្ចនិងការវិនិយោគ ដោយហេតុថាអភិបាលកិច្ចល្អត្រូវបានចាត់ទុកថាជាកត្តាចម្បងក្នុងការកាត់បន្ថយភាពមិនច្បាស់លាស់និងលើកកម្ពស់ប្រសិទ្ធផលសេដ្ឋកិច្ច ។ ការណ៍នេះ នឹងមានផលវិជ្ជមានដល់ការជំរុញសកម្មភាពសេដ្ឋកិច្ចក្នុងរយៈពេលវែង, បង្កើនតម្លៃបន្ថែមខ្ពស់, ជំរុញផលិតភាពសេដ្ឋកិច្ចនិងបង្កើនភាពប្រកួតប្រជែង ។ ក្នុងការជំរុញល្បឿនផលិតភាពសេដ្ឋកិច្ច, រាជរដ្ឋាភិបាលកម្ពុជាបានកំណត់យកអភិបាលកិច្ចល្អជាកិច្ចការស្នូល ដើម្បីពន្លឿនការកែទម្រង់ស្ថាប័នឱ្យកាន់តែស៊ីជម្រៅនិងមានវិសាលភាពគ្រប់ជ្រុងជ្រោយ សម្រាប់ជាមគ្គុទ្ទេសក៍តម្រង់ទិសការអភិវឌ្ឍសង្គម-សេដ្ឋកិច្ចជាតិលើគ្រប់វិស័យ ។ ជាមួយនឹងវឌ្ឍនភាពគួរឱ្យកត់សម្គាល់ក្នុងការកែទម្រង់, បញ្ហាប្រឈមមួយចំនួននៅតែមាន ជាពិសេសពាក់ព័ន្ធនឹងប្រសិទ្ធភាពការអនុវត្តគោលនយោបាយ, កិច្ចសម្របសម្រួលនិងកិច្ចសហប្រតិបត្តិការអន្តរស្ថាប័ន, ការអនុវត្តបទប្បញ្ញត្តិ និងការបែងចែកនិងដាក់ធនធានចំទិសដៅ ដើម្បីសម្រេចបានផលិតភាពខ្ពស់បំផុត ។ ក្នុងការរួមចំណែកដល់អភិបាលកិច្ចល្អ, កម្ពុជា ត្រូវធ្វើទំនើបកម្មលើមុខងាររដ្ឋបាលសាធារណៈ, បង្កើន

ប្រសិទ្ធភាពការអនុវត្តវិធាននៃច្បាប់និងបទប្បញ្ញត្តិ និង ប្រកាន់ខ្ជាប់នូវវប្បធម៌នៃការគ្រប់គ្រងនិងភាពជាអ្នកដឹកនាំល្អ ដើម្បីធានាបានការផ្តល់សេវាសាធារណៈ ប្រកបដោយតម្លាភាព ស័ក្តិសិទ្ធភាព និង គណនេយ្យភាពសម្រាប់បំពេញតម្រូវការជូនធុរកិច្ច ប្រជាជន និងសង្គមជាតិទាន់ពេល ។

**- ការកែលម្អបទប្បញ្ញត្តិទីផ្សារ÷** អភិបាលកិច្ចទីផ្សារ គឺជាកត្តាជំរុញដ៏សំខាន់មួយទៀតចំពោះសមិទ្ធកម្មនិងផលិតភាពសេដ្ឋកិច្ច តាមរយៈការជះឥទ្ធិពលទៅលើថ្លៃដើមក្នុងការផលិតទំនិញនិងសេវាកម្ម ។ ជាក់ស្តែង ការកែទម្រង់សម្រាប់លើកកម្ពស់ការប្រកួតប្រជែង នឹងបង្កើនផលិតភាពសេដ្ឋកិច្ចតាមរយៈការវិភាជធនធានឱ្យចំទិសដៅ ដើម្បីសម្រេចបានសក្តានុពលផលិតភាពខ្ពស់បំផុត ព្រមទាំងជំរុញឱ្យមានជវភាពនៃប្រសិទ្ធផលក្នុងរយៈពេលវែង ។ ដូចគ្នាដែរ ការកែទម្រង់ទីផ្សារលើកទឹកចិត្តនិងជំរុញឱ្យមានប្រសិទ្ធផល តាមរយៈការធ្វើឱ្យប្រសើរឡើងនូវការប្រើប្រាស់កត្តាផលិតកម្មទាំងអស់ ។ លើសពីនេះទៀត ការកែទម្រង់បទប្បញ្ញត្តិជំរុញល្បឿននៃកំណើនផលិតភាព តាមរយៈការលើកទឹកចិត្តឱ្យធុរកិច្ចធ្វើនវានុវត្តន៍ ដើម្បីឈានដល់ឧត្តមភាពលើផ្នែកបច្ចេកវិទ្យា ព្រមទាំងជំរុញល្បឿននៃការអភិវឌ្ឍផលិតផលថ្មីៗ ។ ផ្អែកលើសារៈសំខាន់នៃផលវិជ្ជមានរបស់អភិបាលកិច្ច, រាជរដ្ឋាភិបាល បានបន្តកែទម្រង់ជាប្រចាំនិងដាក់ចេញគោលនយោបាយគន្លឹះនិងបទប្បញ្ញត្តិនានា ដូចជា ច្បាប់ស្តីពីកិច្ចការពារអ្នកប្រើប្រាស់, ច្បាប់ស្តីពីពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក និងច្បាប់ស្តីពីការប្រកួតប្រជែង ដើម្បីដោះស្រាយបញ្ហាថ្លៃទីផ្សារឱ្យមានប្រសិទ្ធភាពខ្ពស់ កាត់បន្ថយថ្លៃប្រតិបត្តិការ និងបង្កើតបរិយាកាសអំណោយផល សម្រាប់ទាក់ទាញការវិនិយោគនិងជំរុញការធ្វើធុរកិច្ចនៅកម្ពុជា ។ ដើម្បីទាក់ទាញការវិនិយោគផ្ទាល់ពីបរទេសនិងជំរុញការវិនិយោគក្នុងស្រុកបន្ថែម, រាជរដ្ឋាភិបាល បានធ្វើវិសោធនកម្មច្បាប់វិនិយោគជាបន្តបន្ទាប់ ហើយច្បាប់ស្តីពីវិនិយោគថ្មីត្រូវបានអនុម័តនៅខែតុលា ឆ្នាំ២០២១ សំដៅពង្រឹងក្របខណ្ឌគតិយុត្តដែលមានលក្ខណៈបើកចំហ បង្កើនភាពច្បាស់លាស់ និងលើកកម្ពស់តម្លាភាព សម្រាប់ធានាបានភាពទាក់ទាញខ្ពស់របស់កម្ពុជា ជាគោលដៅវិនិយោគក្នុងតំបន់ ។ ច្បាប់ស្តីពីវិនិយោគថ្មីនេះ កំណត់នីតិវិធីច្បាស់លាស់ សាមញ្ញនិងលឿន ព្រមទាំងផ្តល់នូវការធានានិងការលើកទឹកចិត្តជាច្រើនដល់គម្រោងវិនិយោគ ដែលមានបច្ចេកវិទ្យាខ្ពស់ នវានុវត្តន៍ ការស្រាវជ្រាវនិងការអភិវឌ្ឍ និងឧស្សាហកម្មដែលមានតម្លៃបន្ថែមខ្ពស់ ។ ការណ៍នេះនឹងជួយជំរុញសន្ទុះនៃការផ្ទេរបច្ចេកវិទ្យានិងនវានុវត្តន៍នៅកម្ពុជា ដែលជាកត្តាដ៏សំខាន់ក្នុងការបង្កើនផលិតភាពសេដ្ឋកិច្ច ។

**- ការលើកកម្ពស់ស្ថាប័នទីផ្សារការងារ÷** ការកសាងស្ថាប័នទីផ្សារការងារល្អ បង្កើតនូវលក្ខខណ្ឌអំណោយផលដើម្បីឱ្យទីផ្សារការងារដំណើរការប្រកបដោយប្រសិទ្ធផលនិងប្រសិទ្ធភាព ព្រមទាំងមានផលវិជ្ជមានលើផលិតភាពសេដ្ឋកិច្ច តាមរយៈការលើកកម្ពស់ប្រសិទ្ធផលដែលទទួលបានពីការធ្វើវិភាជន៍

ធនធាន និង នវានុវត្តន៍ ដែលជំរុញដោយការកសាងជំនឿទុកចិត្តទៅវិញទៅមករវាងធុរកិច្ច និងនិយោជិត ។ ផ្អែកលើបទពិសោធនិងភស្តុតាងពីការសិក្សាស្រាវជ្រាវ, ឥទ្ធិពលនៃការកសាងស្ថាប័នទីផ្សារការងារជះទៅលើផលិតភាព កើតមានឡើងតាមរយៈយន្តការ ៣ធំៗគឺ (១). បសិដ្ឋកម្មផលិតភាពអាស្រ័យជាចម្បងលើការសហការល្អនៃនិយោជិត និងគំនិតច្នៃប្រតិដ្ឋរបស់និយោជិត ដែលជំរុញដោយការកសាងទំនុកចិត្តក្នុងការទទួលបានការងាររយៈពេលយូរជាមួយនិយោជក និង ការបែងចែកប្រកបដោយសមធម៌នៃផលប្រយោជន៍ដែលទទួលបានពីកំណើនផលិតភាពប្រកបដោយសមធម៌, (២). ការការពារការងារល្អ ផ្តល់នូវការធានាការងារនិងលើកទឹកចិត្តដល់និយោជិតឱ្យវិនិយោគលើការអប់រំ និង បណ្តុះបណ្តាលបន្ថែម ដែលការណ៍នេះមានឥទ្ធិពលវិជ្ជមានលើកំណើនផលិតភាពសេដ្ឋកិច្ច និង (៣). ស្ថាប័នទីផ្សារការងារល្អ កាត់បន្ថយរំហូរផ្លាស់ប្តូរការងារ និងសម្រួលដល់ការវិភាជធនធានទៅក្នុងសកម្មភាពសេដ្ឋកិច្ចដែលមានផលិតភាពខ្ពស់ ។

### ២.២.៤. ហេដ្ឋារចនាសម្ព័ន្ធ

ហេដ្ឋារចនាសម្ព័ន្ធ គឺជាឆ្អឹងខ្នងនិងធាតុចូលដ៏សំខាន់ ដែលរួមចំណែកដល់កំណើននិងការអភិវឌ្ឍសង្គម-សេដ្ឋកិច្ច តាមរយៈធនប្រាប្ត (gain) នៃផលិតភាពសេដ្ឋកិច្ចនិងភាពប្រកួតប្រជែង ដែលជំរុញដោយការកាត់បន្ថយថ្លៃដើមក្នុងដំណើរការផលិតកម្ម ។ ជាងនេះទៀត ហេដ្ឋារចនាសម្ព័ន្ធ ជួយសម្រួលដល់ពាណិជ្ជកម្ម, ទាក់ទាញការវិនិយោគផ្ទាល់ពីបរទេស, ជំរុញរំហូរសកម្មភាពពាណិជ្ជកម្មនិងការបែងចែកការវិនិយោគក្នុងប្រទេសបានល្អ, លើកកម្ពស់សមាហរណកម្មសេដ្ឋកិច្ចផ្ទៃក្នុង និងការពង្រឹងការតភ្ជាប់សេដ្ឋកិច្ចក្នុងស្រុកទៅក្នុងខ្សែច្រវាក់តម្លៃតំបន់និងសកល ។ ជាមួយគ្នានេះ ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធជំរុញល្បឿននៃការធ្វើពិពិធកម្មសេដ្ឋកិច្ចនិងការផ្គត់ផ្គង់ ព្រមទាំងបង្រួមគម្លាតនៃការអភិវឌ្ឍសេដ្ឋកិច្ចផ្ទៃក្នុងប្រទេសផងដែរ ។

មូលធននៃហេដ្ឋារចនាសម្ព័ន្ធ ដូចជា សុខុបត្ថម្ភវត្ថុដឹកជញ្ជូន (transportation facility) ប្រព័ន្ធភស្តុភារកម្ម ប្រព័ន្ធទឹកស្អាត ប្រព័ន្ធថាមពល ប្រព័ន្ធទូរគមនាគមន៍ និងប្រព័ន្ធបច្ចេកវិទ្យាគមនាគមន៍និងព័ត៌មាន (ICT) គឺជាបុរេលក្ខខណ្ឌដ៏សំខាន់សម្រាប់ធានាភាពជោគជ័យនៃការអភិវឌ្ឍលើគ្រប់វិស័យដោយសារហេដ្ឋារចនាសម្ព័ន្ធទាំងនេះ មានឥទ្ធិពលវិជ្ជមានលើគ្រប់សកម្មភាពសេដ្ឋកិច្ច, សមត្ថភាពផលិតកម្មនៅគ្រប់ខ្សែច្រវាក់តម្លៃ និងការប្រើប្រាស់ទំនិញនិងសេវាកម្ម ។ ជាមួយនឹងវិបាកនៅកម្រិតម៉ាក្រូសេដ្ឋកិច្ច, ហេដ្ឋារចនាសម្ព័ន្ធ គឺជាសសរស្តម្ភគាំទ្រដល់ពិពិធកម្មសេដ្ឋកិច្ច សម្រួលការធ្វើពាណិជ្ជកម្មជំរុញល្បឿនកំណើន លើកកម្ពស់ផលិតភាពពលកម្ម និងកាត់បន្ថយភាពក្រីក្រនិងគម្លាតវិសមភាពសេដ្ឋកិច្ច ។ ដើម្បីលើកកម្ពស់ផលិតភាពសេដ្ឋកិច្ចកម្ពុជា, ក្របខណ្ឌគោលនយោបាយនេះ ផ្តល់អាទិភាពលើហេដ្ឋារចនាសម្ព័ន្ធចម្បងៗ ដូចខាងក្រោម÷

- **ប្រព័ន្ធដឹកជញ្ជូន÷** ប្រព័ន្ធដឹកជញ្ជូនល្អ គឺជាសមាសធាតុសំខាន់សម្រាប់តភ្ជាប់សកម្មភាពសេដ្ឋកិច្ចនិងសង្គម, ជំរុញសមាហរណកម្មនិងពាណិជ្ជកម្ម ព្រមទាំងលើកកម្ពស់រំហូរផលិតផលនិងធនធានពីកន្លែងមួយទៅកន្លែងមួយទៀត ប្រកបដោយប្រសិទ្ធផលនិងប្រសិទ្ធភាពខ្ពស់ ដែលការណ៍នេះរួមចំណែកដល់ការជំរុញកំណើនផលិតភាពសេដ្ឋកិច្ចកម្ពុជា ។ ផ្ទុយទៅវិញ គុណភាពប្រព័ន្ធដឹកជញ្ជូនទាប បង្កើនថ្លៃដើមនៃផលិតកម្មនិងពាណិជ្ជកម្ម, កាត់បន្ថយការប្រើប្រាស់របស់ប្រជាជន និងកាត់បន្ថយប្រសិទ្ធផលនៃរំហូរកត្តាផលិតកម្មសំខាន់ៗ ដែលកត្តាទាំងអស់នេះបង្កើតនូវបញ្ហាប្រឈមដល់ការធ្វើពិពិធកម្មសេដ្ឋកិច្ចនិងបង្កើនប្រសិទ្ធផលសេដ្ឋកិច្ច ព្រមទាំងកាត់បន្ថយផលិតភាពសេដ្ឋកិច្ច ។ ជាមួយនឹងកិច្ចខិតខំកសាងនិងលើកកម្ពស់គុណភាពប្រព័ន្ធដឹកជញ្ជូន, កម្ពុជា នៅមានបញ្ហាប្រឈមមួយចំនួនពាក់ព័ន្ធនឹងហេដ្ឋារចនាសម្ព័ន្ធក្នុងវិស័យនេះ ដែលចាំបាច់ត្រូវការដោះស្រាយជាប្រចាំដោយមានក្រសួង-ស្ថាប័នពាក់ព័ន្ធជាអ្នកនាំមុខ ដោយហេតុថាហេដ្ឋារចនាសម្ព័ន្ធភាគច្រើនមានលក្ខណៈជាទំនិញនិងសេវាសាធារណៈ ដែលការចូលរួមពីវិស័យឯកជននៅមានកម្រិតទាប ។ ជាក់ស្តែង តាមរយៈទិន្នន័យថ្មីៗបង្ហាញថា លទ្ធភាពទទួលបានផ្លូវថ្នល់សម្រាប់ប្រើប្រាស់នៅតំបន់ជនបទមានអត្រាត្រឹមតែ ៣៨,១០% នៃប្រជាជននៅតំបន់ជនបទសរុប ដែលអាត្រានេះគឺនៅមានកម្រិតទាប បើប្រៀបធៀបជាមួយប្រទេសក្នុងតំបន់ ។

- **ប្រព័ន្ធភស្តុភារកម្ម÷** ប្រព័ន្ធភស្តុភារកម្ម គឺជាសមាសធាតុសំខាន់ក្នុងការជំរុញនិងលើកកម្ពស់ផលិតភាពសេដ្ឋកិច្ច តាមរយៈការទាក់ទាញការវិនិយោគ, ព្រមទាំងការបែងចែកផលិតផលនិងធនធានសម្រាប់ទ្រទ្រង់សកម្មភាពផលិតកម្មនិងសេវាកម្ម ។ ដូចនេះ ប្រព័ន្ធភស្តុភារកម្មត្រូវមានគុណភាពស័ក្តិសិទ្ធភាព ភាពធន់ និងអភិបាលកិច្ចល្អ ដើម្បីសម្រេចបានភាពប្រកួតប្រជែងខ្ពស់ សំដៅកាត់បន្ថយថ្លៃនៃការបែងចែកទំនិញនិងសេវាកម្ម ។ តាមរយៈការវាយតម្លៃរបស់ធនាគារពិភពលោក, វិស័យភស្តុភារកម្មនៅកម្ពុជា មានការអភិវឌ្ឍនិងវឌ្ឍនភាពកាន់តែប្រសើរ ដោយទទួលបានចំណាត់ថ្នាក់ពីលេខ ១២៩ នៅឆ្នាំ២០១០ មកចំណាត់ថ្នាក់លេខ ៩៨ នៅឆ្នាំ២០១៨ ។ ទោះបីជាសន្ទស្សន៍ភស្តុភារកម្មនៅកម្ពុជាមានកំណើនវិជ្ជមាន ប៉ុន្តែសក្តានុពលនៃវិស័យនេះនៅមានកម្រិតទាបជាងបណ្តាប្រទេសជាសមាជិកអាស៊ានផ្សេងទៀត ដោយសារបញ្ហាប្រឈមលើហេដ្ឋារចនាសម្ព័ន្ធ នីតិវិធីគយ នីតិវិធីរដ្ឋបាល សមត្ថភាពនៃប្រព័ន្ធដឹកជញ្ជូននិងភស្តុភារកម្ម និងប្រព័ន្ធតាមដានការដឹកជញ្ជូន ដែលចាំបាច់ត្រូវការដោះស្រាយឱ្យល្អប្រសើរជាបន្ទាន់និងជាប្រចាំ ។

**- ប្រព័ន្ធទឹកស្អាត÷** ទឹកស្អាត គឺជាសមាសធាតុសំខាន់សម្រាប់ប្រើប្រាស់ក្នុងជីវភាពប្រចាំថ្ងៃ និងសម្រាប់ដំណើរការនៃផលិតកម្មនិងសេវាកម្ម ព្រមទាំងលើកកម្ពស់សុខភាពសាធារណៈដែលជាកត្តាសំខាន់ក្នុងការជំរុញផលិតភាពសេដ្ឋកិច្ច ។ សុខភាពល្អ លើកកម្ពស់ផលិតភាពនិងជវភាពនៃផលិតភាពសេដ្ឋកិច្ច

ដោយហេតុថានិយោជិតដែលមានសុខភាពល្អ មានប្រសិទ្ធផលខ្ពស់ ឆាប់ចាប់យកចំណេះដឹងនិងបច្ចេកវិទ្យាថ្មីៗ និងមានការតាំងចិត្តខ្ពស់ក្នុងការអនុវត្តការងារនិងការអភិវឌ្ឍជំនាញបន្ថែម ដែលជួយពង្រឹងបន្ថែមទាំងបរិមាណនិងគុណភាពដល់កម្លាំងពលកម្មសរុបរបស់ជាតិ ។ យោងតាមធនាគារពិភពលោក, គុណភាពនៃការផ្គត់ផ្គង់ទឹកស្អាតរបស់កម្ពុជា ត្រូវបានទទួលស្គាល់ពីកម្រិតស្តង់ដារគុណភាព ដែលប្រើប្រាស់បាន ១០០% ប៉ុន្តែប្រជាជនកម្ពុជាចំនួន ២៦,១៣% ប៉ុណ្ណោះ ដែលទទួលបានទឹកម៉ាស៊ីនសម្រាប់ប្រើប្រាស់នៅឆ្នាំ២០២០ ក្នុងនោះ ៧៧,២៨% នៅតំបន់ទីប្រជុំជន និង ១០,៨៧% នៅតំបន់ជនបទ ។ ទិន្នន័យទាំងនេះ បង្ហាញនូវគម្លាតនៃការផ្គត់ផ្គង់និងការចែកចាយទឹកស្អាតរវាងទីប្រជុំជននិងជនបទ ។ ដូច្នេះ កម្ពុជា ត្រូវតែបង្កើនសមត្ថភាពផ្គត់ផ្គង់ទឹកស្អាតបន្ថែម ប្រកបដោយបរិយាបន្ន ប្រសិទ្ធផល និងប្រសិទ្ធភាពខ្ពស់ ដើម្បីរួមចំណែកដល់ការលើកកម្ពស់សុខភាពសាធារណៈនិងជំរុញផលិតភាពសេដ្ឋកិច្ចកម្ពុជា ។

**- ប្រព័ន្ធថាមពល÷** ធនធានថាមពល ដូចជា អគ្គិសនី ប្រេង និងហ្គាស គឺជាធាតុចូលដ៏សំខាន់ និងដើរតួនាទីគន្លឹះក្នុងការអភិវឌ្ឍសេដ្ឋកិច្ចជាតិលើគ្រប់វិស័យ ។ ការវិនិយោគលើហេដ្ឋារចនាសម្ព័ន្ធថាមពល និង ការផ្គត់ផ្គង់ថាមពលប្រកបដោយភាពជឿជាក់ ភាពធន់ និងថ្លៃសមរម្យ នឹងជំរុញល្បឿនការពង្រីកគ្រប់សកម្មភាពសេដ្ឋកិច្ច ព្រមទាំងមានផលវិជ្ជមានដល់ផលិតភាពសេដ្ឋកិច្ច តាមរយៈការវិភាជធនធាននៅក្នុងដំណើរការផលិតកម្ម និងមានឥទ្ធិពលលើដំណើរនៃការអភិវឌ្ឍសេដ្ឋកិច្ចជាតិ ។ ជាការពិតថ្លៃថាមពល មានតួនាទីជាសារវន្តក្នុងដំណើរការផលិតកម្ម ក៏ដូចជាផលិតកម្មនៃធាតុចូលអន្តរការីសម្រាប់ផលិតកម្មនៃផលិតផលសម្រេច ។ ជាមួយនឹងលទ្ធផលនៃការសិក្សាស្រាវជ្រាវជាច្រើន, អង្គការវេទិកាសេដ្ឋកិច្ចពិភពលោក (WEF) បានបង្ហាញនូវទំនាក់ទំនងរវាងការទទួលបានថាមពលអគ្គិសនី និងគុណភាពនៃការផ្គត់ផ្គង់អគ្គិសនី ជាមួយនឹងផលិតភាពរបស់សហគ្រាសធុនតូច និង មធ្យម (SMEs) ។

រាជរដ្ឋាភិបាលកម្ពុជា បានបង្កើនការវិនិយោគជាច្រើនដើម្បីពង្រឹងការផ្គត់ផ្គង់អគ្គិសនី សំដៅជំរុញសក្តានុពលផលិតភាពសេដ្ឋកិច្ចគ្រួសារ សកម្មភាពអាជីវកម្ម ភាពប្រកួតប្រជែង និងតម្លៃបន្ថែមនៅក្នុងខ្សែច្រវាក់ផ្គត់ផ្គង់និងខ្សែច្រវាក់តម្លៃក្នុងប្រព័ន្ធសេដ្ឋកិច្ចជាតិ ។ ដោយមានការកើនឡើងនៃប្រាក់ចំណូលនិងសកម្មភាពសេដ្ឋកិច្ចជាប្រចាំ, តម្រូវការថាមពលបានកើនឡើងគួរឱ្យកត់សម្គាល់ជាមធ្យម១៨%ក្នុងមួយឆ្នាំ ចាប់ពីឆ្នាំ២០១០-២០១៦ ហើយត្រូវបានរំពឹងទុកថានឹងបន្តកើនឡើងដល់ ៥,៤ ដង ចាប់ពីឆ្នាំ២០១៧-២០៣៥ ។ ជាមួយគ្នានេះ លទ្ធភាពទទួលបានអគ្គិសនីនៅតាមភូមិបានកើនឡើងពី ៩,៩៥% ក្នុងឆ្នាំ ២០០៦ ទៅ ៩៧,៥៣% ក្នុងឆ្នាំ២០២១ ។ ជាមួយនឹងវឌ្ឍនភាពគួរឱ្យកត់សម្គាល់, កម្ពុជានៅបន្តជួបនូវបញ្ហាប្រឈមលើផ្នែកថាមពល ដែលត្រូវដោះស្រាយជាបន្ទាន់និងជាប្រចាំ រួមមាន ការបាត់បង់

អគ្គិសនីនៅពេលផ្ទេរនិងចែកចាយ, គុណភាពនិងភាពទុកចិត្តបាននៃការផ្គត់ផ្គង់អគ្គិសនីនៅមានកម្រិត, ការដាច់ចរន្តអគ្គិសនីមានភាពញឹកញាប់, ការចំណាយពេលយូរក្នុងការតភ្ជាប់អគ្គិសនី, ថ្លៃតភ្ជាប់អគ្គិសនីមានតម្លៃខ្ពស់ និងការប្រើប្រាស់ថាមពលកកើតឡើងវិញ មិនទាន់ដល់កម្រិតអតិបរមា ។ កម្ពុជា កំពុងបន្តបង្កើនប្រសិទ្ធភាពនៃការប្រើប្រាស់ប្រភពថាមពល ថាមពលកកើតឡើងវិញ និងប្រភពផ្សេងទៀតដែលមិនប៉ះពាល់ធ្ងន់ធ្ងរដល់បរិស្ថាន និងបង្កើនប្រសិទ្ធភាពនៃសេវាកម្មផ្គត់ផ្គង់អគ្គិសនី ។

**- ប្រព័ន្ធហេដ្ឋារចនាសម្ព័ន្ធឌីជីថល÷** ហេដ្ឋារចនាសម្ព័ន្ធឌីជីថល ដូចជា បច្ចេកវិទ្យាទូរគមនាគមន៍និងព័ត៌មាន បច្ចេកវិទ្យាប្លុកឆេន បច្ចេកវិទ្យាក្លោដ ទីក្រុងឆ្លាត ថ្នាលឌីជីថល និងបច្ចេកវិទ្យាហិរញ្ញវត្ថុមានសក្តានុពលខ្ពស់ក្នុងការជំរុញល្បឿនពិពិធកម្មសេដ្ឋកិច្ច ផលិតភាពសេដ្ឋកិច្ច និងលើកកម្ពស់កម្រិតជីវភាពប្រជាជន ។ ហេដ្ឋារចនាសម្ព័ន្ធឌីជីថល ផ្តល់ឱ្យធុរកិច្ចនូវឧបករណ៍ថ្មីៗ សម្រាប់ការធ្វើវិចិត្រកម្មផលិតនិង លក់ផលិតផល ព្រមទាំងផ្តល់មធ្យោបាយថ្មីសម្រាប់អន្តរកម្មសេដ្ឋកិច្ចនិងសង្គម ។ ការចាប់យកបច្ចេកវិទ្យា និងបសិដ្ឋកម្មជំនាញឌីជីថល បង្កើនការរួមចំណែករបស់មូលធននិងកម្លាំងពលកម្មដល់ផលិតភាពនិងកំណើនសេដ្ឋកិច្ច ។ លើសពីនេះ បច្ចេកវិទ្យាឌីជីថល ដូចជា ទិន្នន័យធំនិងបច្ចេកវិទ្យាក្លោដ ធ្វើបសិដ្ឋកម្មប្រតិបត្តិការរបស់ការិយាល័យជួរមុខ ដែលកាត់បន្ថយថ្លៃនៃការធ្វើអន្តរកម្មជាមួយអ្នកផ្គត់ផ្គង់និងអតិថិជន ដែលនេះនាំមកនូវផលប្រយោជន៍នៃការកើនឡើងនៃផលិតភាពសេដ្ឋកិច្ច ។ ថ្មីៗនេះ អង្គការសម្រាប់កិច្ចសហប្រតិបត្តិការសេដ្ឋកិច្ចនិងការអភិវឌ្ឍ (OECD) បានផ្តល់ភស្តុតាងថា ការកើនឡើងចំនួន ១០% នៃអត្រាទទួលយកបច្ចេកវិទ្យាក្លោដ ជំរុញឱ្យមានការកើនឡើងនៃផលិតភាពចំនួន ៣,៥០% ។ ការសិក្សា ជាច្រើនទៀតបានបង្ហាញថាការចាប់យកឌីជីថល បង្កើនកំណើនផលិតភាពសេដ្ឋកិច្ច, ភាពប្រកួតប្រជែង និងជំរុញល្បឿនបរិវត្តកម្មសេដ្ឋកិច្ចឆ្ពោះទៅរកសេដ្ឋកិច្ចនិងសង្គមឌីជីថល ។

ផ្អែកលើភាគលាភនៃប្រជាសាស្ត្រនិងកំណើននៃប្រជាជនប្រើប្រាស់ទូរស័ព្ទនិងអ៊ីនធឺណិត, កម្ពុជាមានសក្តានុពលខ្ពស់ក្នុងការទាញយកផលប្រយោជន៍នៃឌីជីថលូបនីយកម្ម ដើម្បីបង្កើនផលិតភាពសេដ្ឋកិច្ចនិងភាពប្រកួតប្រជែង ។ ជាក់ស្តែង ចំនួនអ្នកប្រើប្រាស់ទូរស័ព្ទ ប្រព័ន្ធអ៊ីនធឺណិត និងបណ្តាញសង្គមនៅកម្ពុជាមានការកើនឡើងខ្ពស់ជាងចំនួនប្រជាជនសរុប ដោយសារថ្លៃប្រើប្រាស់អ៊ីនធឺណិតមានកម្រិតសមរម្យនិងមាននិន្នាការថយចុះថែមទៀត តាមរយៈការកើនឡើងនៃការប្រកួតប្រជែងក្នុងវិស័យទូរគមនាគមន៍នៅកម្ពុជា ។ ក្នុងអំឡុងពេលជំងឺកូវីដ-១៩ និងបដិវត្តន៍ឧស្សាហកម្មទី៤, ការប្រើប្រាស់ប្រព័ន្ធឌីជីថលមានការកើនឡើងគួរឱ្យកត់សម្គាល់ ។ ទោះជាយ៉ាងនេះក្តី សមត្ថភាពនិងលទ្ធភាពក្នុងការប្រើប្រាស់បច្ចេកវិទ្យាទំនើបនៅកម្ពុជា អាចជួបនូវបញ្ហាប្រឈមមួយចំនួន ដោយសារប្រជាជនភាគច្រើនមានចំណេះដឹងទាបលើផ្នែកបច្ចេកវិទ្យាថ្មីៗនិងអក្ខរកម្មបច្ចេកវិទ្យា ។ ជាមួយគ្នានេះដែរ ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធឌីជីថល

នៅមានកម្រិតទាប ហើយល្បឿនអ៊ីនធឺណិតមានភាពយឺតខ្លាំង ជាពិសេសនៅតំបន់ក្រៅទីប្រជុំជននិងនៅទីជនបទ ។ ការណ៍នេះនឹងជះឥទ្ធិពលអវិជ្ជមានដល់ការជំរុញល្បឿននៃការធ្វើបរិវត្តកម្មឌីជីថលនិងការធ្វើបរិវត្តកម្មសេដ្ឋកិច្ចកម្ពុជាឆ្ពោះទៅរកសេដ្ឋកិច្ចឌីជីថលពេញលេញ ។

## ៣. ក្របខណ្ឌគោលនយោបាយ

### ៣.១. ចក្ខុវិស័យ គោលបំណង គោលដៅ

ចក្ខុវិស័យនៃក្របខណ្ឌគោលនយោបាយជាតិផលិតភាពសេដ្ឋកិច្ចកម្ពុជាគឺ ***កសាង និង លើកកម្ពស់ផលិតភាពសេដ្ឋកិច្ចជាតិដោយផ្អែកលើកម្លាំងពលកម្មជំនាញខ្ពស់ និង នវានុវត្តន៍ ដើម្បីជំរុញសន្ទុះការអភិវឌ្ឍសង្គម-សេដ្ឋកិច្ច ឱ្យកាន់តែប្រសើរ*** ។

ក្របខណ្ឌគោលនយោបាយជាតិផលិតភាពសេដ្ឋកិច្ចកម្ពុជាមានគោលបំណង ***ជំរុញកំណើនផលិតភាពសេដ្ឋកិច្ច និង បង្កើនប្រាក់ចំណូលសម្រាប់ប្រជាជនម្នាក់ៗ សំដៅបង្កើនសន្តិសុខសេដ្ឋកិច្ច និង សុខុមាលភាពសង្គម ប្រកបដោយចីរភាព និង បរិយាបន្ន*** ។

ដើម្បីសម្រេចបានចក្ខុវិស័យនិងគោលបំណងខាងលើ, រាជរដ្ឋាភិបាលកំណត់គោលដៅយុទ្ធសាស្ត្រអាទិភាពចំនួន ៤ ដែលជាកត្តាកំណត់ផលិតភាពសេដ្ឋកិច្ចគន្លឹះ រួមមាន÷

(១). **ការកែលម្អការអប់រំ និង ការបណ្តុះបណ្តាលបច្ចេកទេសវិជ្ជាជីវៈ** ដើម្បីទ្រទ្រង់និងគាំទ្រលើការបង្កើនជំនាញនិងសមត្ថភាពខ្ពស់ក្នុងការចាប់យកបច្ចេកវិទ្យា, ការបន្សាំបច្ចេកវិទ្យា និងការធ្វើនវានុវត្តន៍ ដើម្បីជំរុញផលិតភាពសេដ្ឋកិច្ចផ្អែកលើពលកម្មជំនាញ ព្រមទាំងធ្វើបរិវត្តកម្មរចនាសម្ព័ន្ធសេដ្ឋកិច្ច ដោយផ្តោតលើការអភិវឌ្ឍមូលធនមនុស្ស និងការបង្កើនផលិតភាពពលកម្មខ្ពស់,

(២). **ការជំរុញការចាប់យកបច្ចេកវិទ្យា និង នវានុវត្តន៍** ដើម្បីលើកកម្ពស់ភាពប្រកួតប្រជែងនិងការបង្កើតគុណតម្លៃសម្រាប់សង្គម-សេដ្ឋកិច្ច ដោយផ្តោតលើការអភិវឌ្ឍជំនាញបច្ចេកវិទ្យា, គាំទ្រនិងលើកទឹកចិត្តសហគ្រាសលើបច្ចេកវិទ្យានិងនវានុវត្តន៍ និងពង្រឹងប្រសិទ្ធភាពនៃកិច្ចសហប្រតិបត្តិការរវាងស្ថាប័នគាំទ្របច្ចេកវិទ្យានិងនវានុវត្តន៍,

(៣). **ការអភិវឌ្ឍសមត្ថភាពស្ថាប័នសាធារណៈ** ដើម្បីបង្កើនប្រសិទ្ធភាពនិងប្រសិទ្ធផលក្នុងការផ្តល់សេវាសាធារណៈសម្រាប់ជំរុញផលិតភាព ក្នុងរយៈពេលវែងដែលមានភាពធន់ ចីរភាព និងបរិយាបន្ន ដោយផ្តោតលើការជំរុញអភិបាលកិច្ចល្អនិងគុណភាពស្ថាប័នខ្ពស់, បទប្បញ្ញត្តិទីផ្សារ, ការប្រកួតប្រជែងស្មើភាព និងគុណភាពស្ថាប័នទីផ្សារការងារដែលកត្តាទាំងនេះកាត់បន្ថយថ្លៃដើមនិងពេលនៃប្រតិបត្តិការធុរកិច្ច, និង

**(៤). ការអភិវឌ្ឍប្រព័ន្ធហេដ្ឋារចនាសម្ព័ន្ធ** ដើម្បីសម្រេចបានប្រសិទ្ធផល ប្រសិទ្ធភាព ភាពប្រកួតប្រជែង និងការបង្កើតគុណតម្លៃសម្រាប់ជំរុញបរិវត្តកម្មសង្គម-សេដ្ឋកិច្ចដោយ ហេតុថាហេដ្ឋារចនាសម្ព័ន្ធល្អមានឥទ្ធិពលវិជ្ជមានដល់ផលិតភាពសេដ្ឋកិច្ច តាមរយៈ ការទទួលបានបច្ចេកវិទ្យា, ការកើនឡើងនៃការវិនិយោគឯកជននិងពាណិជ្ជកម្ម, ការកើនឡើង នៃប្រសិទ្ធផលក្នុងការផលិត និងសមាហរណកម្មនៃខ្សែច្រវាក់ផលិតកម្ម ។

## ៣.២. គោលការណ៍ក្នុងការជំរុញផលិតភាពសេដ្ឋកិច្ចកម្ពុជា

ផ្អែកលើបទពិសោធនិងឧត្តមានុវត្តន៍នៃបណ្តាប្រទេសមួយចំនួននៅក្នុងពិភពលោក ព្រមទាំង ដើម្បីជំរុញផលិតភាពសេដ្ឋកិច្ច ប្រកបដោយប្រសិទ្ធភាព ប្រសិទ្ធផល ចីរភាព និងបរិយាបន្ន, រាជរដ្ឋាភិបាល កំណត់យកគោលការណ៍អនុវត្តជាមូលដ្ឋានចំនួន ៣ ដូចខាងក្រោម÷

**(១). កិច្ចសហប្រតិបត្តិការនៃគ្រប់តួអង្គសេដ្ឋកិច្ច÷** សំដៅលើការអនុវត្តផលិតភាពសេដ្ឋកិច្ច ស្ថិតក្នុងជវភាពនៃប្រព័ន្ធតួអង្គតែមួយ ដែលនឹងបង្កើតជាកម្លាំងចលករយ៉ាងសកម្មពីគ្រប់ភាគីពាក់ព័ន្ធក្នុង ការធ្វើយុទ្ធនាការផលិតភាពសេដ្ឋកិច្ចឱ្យទៅមុខយ៉ាងរឹងមាំ បង្កើនគុណភាព ប្រសិទ្ធផល និងប្រសិទ្ធភាព លើសមិទ្ធផលការងារ ។ ក្នុងក្របខណ្ឌជវភាពនៃប្រព័ន្ធតួអង្គតែមួយ, ការងារនឹងអនុវត្តប្រកបដោយ សហថាមពល (ការផ្គួបថាមពលដោយប្រទាក់ក្រឡា និង ស៊ីសង្វាក់គ្នា) មានសង្គតិភាព មានកិច្ចសហការ ជិតស្និទ្ធ ផ្តល់ព័ត៌មាន និងបំពេញឱ្យគ្នាទៅវិញទៅមក ព្រមទាំងមានការទទួលខុសត្រូវខ្ពស់ ដើម្បីសម្រេច បានជោគជ័យក្នុងការអនុវត្តវិធានការគោលនយោបាយលើកកម្ពស់ផលិតភាពសេដ្ឋកិច្ចកម្ពុជា,

**(២). ការបែងចែកដោយសមធម៌នៃផលប្រយោជន៍ផលិតភាព÷** សំដៅលើសមិទ្ធផលនៃផលិតភាព សេដ្ឋកិច្ចដែលនឹងផ្តល់ឱ្យទៅគ្រប់តួអង្គសេដ្ឋកិច្ច រួមមាន វិនិយោគិន និយោជក និយោជិត អ្នកប្រើប្រាស់ ទំនិញនិងសេវាកម្ម និងអ្នកពាក់ព័ន្ធទាំងអស់ ដើម្បីធានាការលើកទឹកចិត្តខ្ពស់ក្នុងការបង្កើនកិច្ចខិតខំ ប្រឹងប្រែងកាន់តែខ្លាំងនិងការធ្វើបសិដ្ឋកម្ម ប្រកបដោយជវភាពនៃភាពប្រកួតប្រជែងនៃផលិតផលរបស់ កម្ពុជា ។ ជាពិសេស គោលការណ៍គុណាធិបតេយ្យ ត្រូវពង្រឹងជាប្រចាំដើម្បីបង្កើតឱ្យមានប្រព័ន្ធនៃការលើក ទឹកចិត្តនិងជំរុញកម្លាំងភាគីពាក់ព័ន្ធ ឱ្យមានការចូលរួមពេញលេញក្នុងស្មារតីបុរេសកម្មប្រកបដោយសមធម៌ ប្រសិទ្ធភាព និងភាពទទួលខុសត្រូវខ្ពស់, និង

**(៣). ការបង្កើតការងារសម្រាប់រយៈពេលវែង÷** សំដៅលើស្ថិរភាពនិងកំណើនការងារ ស្របពេល ដែលផលិតភាពសេដ្ឋកិច្ចកម្ពុជាត្រូវបានលើកកម្ពស់ ។ ក្នុងកិច្ចខិតខំជំរុញផលិតភាពសេដ្ឋកិច្ច, ការប្រែប្រួល ទៅលើស្ថានភាពការងារនឹងអាចកើតមានឡើង ។ ដើម្បីនិរន្តរភាពនៃការបង្កើនទាំងផលិតភាពនិងការងារ, រាជរដ្ឋាភិបាល និយោជក និងនិយោជិត ត្រូវសហការនិងយកចិត្តទុកដាក់រៀបចំនិងបណ្តុះបណ្តាល

ជំនាញឡើងវិញប្រកបដោយប្រតិសកម្ម ដល់កម្លាំងពលកម្មដែលរងផលប៉ះពាល់ដោយវិធានការជំរុញផលិតភាព សំដៅអនុញ្ញាតឱ្យកម្លាំងពលកម្មទាំងនោះសម្របខ្លួនទៅនឹងការប្រែប្រួលដែលអាចកើតមានជាយថាហេតុទៅលើការងាររបស់ខ្លួន ។ ក្នុងន័យនេះ ការបង្កើនកម្រិតជំនាញកម្លាំងពលកម្ម និងការបណ្តុះបណ្តាលជំនាញឡើងវិញ សម្រាប់វិស័យដែលមានកំណើនកម្លាំងពលកម្មពិតជាមានសារៈសំខាន់ ដើម្បីធានានិរន្តរភាពក្នុងការជំរុញផលិតភាពសេដ្ឋកិច្ចកម្ពុជា ប្រកបដោយចីរភាព ភាពធន់ និងបរិយាបន្ន ។

**រូបភាពទី ១÷ គោលការណ៍ក្នុងការជំរុញផលិតភាពសេដ្ឋកិច្ចកម្ពុជា**




## ៣.៣. វិធានការគោលនយោបាយគន្លឹះ

វិធានការគោលនយោបាយគន្លឹះនេះ ត្រូវបានរៀបចំឡើងដើម្បីកែលម្អកត្តាកំណត់ផលិតភាពសេដ្ឋកិច្ចទាំង៤ ដែលជាអាទិភាពក្នុងការកសាងនិងជំរុញផលិតភាពសេដ្ឋកិច្ចកម្ពុជា ។ ជាមួយគ្នានេះ ក្របខណ្ឌពេលវេលានិងការទទួលខុសត្រូវនៃក្រសួង-ស្ថាប័នពាក់ព័ន្ធ ក្នុងការអនុវត្តវិធានការគោលនយោបាយទាំងនេះ នឹងមានបញ្ជាក់លម្អិតនៅក្នុងតារាងម៉ាទ្រីសនៃឧបសម្ព័ន្ធ ។ ក្រសួង-ស្ថាប័នពាក់ព័ន្ធត្រូវដាក់ចេញផែនការសកម្មភាពលម្អិត និងទទួលខុសត្រូវក្នុងការអនុវត្តវិធានការគោលនយោបាយ ទាំងនេះប្រកបដោយភាពប្រទាក់ក្រឡានិងស្មារតីសហប្រតិបត្តិការខ្ពស់ ស្របតាមឯកទេសកម្មទៅតាមក្របខណ្ឌពេលវេលាដែលបានកំណត់ ។ ទន្ទឹមនេះ ក្រសួង-ស្ថាប័ន ត្រូវប្រកាន់យកអភិក្រមក្នុងការបញ្ជ្រាបសញ្ញាណ

ផលិតភាពសេដ្ឋកិច្ច ទៅក្នុងគ្រប់ឯកសារការងារ គោលនយោបាយ ផែនការយុទ្ធសាស្ត្រ និងកម្មវិធីអភិវឌ្ឍន៍តាមវិស័យរបស់ខ្លួន ជាពិសេសនៅតាមវិស័យទាំង៤ ដែលជាកត្តាកំណត់ផលិតភាពសេដ្ឋកិច្ច ប៉ុន្តែមិនកំហិតត្រឹមតែ ៤ វិស័យនេះទេ ។ វិធានការគោលនយោបាយគន្លឹះទាំងនេះ រួមមាន÷

### ៣.៣.១. ការកែលម្អការអប់រំ និង ការបណ្តុះបណ្តាលបច្ចេកទេសវិជ្ជាជីវៈ

ការអប់រំ និង ការបណ្តុះបណ្តាលបច្ចេកទេសវិជ្ជាជីវៈ ដើរតួនាទីយ៉ាងសំខាន់ក្នុងការកសាងមូលធនមនុស្ស ការលើកកម្ពស់ចំណេះដឹង ចំណេះធ្វើ ទេពកោសល្យ និងជំនាញ ក្នុងការបង្កើតគំនិតច្នៃប្រឌិត សម្រាប់ទាញយកប្រយោជន៍ពីបច្ចេកវិទ្យាថ្មីៗ សំដៅជំរុញកំណើនផលិតភាពសេដ្ឋកិច្ច វិបុលភាព និងភាពប្រកួតប្រជែងយកឈ្នះរបស់កម្ពុជា ។ ក្នុងន័យនេះ ដើម្បីសម្រេចបានការអភិវឌ្ឍមូលធនមនុស្សរឹងមាំនិងការបង្កើនផលិតភាពរបស់កម្លាំងពលកម្មជាតិខ្ពស់, ក្របខណ្ឌគោលនយោបាយនេះផ្តល់អាទិភាពសំខាន់ៗ ដូចខាងក្រោម÷

#### (១). វិធានការគោលនយោបាយអភិវឌ្ឍមូលធនមនុស្ស

មូលធនមនុស្សគឺជាបុរេលក្ខខណ្ឌដ៏ចាំបាច់ សម្រាប់ជំរុញកំណើនផលិតភាពសេដ្ឋកិច្ច, ជាធាតុចូលសកម្មនាំមុខនៅក្នុងដំណើរការផលិតកម្មនានា និងជាមូលដ្ឋានគ្រឹះក្នុងការបង្កើនផលិតភាពការងារ និងសម្របខ្លួនជាមួយនិន្នាការនៃការវិវត្តថ្មីៗ ដូចជា បដិវត្តន៍ឧស្សាហកម្មទី៤និងសេដ្ឋកិច្ចឌីជីថល ។ វិធានការគោលនយោបាយពាក់ព័ន្ធនឹងការអភិវឌ្ឍមូលធនមនុស្ស មានដូចខាងក្រោម÷

- កែលម្អកម្មវិធីអប់រំ ដោយផ្តោតលើការកសាងនិងពង្រឹងសមត្ថភាពវិភាគស៊ីជម្រៅនិងសមត្ថភាពលើជំនាញទន់ ព្រមទាំងលើកកម្ពស់ចំណេះដឹងផ្នែកវិទ្យាសាស្ត្រអនុវត្តន៍,
- រៀបចំយន្តការសិក្សានិងវាយតម្លៃ ព្រមទាំងពិគ្រោះយោបល់ជាមួយសហគ្រាសនិងគ្រឹះស្ថានអប់រំ ទាំងសាធារណៈនិងឯកជន ក្នុងគោលដៅធានាឱ្យបានសង្គតិភាពនៃកម្មវិធីអប់រំជាមួយនឹងកម្មវិធីបណ្តុះបណ្តាលបច្ចេកទេសវិជ្ជាជីវៈ ដើម្បីបំពេញតម្រូវការនៃការអភិវឌ្ឍសេដ្ឋកិច្ចនិងទីផ្សារជាក់ស្តែង,
- រៀបចំយុទ្ធសាស្ត្រកាត់បន្ថយការបោះបង់ការសិក្សានៅកម្រិតមធ្យមសិក្សានិងលើកទឹកចិត្តឱ្យសិស្សានុសិស្សបន្តសិក្សារហូតដល់កម្រិតមធ្យមសិក្សាទុតិយភូមិ ឬ ខ្ពស់ជាងនេះ,
- រៀបចំយន្តការសិក្សា តាមដាន និងវាយតម្លៃលើវឌ្ឍនភាពនិងគុណភាពវិស័យអប់រំ ដោយផ្តោតលើសមិទ្ធផលនិងវិបាកនៃការវិនិយោគក្នុងវិស័យនេះ,

- ពន្លឿនការរៀបចំយុទ្ធសាស្ត្រពង្រឹងសមត្ថភាព ក្នុងការទទួលយក ការបន្សាំ ការធ្វើនវានុវត្តន៍ និងការធ្វើបរិវត្តកម្មនៅក្នុងកម្មវិធីអប់រំផ្នែកវិទ្យាសាស្ត្រ បច្ចេកវិទ្យា វិស្វកម្ម និងគណិតវិទ្យា,
- បញ្ចូលទស្សនាទានផលិតភាពនិងវប្បធម៌ផលិតភាពនៅក្នុងកម្មវិធីអប់រំ ព្រមទាំងផ្សព្វផ្សាយអំពីសារៈសំខាន់នៃការបង្កើតផលិតភាពក្នុងការសិក្សានិងការងារ,
- រៀបចំយន្តការនិងគោលការណ៍ណែនាំ បង្កើតបរិយាកាសសិក្សាដែលមានអំណោយផលនិងបង្កើនប្រសិទ្ធភាពក្នុងការផ្សព្វផ្សាយ សម្រាប់ការបញ្ជាបគុណតម្លៃនៃការសិក្សានិងការបណ្តុះស្មារតីភាពជាម្ចាស់ ដើម្បីទាក់ទាញនិងលើកទឹកចិត្តឱ្យមានការចូលរួមបណ្តុះវប្បធម៌នៃការអប់រំបណ្តុះបណ្តាលឱ្យកាន់តែប្រសើរឡើង,
- រៀបចំនិងដាក់ឱ្យអនុវត្តផែនការយុទ្ធសាស្ត្រអភិវឌ្ឍមូលធនមនុស្សក្នុងបរិបទបដិវត្តន៍ឧស្សាហកម្មទី៤ និងក្របខណ្ឌប្រព័ន្ធអេកូឡូស៊ីនៃការអភិវឌ្ឍមូលធនមនុស្ស , និង
- រៀបចំផែនការពង្រឹងនិងពង្រីកវិសាលភាពនៃការអប់រំ នៅតាមទីជនបទនិងតំបន់ដាច់ស្រយាល ។

### (២). វិធានការគោលនយោបាយអភិវឌ្ឍមូលធនមនុស្សកម្រិតឧត្តមសិក្សា

ការអភិវឌ្ឍធនធានមនុស្សកម្រិតឧត្តមសិក្សា ដើរតួនាទីយ៉ាងសំខាន់ក្នុងការលើកកម្ពស់មូលធនមនុស្សសម្រាប់ជំរុញផលិតភាពសេដ្ឋកិច្ច, បង្កើនភាពប្រកួតប្រជែងក្នុងទីផ្សារការងារនិងជំរុញសម្ទុះនៃការអភិវឌ្ឍសង្គម-សេដ្ឋកិច្ច ។ វិធានការគោលនយោបាយពាក់ព័ន្ធនឹងការអភិវឌ្ឍមូលធនមនុស្សកម្រិតឧត្តមសិក្សា មានដូចខាងក្រោម÷

- រៀបចំផែនការនិងយុទ្ធសាស្ត្រលើកទឹកចិត្តនិងទាក់ទាញឥស្សរជននិងអ្នកស្រាវជ្រាវជាន់ខ្ពស់ដែលមានគុណវុឌ្ឍិនិងចំណេះដឹងអប់រំខ្ពស់ ព្រមទាំងមានបទពិសោធការងារជាក់ស្តែង ដើម្បីចូលរួមក្នុងការបណ្តុះបណ្តាលនៅតាមគ្រឹះស្ថានឧត្តមសិក្សា,
- រៀបចំផែនការវិនិយោគបន្ថែមដល់គ្រឹះស្ថានឧត្តមសិក្សា ដែលមានគុណភាពខ្ពស់ក្នុងការបណ្តុះបណ្តាលជំនាញសមស្របតាមតម្រូវការទីផ្សារ,
- ធ្វើទំនើបកម្មហេដ្ឋារចនាសម្ព័ន្ធពាក់ព័ន្ធនឹងការបណ្តុះបណ្តាលមុខវិជ្ជាវិទ្យាសាស្ត្រអនុវត្តន៍ និងបច្ចេកវិទ្យា នៅតាមគ្រឹះស្ថានឧត្តមសិក្សា,
- លើកទឹកចិត្តឱ្យគ្រឹះស្ថានឧត្តមសិក្សាលើកកម្ពស់ការផ្តល់ការបណ្តុះបណ្តាលមុខវិជ្ជាវិទ្យាសាស្ត្រអនុវត្តន៍ បច្ចេកវិទ្យា និងសេដ្ឋកិច្ចបៃតង សមស្របតាមតម្រូវការនៃទីផ្សារការងារជាក់ស្តែង,
- សិក្សានិងពិនិត្យលើលទ្ធភាពបង្កើនកម្មវិធីអាហារូបករណ៍ សម្រាប់ជំរុញការកសាងជំនាញដែលជាតម្រូវការទីផ្សារ និងជាទិសដៅអភិវឌ្ឍសង្គម-សេដ្ឋកិច្ចរបស់រាជរដ្ឋាភិបាល,

- រៀបចំយុទ្ធនាការជំរុញឱ្យសិស្សានុសិស្សចាប់យកជំនាញក្នុងវិទ្យាសាស្ត្រអនុវត្តន៍ នៅកម្រិតឧត្តមសិក្សា សមស្របនឹងតម្រូវការទីផ្សារនិងទិសដៅនៃការអភិវឌ្ឍសេដ្ឋកិច្ចជាតិ,
- បង្កើតឱ្យមានកម្មវិធីប្រឹក្សាយោបល់ដល់សិស្សានុសិស្ស ក្នុងការជ្រើសរើសអាជីពនិងមុខជំនាញនៅតាមវិទ្យាល័យនិងគ្រឹះស្ថានឧត្តមសិក្សា,
- រៀបចំផែនការធ្វើបច្ចុប្បន្នកម្មលើកម្មវិធីបណ្តុះបណ្តាលបច្ចេកទេសនិងវិទ្យាសាស្ត្រ ដែលបម្រើឱ្យវិស័យឧស្សាហកម្មនិងវិស័យដទៃទៀតដែលមានតម្លៃបន្ថែមខ្ពស់ ស្របតាមការប្រែប្រួលនៃទីផ្សារការងារក្នុងស្រុកនិងទិសដៅនៃការអភិវឌ្ឍវិស័យឧស្សាហកម្មជាតិ,
- រៀបចំយន្តការនិងក្របខណ្ឌ ដើម្បីជំរុញនិងលើកកម្ពស់ការចូលរៀនក្នុងចំណោមនិស្សិតក្រីក្រ និស្សិតនារី និងនិស្សិតរស់នៅក្នុងតំបន់ដាច់ស្រយាល,
- រៀបចំយន្តការពិនិត្យ តាមដាន និងវាយតម្លៃ ដើម្បីធានាស្តង់ដារនៃកម្មវិធីសិក្សានៅកម្រិតឧត្តមសិក្សា សមស្របនឹងស្តង់ដារតំបន់និងអន្តរជាតិ, និង
- រៀបចំយន្តការលើកទឹកចិត្តដល់គ្រឹះស្ថានឧត្តមសិក្សា សម្រាប់ជំរុញការអភិវឌ្ឍការស្រាវជ្រាវ បង្កើនសមត្ថភាពបង្រៀននិងស្រាវជ្រាវ ព្រមទាំងពង្រឹងការគ្រប់គ្រងនិងអភិបាលកិច្ចល្អនៃគ្រឹះស្ថានឧត្តមសិក្សា ។

### (៣). វិធានការគោលនយោបាយបង្កើនផលិតភាពកម្លាំងពលកម្មជាតិ

ពលកម្មជំនាញ គឺជាកម្លាំងចលករនិងជាធាតុចូលចម្បងក្នុងដំណើរការអភិវឌ្ឍសង្គម-សេដ្ឋកិច្ច ។ ក្នុងន័យនេះ ការកសាងកម្លាំងពលកម្មឱ្យមានចំណេះដឹង ជំនាញវិជ្ជាជីវៈ និងឯកទេសកម្មខ្ពស់ គឺជាកត្តាចាំបាច់សម្រាប់ពង្រឹងផលិតភាពសេដ្ឋកិច្ចនិងទ្រទ្រង់ដល់ដំណើរការបរិវត្តកម្មសង្គម-សេដ្ឋកិច្ច ។ វិធានការគោលនយោបាយពាក់ព័ន្ធនឹងការបង្កើនផលិតភាពកម្លាំងពលកម្មជាតិ មានដូចខាងក្រោម÷

- រៀបចំផែនការជំរុញការបែងចែកកម្លាំងពលកម្មឱ្យសមស្របទៅតាមជំនាញវិជ្ជាជីវៈ និងឯកទេសកម្មដើម្បីសម្រេចបានប្រសិទ្ធផល ប្រសិទ្ធភាព និងផលិតភាពពលកម្មខ្ពស់ជាអតិបរមា,
- រៀបចំក្របខណ្ឌ ឬ យន្តការ ជំរុញនិងលើកទឹកចិត្តដល់សហគ្រាសនិងគ្រឹះស្ថានបណ្តុះបណ្តាលលើចំណេះដឹងបច្ចេកទេសនិងជំនាញវិជ្ជាជីវៈ ដូចជា រ៉ូបូទិក, ការវិភាគទិន្នន័យ, ការរចនានិងការអភិវឌ្ឍផលិតផល, វិស្វកម្មមេកានិក, ការសរសេរកម្មវិធី, បច្ចេកទេសគ្រប់គ្រងបណ្តាញកុំព្យូទ័រ, បច្ចេកទេស និងវិស្វកម្មយានយន្ត,

- រៀបចំផែនការនិងយុទ្ធនាការលើកកម្ពស់ការគាំទ្រជាសាធារណៈលើការចាប់យកអាជីព ដែលផ្អែកលើជំនាញវិជ្ជាជីវៈនិងបច្ចេកទេស ដើម្បីលើកទឹកចិត្តឱ្យប្រជាជនទូទៅចូលរួមក្នុងកម្មវិធីបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈទាំងនេះ,
- រៀបចំយុទ្ធសាស្ត្រលើកកម្ពស់គុណតម្លៃនិងពង្រឹងគុណភាព TVET សំដៅបង្កើនសមត្ថភាពនិងផលិតភាពសេដ្ឋកិច្ចក្នុងសកម្មភាពដែលមានតម្លៃបន្ថែមខ្ពស់,
- កំណត់យុទ្ធសាស្ត្រវិនិយោគនិងគ្រប់គ្រងលើការអភិវឌ្ឍកម្លាំងពលកម្មជាតិ ដើម្បីបង្កើនគុណភាពនិងសមត្ថភាពកម្លាំងពលកម្ម សម្រាប់ទ្រទ្រង់សេដ្ឋកិច្ចដោយផ្អែកលើជំនាញបច្ចេកទេសនិងវិជ្ជាជីវៈ,
- រៀបចំគោលការណ៍ណែនាំដល់រោងចក្រ សហគ្រាស និងក្រុមហ៊ុន ស្តីពីការផ្តល់បរិស្ថានការងារគាំទ្រផលិតភាពនិងសុវត្ថិភាពឧស្សាហកម្ម ដើម្បីជំរុញប្រសិទ្ធភាពផលិតកម្មនិងភាពប្រកួតប្រជែងខ្ពស់,
- រៀបចំគោលការណ៍ណែនាំដល់រោងចក្រ សហគ្រាស និងក្រុមហ៊ុន ស្តីពីការអភិវឌ្ឍចំណេះដឹងជំនាញបច្ចេកទេសនិងវិជ្ជាជីវៈ និងឯកទេសកម្ម សម្រាប់កម្លាំងពលកម្មជាតិដើម្បីជំរុញការងារដែលផ្តល់តម្លៃបន្ថែមខ្ពស់,
- រៀបចំផែនការធ្វើសមាហរណកម្មពលករទេសន្តប្រវេសន៍ខ្មែរទៅក្នុងទីផ្សារការងារ និងសង្គម ដើម្បីកំណើនផលិតភាពសេដ្ឋកិច្ចកម្ពុជា,
- រៀបចំយន្តការតាមដាននិងវាយតម្លៃ លើគុណភាពកម្មវិធីអប់រំនិងបណ្តុះបណ្តាលបច្ចេកទេសវិជ្ជាជីវៈ ផ្អែកលើគោលការណ៍ប្រសិទ្ធភាព ប្រសិទ្ធផល ភាពប្រកួតប្រជែង និងការបង្កើតគុណតម្លៃ, និង
- រៀបចំយន្តការសហប្រតិបត្តិការរវាងស្ថាប័នសាធារណៈ ស្ថាប័នឯកជន ស្ថាប័នស្រាវជ្រាវ និងគ្រឹះស្ថានសិក្សាក្នុងការតម្រង់ទិសកម្មវិធីអប់រំបណ្តុះបណ្តាលបច្ចេកទេស និង វិជ្ជាជីវៈសំដៅជំរុញល្បឿនពិពិធកម្មសេដ្ឋកិច្ចកម្ពុជា ។

### ៣.៣.២. ការជំរុញផ្នែកបច្ចេកវិទ្យា និង នវានុវត្តន៍

បច្ចេកវិទ្យានិងនវានុវត្តន៍ រួមចំណែកយ៉ាងសំខាន់ដល់កំណើនផលិតភាព តាមរយៈការអភិវឌ្ឍចំណេះដឹង វិធីសាស្ត្រផលិតកម្ម និងការបង្កើតផលិតផលថ្មីៗ ។ ការវិនិយោគលើការកសាងចំណេះដឹងបែបវិទ្យាសាស្ត្រនិងបច្ចេកវិទ្យា គឺជាកត្តាចាំបាច់ក្នុងការជំរុញនវានុវត្តន៍ ។ ការពង្រឹងសមត្ថភាពនវានុវត្តន៍ទាមទារនូវចំណេះដឹងថ្មីៗ បច្ចេកវិទ្យាទំនើប និងការសម្របខ្លួនជាមួយនឹងភាពជឿនលឿននៃបច្ចេកវិទ្យា និងបរិវត្តកម្មសង្គម-សេដ្ឋកិច្ច ។ ដូច្នេះ ក្របខណ្ឌគោលនយោបាយនេះផ្តល់អាទិភាព ដូចខាងក្រោម÷

#### (១). វិធានការគោលនយោបាយអភិវឌ្ឍជំនាញបច្ចេកវិទ្យា

ជំនាញបច្ចេកវិទ្យា គឺជាមូលដ្ឋានគ្រឹះក្នុងការទាញយកផលប្រយោជន៍បន្ថែមពីបច្ចេកវិទ្យា ការកសាងទេពកោសល្យ និងការបង្កើតគំនិតច្នៃប្រតិដ្ឋបន្ថែម ដែលជាគុណតម្លៃក្នុងការពង្រឹងផលិតភាព ។ វិធានការគោលនយោបាយពាក់ព័ន្ធនឹងការអភិវឌ្ឍជំនាញបច្ចេកវិទ្យា មានដូចខាងក្រោម÷

- រៀបចំនិងជំរុញការបណ្តុះបណ្តាលលើអក្ខរកម្មបច្ចេកវិទ្យានិងការប្រើប្រាស់បច្ចេកវិទ្យាឌីជីថល ដើម្បីលើកកម្ពស់ប្រសិទ្ធភាព ប្រសិទ្ធផល និងផលិតភាពការងារ,
- រៀបចំនិងកែលម្អកម្មវិធីបណ្តុះបណ្តាលចំណេះដឹងផ្នែកបច្ចេកវិទ្យានិងនវានុវត្តន៍ សំដៅសម្រួលដល់ការចាប់យកបច្ចេកវិទ្យាថ្មីនិងទាញយកផលប្រយោជន៍ពីបច្ចេកវិទ្យាទាំងនោះ,
- រៀបចំកម្មវិធីបណ្តុះបណ្តាលលើការបង្កើតកម្មវិធីឌីជីថល ទាំងក្នុងស្ថាប័នសាធារណៈនិងឯកជន, និង
- រៀបចំផែនការពង្រឹង និងពង្រីកវិសាលភាពនិងគុណភាពនៃការអភិវឌ្ឍជំនាញក្នុងការផ្តល់សេវាកម្មតាមប្រព័ន្ធឌីជីថលសម្រាប់វិស័យឯកជន ។

#### (២). វិធានការគោលនយោបាយគាំទ្រ និង លើកទឹកចិត្តសហគ្រាសលើបច្ចេកវិទ្យា និង នវានុវត្តន៍

វិស័យឯកជន ដើរតួនាទីយ៉ាងសំខាន់ក្នុងផលិតកម្មនិងត្រូវបានចាត់ទុកថាជាក្បាលម៉ាស៊ីនសម្រាប់កំណើនសេដ្ឋកិច្ចនិងការអភិវឌ្ឍសង្គម-សេដ្ឋកិច្ច ។ សហគ្រាសធុនតូចនិងមធ្យម ត្រូវមានសមត្ថភាពនិងលទ្ធភាពពង្រឹងនវានុវត្តន៍ ដើម្បីលើកកម្ពស់ផលិតភាពនិងភាពប្រកួតប្រជែង សំដៅជំរុញការអភិវឌ្ឍសង្គម-សេដ្ឋកិច្ចឱ្យរស់រវើកនិងមានចីរភាព ។ ការគាំទ្រផ្នែកបច្ចេកវិទ្យានិងការលើកទឹកចិត្ត នឹងជំរុញសមត្ថភាពនវានុវត្តន៍របស់សហគ្រាស ដែលការណ៍នេះសម្រេចបាន តាមរយៈការដាក់ចេញនិងអនុវត្តវិធានការគោលនយោបាយ ដូចខាងក្រោម÷

- បង្កើតក្របខណ្ឌជំរុញការវិនិយោគនិងការចូលរួមរបស់វិស័យឯកជន ក្នុងគម្រោងវិនិយោគដែលមានបច្ចេកវិទ្យាទំនើប,
- រៀបចំកម្មវិធីជំរុញឱ្យវិស័យឯកជនចូលរួមក្នុងសកម្មភាពសិក្សាស្រាវជ្រាវ ការអភិវឌ្ឍ និងនវានុវត្តន៍ ដើម្បីបង្កើនផលិតភាពសេដ្ឋកិច្ច, និង
- រៀបចំក្របខណ្ឌពង្រឹងគុណភាពនិងឯកទេសកម្មលើការស្រាវជ្រាវនិងការអភិវឌ្ឍ ដើម្បីជំរុញការអភិវឌ្ឍផលិតផលថ្មីនិងនវានុវត្តកម្មលើដំណើរការអនុវត្តការងារ ។

### (៣). វិធានការគោលនយោបាយពង្រឹងប្រសិទ្ធភាពនៃកិច្ចសហប្រតិបត្តិការរវាងស្ថាប័នគាំទ្របច្ចេកវិទ្យា និង នវានុវត្តន៍

កិច្ចសហប្រតិបត្តិការនិងទំនាក់ទំនងល្អរវាងក្រសួង-ស្ថាប័នពាក់ព័ន្ធ លើការចែកចាយព័ត៌មានទិន្នន័យ ឯកទេសកម្ម ធនធានមនុស្ស និងហិរញ្ញវត្ថុ ជាកត្តាចាំបាច់សម្រាប់នវានុវត្តន៍ ។ ការលើកកម្ពស់កិច្ចសហប្រតិបត្តិការអន្តរក្រសួង-ស្ថាប័ន ដើម្បីគាំទ្រនវានុវត្តន៍ឱ្យបានកាន់តែល្អប្រសើរសម្រេចបាន តាមរយៈការដាក់ចេញនិងអនុវត្តវិធានការគោលនយោបាយ ដូចខាងក្រោម÷

- រៀបចំយន្តការនិងកម្មវិធីចែករំលែកចំណេះដឹង ជំនាញវិជ្ជាជីវៈ ជំនាញបច្ចេកទេស ឯកទេសកម្ម ព័ត៌មាន និងទិន្នន័យរវាងក្រសួង-ស្ថាប័ន វិស័យឯកជន គ្រឹះស្ថានអប់រំ និងស្ថាប័នស្រាវជ្រាវទាំងរដ្ឋនិងឯកជន ដើម្បីបង្កើតជាឱកាសទំនាក់ទំនងរវាងស្ថាប័នទាំងនោះជាប្រចាំ,
- រៀបចំយន្តការសិក្សាស្រាវជ្រាវរួម រវាងក្រសួង-ស្ថាប័ន វិស័យឯកជន គ្រឹះស្ថានអប់រំ និងស្ថាប័នស្រាវជ្រាវទាំងរដ្ឋនិងឯកជន ស្របតាមអភិក្រម "ជីវភាពនៃប្រព័ន្ធតួអង្គតែមួយ",
- គាំទ្រនិងរៀបចំកម្មវិធីនានា សំដៅពង្រឹងកិច្ចសហប្រតិបត្តិការរវាងវិស័យសាធារណៈនិងឯកជន ក្នុងការផ្លាស់ប្តូរបទពិសោធ ការសិក្សាស្រាវជ្រាវ និងអភិវឌ្ឍន៍ផលិតផលថ្មីៗ,
- ជំរុញការចូលរួមយ៉ាងសកម្ម និងកិច្ចសហប្រតិបត្តិការក្នុងស្មារតីបុរេសកម្មរវាងវិស័យសារធារណៈ និងឯកជនក្នុងការចាប់យកនិងប្រើប្រាស់បច្ចេកវិទ្យាទំនើបនិងធ្វើនវានុវត្តន៍, និង
- លើកកម្ពស់ការគាំទ្រសេដ្ឋកិច្ចឌីជីថលនិងនវានុវត្តន៍ ដើម្បីជំរុញការតភ្ជាប់រវាងនវានុវត្តន៍សេដ្ឋកិច្ចឌីជីថលនិងផលិតភាពសេដ្ឋកិច្ច ។

### ៣.៣.៣. ការអភិវឌ្ឍសមត្ថភាពស្ថាប័នសាធារណៈ

ស្ថាប័នសាធារណៈ គឺជាយុទ្ធសាស្ត្រវិទ្ធទទួលបន្ទុកដឹកនាំ គ្រប់គ្រង ព្រមទាំងកំណត់ទិសដៅនិងអនុវត្តគោលនយោបាយ ច្បាប់ និងបទប្បញ្ញត្តិលើការគ្រប់គ្រង បែងចែក និងប្រើប្រាស់ធនធានជាតិ ។ ស្ថាប័នសាធារណៈ ត្រូវធានាឱ្យបានបរិវត្តកម្មលើមុខងារស្ថាប័នប្រកបដោយស័ក្តិសិទ្ធភាព ផលិតភាព តម្លាភាព គណនេយ្យភាព និងគុណតម្លៃបន្ថែម ដើម្បីបំពេញតម្រូវការសាធារណៈនិងស្ថាប័នឯកជនឱ្យទាន់ពេល ។ ក្របខណ្ឌគោលនយោបាយនេះ ផ្តោតសំខាន់លើការបង្កើនប្រសិទ្ធផលនិងប្រសិទ្ធភាពនៃសេវាសាធារណៈ តាមរយៈការជំរុញអភិបាលកិច្ចល្អ កែលម្អបទប្បញ្ញត្តិទីផ្សារ និងលើកកម្ពស់ស្ថាប័នទីផ្សារការងារ សំដៅបង្កើនទំនុកចិត្តនិងភាពជឿជាក់របស់សាធារណជន ។ ដូច្នេះ ក្របខណ្ឌគោលនយោបាយនេះផ្តល់អាទិភាព ដូចខាងក្រោម÷

#### (១). វិធានការគោលនយោបាយលើអភិបាលកិច្ចល្អ

កម្ពុជា ត្រូវបន្តកែលម្អអភិបាលកិច្ចបន្ថែមក្នុងការផ្តល់សេវាសាធារណៈប្រកបដោយប្រសិទ្ធភាព ដើម្បីបង្កើតបរិស្ថានល្អសម្រាប់ធុរកិច្ចនិងលើកកម្ពស់ផលិតភាពសេដ្ឋកិច្ច ។ អភិបាលកិច្ចល្អនាំមកនូវការកាត់បន្ថយចំណាយក្រៅផ្លូវការលើប្រតិបត្តិការការងារ ដែលនឹងពង្រឹងការប្រកួតប្រជែងស្មើភាពនិងកិច្ចការពារអ្នកប្រើប្រាស់ ។ ការណ៍នេះនឹងធ្វើឱ្យសេវាសាធារណៈមានថ្លៃសមរម្យនិងមានទំនុកចិត្តខ្ពស់ ដែលនាំទៅរកការទាក់ទាញការវិនិយោគដែលមានតម្លៃបន្ថែមខ្ពស់ និងភាពងាយស្រួលក្នុងការធ្វើអាជីវកម្មនិងការរស់នៅរបស់ប្រជាជន ។ វិធានការគោលនយោបាយពាក់ព័ន្ធអភិបាលកិច្ចល្អ មានដូចខាងក្រោម÷

- កែលម្អយន្តការតាមដាននិងធ្វើការវាយតម្លៃជាប្រចាំក្នុងការផ្តល់សេវាសាធារណៈ ជាពិសេស ដើម្បីកាត់បន្ថយចំណាយថវិកានិងពេល ព្រមទាំងនីតិវិធីមិនចាំបាច់,
- ជំរុញទម្លាប់ធ្វើវិចារណកម្មលើវិធានការកែទម្រង់នានា នៅតាមក្រសួង-ស្ថាប័នសាធារណៈសំដៅលើកកម្ពស់ការឱ្យតម្លៃលើផលប្រយោជន៍សង្គមជាតិទាំងមូលក្នុងរយៈពេលវែង,
- លើកកម្ពស់ស្មារតីសហប្រតិបត្តិការអន្តរក្រសួង-ស្ថាប័ន ឱ្យបានសមស្របទៅនឹងតម្រូវការការងារនៅតាមក្រសួង-ស្ថាប័នសាធារណៈ,
- ពង្រីកវិសាលភាពនៃការអនុវត្តអភិបាលកិច្ចឌីជីថល ស្របតាមគោលនយោបាយរដ្ឋាភិបាលឌីជីថលកម្ពុជា ២០២២-២០៣៥,
- បន្តជំរុញការរៀបចំនិងអនុវត្តផែនការកែទម្រង់ការផ្តល់សេវាសាធារណៈ នៅតាមក្រសួង-ស្ថាប័នសាធារណៈនានា ក្នុងគោលដៅធានាគុណភាពនិងភាពជឿទុកចិត្តខ្ពស់, និង

- បង្កើតនិងជំរុញយុទ្ធនាការផ្តល់សេវាសាធារណៈ ផ្អែកលើគោលការណ៍ “ *ប្រសិទ្ធភាព ប្រសិទ្ធផល និង គុណតម្លៃ* ។

## (២). វិធានការគោលនយោបាយលើបទប្បញ្ញត្តិទីផ្សារ

ទីផ្សារដែលមានការប្រកួតប្រជែងនិងតម្លាភាពខ្ពស់ គឺជាបុរេលក្ខខណ្ឌមួយ សម្រាប់ធានាឱ្យបាននូវបរិស្ថាន ដែលមានលក្ខណៈអំណោយផលនិងជំរុញដល់ការខិតខំប្រឹងប្រែងអភិវឌ្ឍខ្លួនឯងរបស់គ្រប់តួអង្គសេដ្ឋកិច្ច ដែលជាកត្តាចាំបាច់ក្នុងការលើកកម្ពស់ផលិតភាពសេដ្ឋកិច្ច ។ ការណ៍នេះតម្រូវឱ្យរាជរដ្ឋាភិបាលបន្តអនុវត្តនិងកែលម្អអភិបាលកិច្ចបទប្បញ្ញត្តិទីផ្សារឱ្យបានម៉ឺងម៉ាត់ តាមរយៈការដាក់ចេញនិងអនុវត្តវិធានការគោលនយោបាយ ដូចខាងក្រោម÷

- រៀបចំនិងដាក់ចេញក្របខណ្ឌអនុវត្តអភិបាលកិច្ចទីផ្សារ ផ្អែកលើគោលការណ៍សេដ្ឋកិច្ចទីផ្សារដែលផ្តល់ផលប្រយោជន៍ដល់គ្រប់តួអង្គសេដ្ឋកិច្ច ប្រកបដោយសមធម៌,
- ពិនិត្យឡើងវិញលើបទប្បញ្ញត្តិសំខាន់ៗពាក់ព័ន្ធនឹងការវិនិយោគ សំដៅលើកកម្ពស់ប្រសិទ្ធភាពនៃច្បាប់ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជាក្នុងការទាក់ទាញគម្រោងវិនិយោគ ដែលមានបច្ចេកវិទ្យាខ្ពស់ តម្លៃបន្ថែមខ្ពស់ និងនវានុវត្តន៍ប្រកបដោយភាពច្នៃប្រតិដ្ឋខ្ពស់,
- ពង្រឹងប្រសិទ្ធភាពនៃការអនុវត្តច្បាប់ពាក់ព័ន្ធនឹងបទប្បញ្ញត្តិទីផ្សារ ដូចជា ច្បាប់ស្តីពីការប្រកួតប្រជែងនិងច្បាប់ស្តីពីកិច្ចការពារអ្នកប្រើប្រាស់,
- បង្កើតនិងដាក់ឱ្យប្រើប្រាស់នូវបណ្តុំទិន្នន័យ សម្រាប់ផ្តល់ព័ត៌មាននិងទិន្នន័យទីផ្សារឱ្យមានសង្គតិភាព ភាពជឿជាក់ និងតម្លាភាពខ្ពស់, និង
- កែលម្អយន្តការតាមដាននិងវាយតម្លៃលើការអនុវត្តអភិបាលកិច្ចទីផ្សារ ដោយផ្តោតលើវិបាកប្រសិទ្ធផល ប្រសិទ្ធភាព និងគុណតម្លៃ ។

## (៣). វិធានការគោលនយោបាយលើកកម្ពស់ស្ថាប័នទីផ្សារការងារ

ការកសាងស្ថាប័នទីផ្សារការងារល្អ បង្កើនទំនុកចិត្តទៅវិញទៅមករវាងនិយោជិតនិងនិយោជក, លើកទឹកចិត្តការវិនិយោគលើការអប់រំ និង បណ្តុះបណ្តាលជំនាញវិជ្ជាជីវៈ ព្រមទាំងជំរុញកិច្ចខិតខំប្រឹងប្រែងកសាងសមត្ថភាពនិងជំនាញបន្ថែមដែលទាំងនេះគឺជាកត្តាកំណត់ដ៏សំខាន់ សំដៅជំរុញការវិនិយោគនិងបង្កើនផលិតភាពសេដ្ឋកិច្ចប្រកបដោយចីរភាព ។ វិធានការគោលនយោបាយពាក់ព័ន្ធនឹងការលើកកម្ពស់ស្ថាប័នទីផ្សារការងារ មានដូចខាងក្រោម÷

- កាត់បន្ថយឱ្យនៅកម្រិតអប្បបរមានូវភាពមិនស៊ីសង្វាក់គ្នារវាងតម្រូវការទីផ្សារការងារ និងការផ្គត់ផ្គង់ជំនាញ តាមរយៈការធ្វើបច្ចុប្បន្នភាពជាប្រចាំលើទិន្នន័យអំពីតម្រូវការនិងការផ្គត់ផ្គង់

កម្លាំងពលកម្មជាតិតាមវិស័យ, កិច្ចសហការរវាងនិយោជកនិងគ្រឹះស្ថានអប់រំបណ្តុះបណ្តាល និងការលើកកម្ពស់ប្រសិទ្ធភាពនៃការផ្តល់សេវាកម្មផ្គូផ្គងការងារ,

- លើកកម្ពស់វប្បធម៌គុណាធិបតេយ្យ សំដៅបង្កើនភាពបត់បែននៃទីផ្សារការងារ ដើម្បីជំរុញ និងលើកទឹកចិត្តឱ្យមានកិច្ចខិតខំប្រឹងប្រែងអភិវឌ្ឍសមត្ថភាពនិងផលិតភាពរបស់ខ្លួន បន្ថែមទៀតជាប្រចាំ,
- ជំរុញការវិនិយោគបន្ថែមទៅលើការអប់រំនិងការបណ្តុះបណ្តាល សំដៅពង្រឹងសមត្ថភាពរបស់កម្លាំងពលកម្មក្នុងការចាប់យកជំនាញថ្មីៗ និងបង្កើនចល័តភាពការងារ ដើម្បីឱ្យកម្លាំងពលកម្មអាចសម្របខ្លួនតាមការវិវត្តនៃតម្រូវការទីផ្សារការងារ,
- បន្តរៀបចំនិងពង្រឹងការអនុវត្តកម្មវិធីគាំពារសង្គមដល់និយោជិត ដូចជា ការធានារ៉ាប់រងលើការបាត់បង់ការងារ ការថែទាំសុខភាព និងរបបសន្តិសុខសង្គមផ្នែកប្រាក់សោធន,
- រៀបចំក្របខណ្ឌលើកទឹកចិត្តដើម្បីទាក់ទាញអ្នកមានទេពកោសល្យ ជាពិសេសតាមរយៈការជំរុញមាតុភូមិនិវត្តន៍នៃសិស្សនិស្សិតទទួលការអប់រំនៅក្រៅប្រទេស និងកម្លាំងពលកម្មដែលមានបទពិសោធនិងជំនាញវិជ្ជាជីវៈខ្ពស់,
- រៀបចំផែនការវិនិយោគបន្ថែមលើហេដ្ឋារចនាសម្ព័ន្ធទិន្នន័យ ចងក្រងទិន្នន័យ និងធ្វើការព្យាករតម្រូវការកម្លាំងពលកម្មតាមវិស័យ តាមរយៈការធ្វើបច្ចុប្បន្នភាពជាប្រចាំ,
- កែលម្អយន្តការអភិបាលកិច្ចលើលក្ខខណ្ឌការងារ សំដៅធានាសុខុមាលភាពនិងផាសុកភាពនិយោជិត,
- រៀបចំយុទ្ធនាការជំរុញឱ្យមានការប្រើប្រាស់សេវាប្រឹក្សាយោបល់ពាក់ព័ន្ធនឹងការស្វែងរកការងារ, ការត្រៀមខ្លួនចូលទីផ្សារការងារ, ការផ្លាស់ប្តូរអាជីព និងការបណ្តុះបណ្តាលបច្ចេកទេសជំនាញវិជ្ជាជីវៈ ស្របតាមតម្រូវការរបស់ទីផ្សារការងារជាក់ស្តែង, និង
- បង្កើតជាកម្មវិធី ឬ ឱកាសទំនាក់ទំនងជាប្រចាំរវាងនិយោជក និយោជិត និងភាគីពាក់ព័ន្ធនានាក្នុងវិស័យអាទិភាព ដើម្បីឱ្យភាគីនីមួយៗយល់ច្បាស់ពីតម្រូវការទីផ្សារនិងឱកាសនានា ។

### ៣.៣.៤. ការអភិវឌ្ឍប្រព័ន្ធហេដ្ឋារចនាសម្ព័ន្ធ

ប្រព័ន្ធហេដ្ឋារចនាសម្ព័ន្ធ រួមចំណែកយ៉ាងសំខាន់ក្នុងការលើកកម្ពស់ផលិតភាពសេដ្ឋកិច្ច តាមរយៈការពង្រឹងប្រសិទ្ធភាពនិងប្រសិទ្ធផល, កាត់បន្ថយចំណាយទាំងថវិកានិងពេល, ទ្រទ្រង់កិច្ចដំណើរការដល់គ្រប់តួអង្គនៃសង្គមនិងភ្នាក់ងារសេដ្ឋកិច្ច និងជាកត្តាជំរុញការវិនិយោគលើសកម្មភាពដែលមានតម្លៃបន្ថែមខ្ពស់ ។ ក្របខណ្ឌគោលនយោបាយនេះ បានចាត់ទុកប្រព័ន្ធហេដ្ឋារចនាសម្ព័ន្ធ ជាអាទិភាពមួយ

យ៉ាងសំខាន់ក្នុងការចូលរួមលើកកម្ពស់ផលិតភាពសេដ្ឋកិច្ច ដោយផ្ដោតជាពិសេសលើការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធសំខាន់ៗ រួមមាន ប្រព័ន្ធដឹកជញ្ជូន ប្រព័ន្ធភស្តុភារកម្ម ប្រព័ន្ធទឹកស្អាត ប្រព័ន្ធថាមពល និងប្រព័ន្ធហេដ្ឋារចនាសម្ព័ន្ធឌីជីថល ។ ទន្ទឹមនេះ វិធានការគោលនយោបាយនៃប្រព័ន្ធហេដ្ឋារចនាសម្ព័ន្ធបានឆ្លើយតបជាមួយគោលបំណង គោលដៅ និងយុទ្ធសាស្ត្រនៃការអភិវឌ្ឍបៃតង ។ ដូច្នេះ ក្របខណ្ឌគោលនយោបាយនេះ ផ្ដល់អាទិភាព ដូចខាងក្រោម÷

### (១). វិធានការគោលនយោបាយលើប្រព័ន្ធដឹកជញ្ជូន

ប្រព័ន្ធដឹកជញ្ជូន គឺជាតួអង្គយ៉ាងសំខាន់ក្នុងការតភ្ជាប់សកម្មភាពសេដ្ឋកិច្ចនិងសង្គម, ជាមូលដ្ឋានគ្រឹះក្នុងការគាំទ្រប្រព័ន្ធភស្តុភារកម្ម, លើកកម្ពស់ប្រសិទ្ធភាពសេដ្ឋកិច្ច សុវត្ថិភាព និងទំនុកចិត្ត, ព្រមទាំងកាត់បន្ថយចំណាយនានា ដែលកត្តាទាំងនេះរួមចំណែកយ៉ាងសំខាន់ក្នុងការពង្រឹងផលិតភាពសេដ្ឋកិច្ច ។ វិធានការគោលនយោបាយពាក់ព័ន្ធនឹងប្រព័ន្ធដឹកជញ្ជូន មានដូចខាងក្រោម÷

- រៀបចំផែនការធ្វើទំនើបកម្មនិងលើកកម្ពស់សមត្ថភាពប្រព័ន្ធដឹកជញ្ជូន ឱ្យសមស្របទៅនឹងតម្រូវការអភិវឌ្ឍសេដ្ឋកិច្ចទាំងបច្ចុប្បន្ននិងអនាគត សំដៅបង្កើនប្រសិទ្ធផលនិងប្រសិទ្ធភាពនៃសេដ្ឋកិច្ចដឹកជញ្ជូន,
- រៀបចំយន្តការគ្រប់គ្រង តាមដាននិងវាយតម្លៃ និងកែលម្អការអនុវត្តយន្តការសម្របសម្រួល និងសហប្រតិបត្តិការអន្តរក្រសួង-ស្ថាប័នពាក់ព័ន្ធនឹងគុណភាពនៃប្រព័ន្ធដឹកជញ្ជូន ដើម្បីជំរុញបន្ថែមការអភិវឌ្ឍនិងធានាប្រសិទ្ធផលនៃសេដ្ឋកិច្ចដឹកជញ្ជូន, និង
- រៀបចំនិងកែលម្អយុទ្ធសាស្ត្រដោះស្រាយបញ្ហាកកស្ទះ ដើម្បីធានាបានស័ក្តិសិទ្ធភាពនៃវិហ្វចរាចរណ៍និងការដឹកជញ្ជូន ។

### (២). វិធានការគោលនយោបាយលើប្រព័ន្ធភស្តុភារកម្ម

ប្រព័ន្ធភស្តុភារកម្មដើរតួនាទីយ៉ាងសំខាន់ក្នុងការពង្រីកទំហំនិងសេដ្ឋកិច្ចមាត្រដ្ឋាន និងធានាភាពរលូននៃសកម្មភាពផលិតកម្ម ការដឹកជញ្ជូន និងពាណិជ្ជកម្ម ដើម្បីបែងចែកនិងផ្គត់ផ្គង់ទំនិញ ។ ប្រព័ន្ធភស្តុភារកម្មដែលមានប្រសិទ្ធផល ប្រសិទ្ធភាព និងសមត្ថភាពអភិបាលកិច្ចល្អ អាចធានាថាធាតុចូលផលិតកម្មអាចត្រូវបានដឹកជញ្ជូនទៅគោលដៅផលិតកម្មនិងទីផ្សារ ហើយផលិតផលអាចត្រូវបានដឹកជញ្ជូនទៅទីផ្សារក្នុងតម្លៃសមរម្យ ទាន់ពេល និងប្រកបដោយទំនុកចិត្តខ្ពស់ ។ វិធានការគោលនយោបាយពាក់ព័ន្ធនឹងប្រព័ន្ធភស្តុភារកម្ម មានដូចខាងក្រោម÷

- រៀបចំក្របខណ្ឌគតិយុត្តនិងគោលការណ៍ណែនាំ ដើម្បីបង្កើនស័ក្តិសិទ្ធភាពនិងគុណភាពនៃប្រព័ន្ធភស្តុភារកម្មសម្រាប់ទ្រទ្រង់ផលិតភាពសេដ្ឋកិច្ច,
- ពិនិត្យឡើងវិញ និងកែលម្អនីតិវិធីគយនិងរដ្ឋបាលពាក់ព័ន្ធនឹងការអនុវត្តច្រកចេញចូលតែមួយ សំដៅធានាភាពរលូនពីដើមខ្សែដល់ចុងខ្សែនិងកាត់បន្ថយចំណាយ ដើម្បីជំរុញភាពប្រកួតប្រជែង និងសម្រួលដល់ប្រតិបត្តិការនានា,
- ជំរុញយន្តការភាពជាដៃគូរវាងរដ្ឋនិងឯកជន ក្នុងការវិនិយោគលើវិស័យភស្តុភារកម្ម ដូចជាការបង្កើតមជ្ឈមណ្ឌលភស្តុភារកម្ម ដើម្បីលើកកម្ពស់ភាពប្រកួតប្រជែងក្នុងវិស័យនេះ, និង
- កែលម្អយន្តការតាមដាននិងវាយតម្លៃជាប្រចាំលើស័ក្តិសិទ្ធភាពប្រតិបត្តិការ និងគុណភាពនៃការផ្តល់សេវាភស្តុភារកម្ម ។

### (៣). វិធានការគោលនយោបាយលើប្រព័ន្ធទឹកស្អាត

ការទទួលបានប្រព័ន្ធទឹកស្អាតដែលមានប្រសិទ្ធផលនិងគុណភាពខ្ពស់ គឺជាតម្រូវការសំខាន់សម្រាប់បង្កើនផលិតភាពសេដ្ឋកិច្ចនិងគុណតម្លៃសម្រាប់សង្គម តាមរយៈការធានាសុខភាពសាធារណៈខ្ពស់ ។ ការពង្រឹងគុណភាពនៃប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាត ដែលមានស្រាប់និងពង្រីកបន្ថែមនូវវិសាលភាពនៃការទទួលបានទឹកស្អាតប្រកបដោយបរិយាបន្ន ជាកិច្ចការចាំបាច់ ។ វិធានការគោលនយោបាយពាក់ព័ន្ធនឹងប្រព័ន្ធទឹកស្អាត មានដូចខាងក្រោម ÷

- កែលម្អបច្ចេកវិទ្យាគ្រប់គ្រងទឹកស្អាត ដើម្បីធានាប្រសិទ្ធផល ប្រសិទ្ធភាព និងគុណភាពនៃការផលិតនិងផ្គត់ផ្គង់ទឹកស្អាត សំដៅបំពេញតម្រូវការនៃការអភិវឌ្ឍសង្គម-សេដ្ឋកិច្ចជាក់ស្តែង,
- ជំរុញការវិនិយោគតាមយន្តការភាពជាដៃគូរវាងរដ្ឋនិងឯកជន ក្នុងប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាតដើម្បីពង្រឹងនិងពង្រីកវិសាលភាពក្នុងការទទួលបានទឹកស្អាត នៅតាមទីជនបទនិងតំបន់ដាច់ស្រយាល, និង
- សិក្សានិងរៀបចំផែនការវិនិយោគនិងអភិវឌ្ឍលើស្ថានីយ៍ទឹកស្អាត ដើម្បីបង្កើនសមត្ថភាពផលិតផ្គត់ផ្គង់និងចែកចាយទឹកស្អាត ដើម្បីបំពេញតម្រូវការជាក់ស្តែង ស្របតាមដំណើរការអភិវឌ្ឍសង្គម-សេដ្ឋកិច្ច ។

### (៤). វិធានការគោលនយោបាយលើប្រព័ន្ធថាមពល

ថាមពល គឺជាផ្នែកមួយយ៉ាងសំខាន់នៃដំណើរការផលិតកម្មនិងទ្រទ្រង់ជីវភាពរបស់ប្រជាជន ។ ការពង្រឹងនិងធានាឱ្យបាននូវសន្តិសុខថាមពល ពិតជាមានសារៈសំខាន់ដែលនឹងពង្រឹងទំនុកចិត្ត, ធានាភាព

រលូននៃសកម្មភាពនានាក្នុងខ្សែច្រវាក់ផលិតកម្ម និងទាក់ទាញការវិនិយោគលើសកម្មភាព ដែលមានតម្លៃបន្ថែមខ្ពស់និងបច្ចេកវិទ្យាថ្មី ជាពិសេសក្នុងបរិការណ៍ដែលកម្ពុជាកំពុងប្រឈមនឹងកំណើនប្រជាជន និងកំណើនសេដ្ឋកិច្ចខ្ពស់ ។ ជាមួយនេះ ថាមពលជាធាតុចូលផលិតកម្មយ៉ាងសំខាន់ ដែលតម្រូវឱ្យមានស្ថិរភាព ថ្លៃសមរម្យ និងគ្របដណ្តប់កាន់តែទូលំទូលាយ ដើម្បីធានាសម្រេចបាននូវផលិតភាពសេដ្ឋកិច្ច ។ វិធានការគោលនយោបាយពាក់ព័ន្ធនឹងប្រព័ន្ធថាមពល មានដូចខាងក្រោម÷

- រៀបចំយុទ្ធសាស្រ្តសន្តិសុខថាមពលសម្រាប់រយៈពេលវែង ដើម្បីទ្រទ្រង់តម្រូវការបរិវត្តកម្មសេដ្ឋកិច្ច និងធានាទំនុកចិត្តពីវិនិយោគិនលើការវិនិយោគដែលមានតម្លៃបន្ថែមខ្ពស់,
- រៀបចំផែនការបង្កើនការវិនិយោគលើផលិតកម្មថាមពល ជាពិសេសថាមពលកកើតឡើងវិញ សំដៅកាត់បន្ថយថ្លៃថាមពល ធានាសន្តិសុខថាមពល និងពង្រឹងពង្រីកសមត្ថភាពផ្គត់ផ្គង់ និងចែកចាយថាមពល,
- រៀបចំគម្រោងវិនិយោគលើការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធតភ្ជាប់និងចែកចាយថាមពល ដើម្បីធានាស្ថិរភាពនៃការផ្គត់ផ្គង់ថាមពល និងពង្រីកវិសាលភាពនៃការផ្គត់ផ្គង់នៅក្រៅទីប្រជុំជន និងជនបទ តាមអាទិភាពនៃតម្រូវការនិងភាពចាំបាច់ជាក់ស្តែង,
- ពិនិត្យលើប្រសិទ្ធភាពនៃការផ្គត់ផ្គង់ថាមពលប្រកបដោយតម្លាភាព គណនេយ្យភាព ការទទួលខុសត្រូវខ្ពស់ និងទាន់ពេល, និង
- បង្កើតយន្តការសិក្សា តាមដាន ត្រួតពិនិត្យ និងវាយតម្លៃលើភាពសមស្របនៃការផ្គត់ផ្គង់ និងចែកចាយថាមពលក្នុងការជំរុញឧស្សាហូបនីយកម្មនិងលើកកម្ពស់សកម្មភាពសេដ្ឋកិច្ច ។

### (៥). វិធានការគោលនយោបាយលើប្រព័ន្ធហេដ្ឋារចនាសម្ព័ន្ធឌីជីថល

បច្ចុប្បន្ន ការវិវត្តនៃប្រព័ន្ធបច្ចេកវិទ្យានិងប្រព័ន្ធឌីជីថល បានរួមចំណែកយ៉ាងសំខាន់ក្នុងការបង្កើនប្រសិទ្ធភាពនិងផលិតភាពនៃសកម្មភាពសេដ្ឋកិច្ច ។ ដើម្បីចាប់យកកាលានុវត្តភាពនេះ, កម្ពុជាចាំបាច់ត្រូវបង្កើននិងពង្រឹងចំណេះដឹងបច្ចេកវិទ្យា, សម្រួលការផ្សារភ្ជាប់ទំនាក់ទំនង តាមរយៈប្រព័ន្ធឌីជីថល ព្រមទាំងកសាងចំណេះដឹងនិងជំនាញចាំបាច់សម្រាប់ចាប់យកបច្ចេកវិទ្យាទាំងនេះ មកប្រើប្រាស់ក្នុងការងារនិងទាញយកផលប្រយោជន៍ជាអតិបរមាពីប្រព័ន្ធបច្ចេកវិទ្យានិងប្រព័ន្ធឌីជីថល ។ វិធានការគោលនយោបាយពាក់ព័ន្ធនឹងប្រព័ន្ធហេដ្ឋារចនាសម្ព័ន្ធឌីជីថល មានដូចខាងក្រោម ÷

- រៀបចំនិងអនុវត្តផែនការជំរុញនិងពន្លឿនការធ្វើបរិវត្តកម្មឌីជីថល នៅតាមក្រសួង-ស្ថាប័នសាធារណៈស្របតាមគន្លងប្រក្រតីភាពថ្មី,

- រៀបចំក្របខណ្ឌលើកទឹកចិត្តបង្កើនការវិនិយោគលើប្រព័ន្ធឌីជីថលដល់សហគ្រាសធុនតូច និងមធ្យម,
- រៀបចំក្របខណ្ឌជំរុញការវិនិយោគលើហេដ្ឋារចនាសម្ព័ន្ធឌីជីថល ដើម្បីឆ្លើយតបនឹងបរិវត្តកម្មសេដ្ឋកិច្ចនិងបដិវត្តន៍ឧស្សាហកម្មទី៤,
- បង្កើតយន្តការថ្នាក់ជាតិសម្រាប់តាមដាន វាស់វែង និងវាយតម្លៃលើភាពសមស្របនិងប្រសិទ្ធភាពនៃការប្រើប្រាស់ប្រព័ន្ធឌីជីថលដើម្បីជំរុញផលិតភាពសេដ្ឋកិច្ច,
- រៀបចំផែនការបំពាក់បច្ចេកវិទ្យានិងប្រព័ន្ធឌីជីថល សម្រាប់ការអប់រំនិងបណ្តុះបណ្តាលប្រកបដោយបរិយាបន្ន,
- រៀបចំបណ្ណាល័យឌីជីថលនិងការគ្រប់គ្រងសន្និធិចំណេះដឹង, និង
- បង្កើតយន្តការសហប្រតិបត្តិការអន្តរក្រសួង-ស្ថាប័ន ដើម្បីផ្តល់ការគាំទ្រផ្នែកបច្ចេកវិទ្យាទៅវិញទៅមក ។

## តារាងសង្ខេបស្តីពី គោលដៅយុទ្ធសាស្ត្រអាទិភាពទាំង៤ សម្រាប់កសាង និង លើកកម្ពស់ផលិតភាពសេដ្ឋកិច្ចជាតិ

ដើម្បីសម្រេចបានចក្ខុវិស័យនិងគោលបំណង នៃក្របខណ្ឌគោលនយោបាយជាតិផលិតភាពសេដ្ឋកិច្ចកម្ពុជា ២០២២-២០៣៥, រាជរដ្ឋាភិបាលកំណត់គោលដៅយុទ្ធសាស្ត្រអាទិភាពចំនួន ៤ ដែលជាកត្តាកំណត់ផលិតភាពសេដ្ឋកិច្ចគន្លឹះ រួមមាន÷

| គោលដៅយុទ្ធសាស្ត្រ | វិធានការគោលនយោបាយ |
|---|---|
| **១.ការកែលម្អការអប់រំ និង ការបណ្តុះបណ្តាលបច្ចេកទេសវិជ្ជាជីវៈ ដើម្បីទ្រទ្រង់និងគាំទ្រលើការបង្កើនជំនាញ និងសមត្ថភាពខ្ពស់ក្នុងការចាប់យកបច្ចេកវិទ្យា ការបន្សាំបច្ចេកវិទ្យា និងការធ្វើនវានុវត្តន៍** | ១.១. ការអភិវឌ្ឍមូលធនមនុស្ស |
| | ១.២. ការអភិវឌ្ឍមូលធនមនុស្សកម្រិតឧត្តមសិក្សា |
| | ១.៣. ការបង្កើនផលិតភាពកម្លាំងពលកម្មជាតិ |
| **២.ការជំរុញការចាប់យកបច្ចេកវិទ្យា និង នវានុវត្តន៍ ដើម្បីលើកកម្ពស់ភាពប្រកួតប្រជែង និងការបង្កើតគុណតម្លៃសម្រាប់សង្គម-សេដ្ឋកិច្ច** | ២.១. ការអភិវឌ្ឍជំនាញបច្ចេកវិទ្យា |
| | ២.២. ការគាំទ្រ និង លើកទឹកចិត្តសហគ្រាសលើបច្ចេកវិទ្យា និង នវានុវត្តន៍ |
| | ២.៣. ការពង្រឹងប្រសិទ្ធភាពនៃកិច្ចសហប្រតិបត្តិការរវាងស្ថាប័នគាំទ្របច្ចេកវិទ្យា និង នវានុវត្តន៍ |
| **៣.ការអភិវឌ្ឍសមត្ថភាពស្ថាប័នសាធារណៈ ដើម្បីបង្កើនប្រសិទ្ធភាពនិងប្រសិទ្ធផលក្នុងការផ្តល់សេវាសាធារណៈ សម្រាប់ជំរុញផលិតភាពក្នុងរយៈពេលវែងដែលមានភាពធន់ ចីរភាព និងបរិយាបន្ន** | ៣.១. អភិបាលកិច្ចល្អ |
| | ៣.២. បទប្បញ្ញត្តិទីផ្សារ |
| | ៣.៣. ការលើកកម្ពស់ស្ថាប័នទីផ្សារការងារ |
| **៤.ការអភិវឌ្ឍប្រព័ន្ធហេដ្ឋារចនាសម្ព័ន្ធ ដើម្បីសម្រេចបាន ប្រសិទ្ធផល ប្រសិទ្ធភាព ភាពប្រកួតប្រជែង និងការបង្កើតគុណតម្លៃសម្រាប់ជំរុញបរិវត្តកម្មសង្គម-សេដ្ឋកិច្ច** | ៤.១. ប្រព័ន្ធដឹកជញ្ជូន |
| | ៤.២. ប្រព័ន្ធភស្តុភារកម្ម |
| | ៤.៣. ប្រព័ន្ធទឹកស្អាត |
| | ៤.៤. ប្រព័ន្ធថាមពល |
| | ៤.៥. ប្រព័ន្ធហេដ្ឋារចនាសម្ព័ន្ធឌីជីថល |

## ៤. ក្របខណ្ឌអនុវត្ត និង យន្តការសម្របសម្រួល តាមដាន និង វាយតម្លៃ

ក្របខណ្ឌគោលនយោបាយជាតិផលិតភាពសេដ្ឋកិច្ចកម្ពុជា គឺជាគោលនយោបាយសម្រាប់រយៈពេលវែងរបស់រាជរដ្ឋាភិបាល ដែលត្រូវរៀបចំឡើងដើម្បីជំរុញកំណើនផលិតភាព, ដោះស្រាយបញ្ហាប្រឈមផលិតភាព និងជំរុញការអនុវត្តគោលការណ៍ផលិតភាព “**ប្រសិទ្ធភាព ប្រសិទ្ធផល ភាពប្រកួតប្រជែង និងការបង្កើតគុណតម្លៃ**” ក្នុងការលើកកម្ពស់បន្ថែមដល់ការអភិវឌ្ឍសង្គម-សេដ្ឋកិច្ច ។ ដើម្បីធានាការអនុវត្តក្របខណ្ឌគោលនយោបាយនេះ ទទួលបានជោគជ័យនិងសម្រេចតាមចក្ខុវិស័យនិងគោលបំណង, រាជរដ្ឋាភិបាល រៀបចំនិងកំណត់ក្របខណ្ឌអនុវត្ត ព្រមទាំងយន្តការសម្របសម្រួល តាមដាន និងវាយតម្លៃ សម្រាប់ធ្វើការសិក្សា ត្រួតពិនិត្យ និងវិភាគលើវឌ្ឍនភាព សមិទ្ធកម្ម សមិទ្ធផល និងវិបាកនៃក្របខណ្ឌគោលនយោបាយនេះ ឱ្យកាន់តែមុតស្រួច ច្បាស់លាស់ និងមានការតាំងចិត្តខ្ពស់ពីគ្រប់ក្រសួង-ស្ថាប័នពាក់ព័ន្ធ ។

### ៤.១. ការរៀបចំក្របខណ្ឌស្ថាប័ន និង យន្តការសម្របសម្រួល

ក្របខណ្ឌគោលនយោបាយជាតិផលិតភាពសេដ្ឋកិច្ចកម្ពុជា មានលក្ខណៈចម្រុះវិស័យគ្រប់ទិដ្ឋភាពសង្គមនិងសេដ្ឋកិច្ច ។ ដូច្នេះ យន្តការស្ថាប័ននិងយន្តការសម្របសម្រួលការគ្រប់គ្រងឱ្យបានគ្រប់ជ្រុងជ្រោយ ត្រូវបង្កើតឡើងប្រកបដោយភាពប្រទាក់ក្រឡា ស្មារតីសហការខ្ពស់ និងការចូលរួមយ៉ាងសកម្មពីក្រសួង-ស្ថាប័នពាក់ព័ន្ធទាំងអស់ ។ ដើម្បីធានាបានការអនុវត្តក្របខណ្ឌគោលនយោបាយនេះឱ្យទទួលបានប្រសិទ្ធផល ប្រសិទ្ធភាព ភាពទទួលខុសត្រូវ និងជោគជ័យខ្ពស់, រចនាសម្ព័ន្ធគ្រប់គ្រងខាងក្រោម នឹងត្រូវដាក់ឱ្យអនុវត្ត÷

**រូបភាពទី ២÷ យន្តការស្ថាប័នក្នុងការអនុវត្តក្របខណ្ឌគោលនយោបាយ**



## គណៈកម្មាធិការជាតិផលិតភាពសេដ្ឋកិច្ចកម្ពុជា (គ.ជ.ផ.ក.)

**គ.ជ.ផ.ក.** ត្រូវបានបង្កើតដោយអនុក្រឹត្យលេខ ១២៣ អនក្រ.បក ចុះថ្ងៃទី២៧ ខែសីហា ឆ្នាំ២០១៩ ដែលមានរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ជាប្រធាន ។ **គ.ជ.ផ.ក.** គឺជាសេនាធិការរបស់រាជរដ្ឋាភិបាល ទទួលបន្ទុកជាស្ថាប័នដឹកនាំ អភិវឌ្ឍ និងរៀបចំគោលនយោបាយ ព្រមទាំងសម្របសម្រួលតាមដាន ត្រួតពិនិត្យ និងវាយតម្លៃលើការអនុវត្តក្របខណ្ឌគោលនយោបាយនេះ ។ ក្នុងក្របខណ្ឌគោលនយោបាយជាតិផលិតភាពសេដ្ឋកិច្ចកម្ពុជា, **គ.ជ.ផ.ក.** គឺជាស្ថាប័នកំពូលកម្រិតនយោបាយដែលត្រូវទទួលបន្ទុកដឹកនាំ ធ្វើសេចក្តីសម្រេច និងសម្របសម្រួលអន្តរស្ថាប័នពាក់ព័ន្ធទាំងអស់ ។

## អគ្គលេខាធិការដ្ឋានគណៈកម្មាធិការជាតិផលិតភាពសេដ្ឋកិច្ចកម្ពុជា

អគ្គលេខាធិការដ្ឋាន **គ.ជ.ផ.ក.** ត្រូវបានបង្កើតដោយអនុក្រឹត្យលេខ ២៧ អនក្រ.បក ចុះថ្ងៃទី១០ ខែមីនា ឆ្នាំ២០២០ ដែលជាសេនាធិការរបស់ **គ.ជ.ផ.ក.** លើការងារបច្ចេកទេស ការសិក្សាស្រាវជ្រាវបែបវិទ្យាសាស្ត្រ រដ្ឋបាល និងប្រតិបត្តិការនានា ។ ក្នុងក្របខណ្ឌគោលនយោបាយនេះ, អគ្គលេខាធិការដ្ឋាន **គ.ជ.ផ.ក.** ត្រូវធ្វើកិច្ចសហប្រតិបត្តិការនិងសម្របសម្រួលការងាររវាងក្រុមការងារបច្ចេកទេសទាំង៤ ក៏ដូចជាប្រមូលបូកសរុបរបាយការណ៍និងរៀបចំកិច្ចប្រជុំរបស់ **គ.ជ.ផ.ក.** ។

## ក្រុមការងារបច្ចេកទេស

ដើម្បីគាំទ្រការអនុវត្តក្របខណ្ឌគោលនយោបាយជាតិផលិតភាពសេដ្ឋកិច្ចកម្ពុជា ប្រកបដោយប្រសិទ្ធផល ប្រសិទ្ធភាព និងទាន់ពេល, **គ.ជ.ផ.ក.** បង្កើតក្រុមការងារបច្ចេកទេសចំនួន ៤ រួមមាន ក្រុមការងារបច្ចេកទេសផ្នែកការអប់រំ និង ការបណ្តុះបណ្តាលបច្ចេកទេសវិជ្ជាជីវៈ, ក្រុមការងារបច្ចេកទេសផ្នែកបច្ចេកវិទ្យា និងនវានុវត្តន៍, ក្រុមការងារបច្ចេកទេសផ្នែកស្ថាប័នសាធារណៈ និងក្រុមការងារបច្ចេកទេសផ្នែកហេដ្ឋារចនាសម្ព័ន្ធ ។ ក្រុមការងារបច្ចេកទេសទាំង៤នេះ ត្រូវបំពេញមុខងារជាសេនាធិការផ្នែកបច្ចេកទេស និងរដ្ឋបាល ព្រមទាំងជាដៃគូសហប្រតិបត្តិការជាមួយអគ្គលេខាធិការដ្ឋាន **គ.ជ.ផ.ក.** ដើម្បីគាំទ្រនិងជំរុញការអនុវត្តវិធានការគោលនយោបាយនេះ ។

ក្រុមការងារបច្ចេកទេសនីមួយៗ ត្រូវស្ថិតក្រោមការដឹកនាំរបស់ក្រសួងជំនាញលើវិស័យពាក់ព័ន្ធ និងមានសមាសភាពមកពីក្រសួង-ស្ថាប័ន ដែលជាសមាជិក **គ.ជ.ផ.ក.** និងក្រសួង-ស្ថាប័នពាក់ព័ន្ធមួយចំនួនទៀត ។ ការរៀបចំនិងការប្រព្រឹត្តទៅនិងសមាសភាពនៃក្រុមការងារបច្ចេកទេស នឹងត្រូវកំណត់ដោយសេចក្តីសម្រេចរបស់រាជរដ្ឋាភិបាល តាមសំណើរបស់ប្រធាន **គ.ជ.ផ.ក.** ។

ក្នុងក្របខណ្ឌអនុវត្តវិធានការគោលនយោបាយនៅក្នុងតារាងម៉ាទ្រីស ដែលជាឧបសម្ព័ន្ធនៃក្របខណ្ឌគោលនយោបាយនេះ, រាជរដ្ឋាភិបាល បែងចែកការទទួលខុសត្រូវជា ២កម្រិត គឺស្ថាប័ន

ទទួលបន្ទុកនិងស្ថាប័នគាំទ្រ ។ ស្ថាប័នទទួលបន្ទុកមានតួនាទីនាំមុខ ដឹកនាំ សម្របសម្រួល និងសហការជាមួយស្ថាប័នគាំទ្រ ដើម្បីធានាបានប្រសិទ្ធភាព ប្រសិទ្ធផល និងភាពប្រទាក់ក្រឡាលើការអនុវត្តវិធានការគោលនយោបាយ ។ ចំណែកឯស្ថាប័នគាំទ្រ ត្រូវផ្តល់កិច្ចសហប្រតិបត្តិការពេញលេញប្រកបដោយស្មារតីបុរេសកម្ម ជូនស្ថាប័នទទួលបន្ទុក ។

## ៤.២. យន្តការតាមដាន និង វាយតម្លៃលើការអនុវត្តក្របខណ្ឌគោលនយោបាយ

ក្នុងការតាមដាននិងវាយតម្លៃលើវឌ្ឍនភាព សមិទ្ធផល និងបញ្ហាប្រឈមក្នុងការអនុវត្តក្របខណ្ឌគោលនយោបាយជាតិផលិតភាពសេដ្ឋកិច្ចកម្ពុជា, **គ.ជ.ផ.ក.** ត្រូវបង្កើតយន្តការតាមដាននិងវាយតម្លៃសម្រាប់វាស់វែងលើប្រសិទ្ធផលនិងប្រសិទ្ធភាពនៃប្រតិបត្តិការ សមិទ្ធកម្ម សមិទ្ធផល និងវិបាកនៃការអនុវត្តក្របខណ្ឌគោលនយោបាយនេះ ។ យន្តការតាមដាននិងវាយតម្លៃនេះ មាន ២ កម្រិត គឺស្ថាប័នទទួលបន្ទុកនិងស្ថាប័នគាំទ្រ ផ្អែកតាមដែនសមត្ថកិច្ច បទពិសោធ និងឯកទេសកម្មរបស់ខ្លួន ។ វិធីសាស្ត្រនេះជួយសម្របសម្រួលដល់កិច្ចសហប្រតិបត្តិការ, កិច្ចទំនាក់ទំនងអន្តរក្រសួង-ស្ថាប័ន, ការចែករំលែកទិន្នន័យនិងព័ត៌មាន, អន្តរាគមន៍រួមគ្នា និងមានអំណោយផល ដូចជា ប្រសិទ្ធភាពក្នុងការបំពេញការងារ, ប្រសិទ្ធផលក្នុងការអនុវត្តក្របខណ្ឌគោលនយោបាយនិងការវាយតម្លៃសមិទ្ធផល និងវិបាកនៃការអនុវត្តគោលយោបាយនេះ ។ ក្នុងករណីចាំបាច់, **គ.ជ.ផ.ក.** អាចរៀបចំឱ្យមានការវាយតម្លៃឯករាជ្យ ដោយសហការជាមួយដៃគូអភិវឌ្ឍន៍និងវិស័យឯកជនដែលពាក់ព័ន្ធ ។ ដ្យាក្រាមខាងក្រោម បង្ហាញពីដំណើរការនៃការតាមដាននិងវាយតម្លៃ ។

**រូបភាពទី ៣៖ ដ្យាក្រាមនៃដំណើរការតាមដាន និង វាយតម្លៃ**



### ៤.២.១. ការរៀបចំផែនការសកម្មភាព និង សូចនាករ

អគ្គលេខាធិការដ្ឋាន **គ.ជ.ផ.ក.** នឹងដឹកនាំ សម្របសម្រួល និងធ្វើសហប្រតិបត្តិការជាមួយក្រុមការងារបច្ចេកទេសទាំង៤ ក្នុងការរៀបចំផែនការសកម្មភាព កម្មវិធី និងសូចនាករ តាមការិយបរិច្ឆេទស្របជាមួយវិធានការគោលនយោបាយ និងក្របខណ្ឌពេលវេលាដូចបានកំណត់នៅក្នុងតារាងម៉ាទ្រីសដែលជាឧបសម្ព័ន្ធនៃក្របខណ្ឌគោលនយោបាយនេះ ។ ការរៀបចំនេះ បង្ហាញអំពីវឌ្ឍនភាព សមិទ្ធកម្ម សមិទ្ធផល និងវិបាកផ្អែកលើគោលការណ៍ផលិតភាព ។ បន្ទាប់ពីពិនិត្យ ពិភាក្សា និងសម្រេចពីក្រុមការងារបច្ចេកទេស, ផែនការនេះនឹងត្រូវដាក់ជូន **គ.ជ.ផ.ក.** ដើម្បីពិនិត្យនិងសម្រេចដាក់ឱ្យអនុវត្តជាផ្លូវការដែលត្រូវរៀបចំក្នុងរយៈពេល **៣ ឆ្នាំម្តង** ។

### ៤.២.២. ការតាមដាន

ការតាមដាន គឺជាដំណើរការដើម្បីតម្រង់ទិសការអនុវត្តក្របខណ្ឌគោលនយោបាយឱ្យបានត្រឹមត្រូវស្របតាមផែនការដែលបានគ្រោងទុក តាមរយៈការសង្កេតនិងការត្រួតពិនិត្យជាប្រចាំលើសកម្មភាព គម្រោងនិងកម្មវិធីលើកកម្ពស់ផលិតភាពរបស់ក្រសួង-ស្ថាប័នពាក់ព័ន្ធ ។ ដើម្បីសម្រេចបានការតាមដានប្រកបដោយប្រសិទ្ធភាពនិងការអនុវត្តចំទិសដៅ, អគ្គលេខាធិការដ្ឋាន **គ.ជ.ផ.ក.** និងក្រសួង-ស្ថាប័នពាក់ព័ន្ធត្រូវសហប្រតិបត្តិការឱ្យបានជិតស្និទ្ធ តាមយន្តការការងារចាប់ពីការរៀបចំផែនការរហូតដល់ការអនុវត្តនៅគ្រប់ដំណាក់កាល ។

#### ការប្រជុំតាមដាន និង ត្រួតពិនិត្យ

អគ្គលេខាធិការដ្ឋាន **គ.ជ.ផ.ក.** ត្រូវដឹកនាំនិងសម្របសម្រួលកិច្ចប្រជុំកម្រិតបច្ចេកទេសជាមួយក្រសួង-ស្ថាប័នពាក់ព័ន្ធ ក្នុងរយៈពេល **៦ ខែម្តង** ឬ ក្នុងរយៈពេលណាមួយតាមការចាំបាច់ ដើម្បីពិនិត្យលើការអនុវត្តផែនការសកម្មភាពនិងសូចនាករដែលបានដាក់ចេញ ។ អគ្គលេខាធិការដ្ឋាន **គ.ជ.ផ.ក.** ត្រូវបូកសរុបរបាយការណ៍សម្រាប់ដាក់ជូន **គ.ជ.ផ.ក.** ដើម្បីជាមូលដ្ឋានសម្រាប់កិច្ចប្រជុំប្រចាំឆ្នាំពិនិត្យពិភាក្សានិងសម្រេច ។ ចំណែកឯស្ថាប័នទទួលបន្ទុកត្រូវដឹកនាំនិងសម្របសម្រួលកិច្ចប្រជុំជាមួយស្ថាប័នគាំទ្រដើម្បីធានាបានសង្គតិភាព និងភាពប្រទាក់ក្រឡានៃព័ត៌មាននិងទិន្នន័យលើវឌ្ឍនភាពនិងសមិទ្ធកម្ម ។ **គ.ជ.ផ.ក.** ត្រូវរៀបចំកិច្ចប្រជុំ **យ៉ាងតិច ១ដង ក្នុងមួយឆ្នាំ** ដើម្បីពិនិត្យលើវឌ្ឍនភាព សមិទ្ធកម្ម និងដោះស្រាយបញ្ហាប្រឈមនានា ។ លទ្ធផលនៃកិច្ចប្រជុំនេះ គឺជាកម្មវត្ថុក្នុងការកែសម្រួលសូចនាករ និងដំណើរការអនុវត្តការងារតាមការចាំបាច់ ។

### ការរៀបចំប្លង់គំរូស្តង់ដារនៃរបាយការណ៍សមិទ្ធកម្ម

អគ្គលេខាធិការដ្ឋាន **គ.ជ.ផ.ក.** ត្រូវដឹកនាំនិងសហការជាមួយក្រុមការងារបច្ចេកទេសទាំង៤ ដើម្បីបង្កើតប្លង់គំរូស្តង់ដារ (template) សម្រាប់របាយការណ៍សមិទ្ធកម្មរបស់ក្រសួង-ស្ថាប័នពាក់ព័ន្ធ ។ ស្ថាប័នទទួលបន្ទុកត្រូវទទួលខុសត្រូវរៀបចំរបាយការណ៍វឌ្ឍនភាព សម្រាប់រយៈពេល **៦ ខែម្តង** និងរបាយការណ៍សមិទ្ធកម្ម **១ ឆ្នាំម្តង** ដោយមានការចូលរួមពីស្ថាប័នគាំទ្រ សម្រាប់ដាក់ជូនអគ្គលេខាធិការដ្ឋាន **គ.ជ.ផ.ក.** ពិនិត្យនិងធ្វើរបាយការណ៍ ជូន **គ.ជ.ផ.ក.** ។ **គ.ជ.ផ.ក.** នឹងត្រួតពិនិត្យលើរបាយការណ៍នេះ ដើម្បីដាក់ចេញវិធានការសម្រាប់ដោះស្រាយបញ្ហាប្រឈមឱ្យបានទាន់ពេល ។

### ៤.២.៣. ក្របខណ្ឌវាយតម្លៃ

ក្របខណ្ឌវាយតម្លៃ មានសារៈសំខាន់សម្រាប់ដំណើរការវាស់វែងនិងវាយតម្លៃលើសមិទ្ធកម្ម សមិទ្ធផល និងវិបាកនៃក្របខណ្ឌគោលនយោបាយនេះ ។ **គ.ជ.ផ.ក.** បង្កើតក្របខណ្ឌវាយតម្លៃសម្រាប់វិភាគនិងយល់ដឹងអំពីវឌ្ឍនភាពនិងបញ្ហាប្រឈមនានា ក្នុងការអនុវត្តក្របខណ្ឌគោលនយោបាយជាតិផលិតភាពសេដ្ឋកិច្ចកម្ពុជាក្នុងរយៈពេល **៣ ឆ្នាំម្តង** ។

នីតិវិធីបង្កើតក្របខណ្ឌវាយតម្លៃនៃក្របខណ្ឌគោលនយោបាយជាតិផលិតភាពសេដ្ឋកិច្ចកម្ពុជា មាន ៣ ដំណាក់កាល ។ ដំណាក់កាលទី១ គឺការពិគ្រោះយោបល់, ដំណាក់កាលទី២ គឺការធ្វើសុពលកម្ម និងដំណាក់កាលទី៣ គឺកិច្ចប្រជុំលើរបាយការណ៍វាយតម្លៃ ។

- **ការពិគ្រោះយោបល់÷** ក្នុងការបង្កើតក្របខណ្ឌវាយតម្លៃ, អគ្គលេខាធិការដ្ឋាន **គ.ជ.ផ.ក.** នឹងរៀបចំកិច្ចប្រជុំពិភាក្សា និង/ឬ សិក្ខាសាលាប្រឹក្សាយោបល់លើវិធីសាស្ត្រ យុទ្ធសាស្ត្រ គោលដៅ និងមុខងារនៃក្របខណ្ឌវាយតម្លៃជាមួយក្រសួង-ស្ថាប័នពាក់ព័ន្ធ និងក្រុមការងារបច្ចេកទេសជំនាញ ដើម្បីប្រមូលធាតុចូលនិងមតិយោបល់ ។

- **ការធ្វើសុពលកម្ម÷** អគ្គលេខាធិការដ្ឋាន **គ.ជ.ផ.ក.** នឹងដាក់របាយការណ៍និងអនុសាសន៍ដែលទទួលបានពីការពិគ្រោះយោបល់ជូន **គ.ជ.ផ.ក.** ដើម្បីពិនិត្យ សម្រេច និងផ្តល់អនុសាសន៍ ដើម្បីកែលម្អក្របខណ្ឌវាយតម្លៃនេះ ។

- **កិច្ចប្រជុំលើរបាយការណ៍វាយតម្លៃ÷** **គ.ជ.ផ.ក.** នឹងដឹកនាំកិច្ចប្រជុំពិភាក្សា ត្រួតពិនិត្យ និសម្រេចលើលទ្ធផលនៃការវាយតម្លៃលើការអនុវត្តក្របខណ្ឌគោលនយោបាយនេះ, ចង្អុលបង្ហាញទិសដៅនិងដាក់ចេញវិធានការគោលនយោបាយសម្រាប់ជំរុញកំណើនផលិតភាព ឬ ដោះស្រាយបញ្ហាប្រឈមនៃការអនុវត្តក្របខណ្ឌគោលនយោបាយជាតិផលិតភាពសេដ្ឋកិច្ចកម្ពុជា ។

### ៤.២.៤. ការវាស់វែង និង ផ្សព្វផ្សាយអំពីផលិតភាពសេដ្ឋកិច្ច

ការវាស់វែងលើកំណើនផលិតភាព ជួយឱ្យកម្ពុជាអនុវត្តយុទ្ធសាស្ត្រអន្តរាគមន៍សម្រាប់ជំរុញកំណើនផលិតភាពសេដ្ឋកិច្ចប្រកបដោយប្រសិទ្ធភាពខ្ពស់ ។ ដើម្បីសម្រេចបានគោលបំណងនេះ, **ប្រព័ន្ធវាស់វែងផលិតភាពសេដ្ឋកិច្ចជាតិ** និង **យន្តការចែករំលែកព័ត៌មានស្ដីពីផលិតភាពសេដ្ឋកិច្ច** នឹងត្រូវបានបង្កើតឡើងសម្រាប់គាំទ្រការអនុវត្តក្របខណ្ឌគោលនយោបាយជាតិផលិតភាពសេដ្ឋកិច្ចកម្ពុជា ។ លទ្ធផលនៃការវាស់វែងនឹងត្រូវធ្វើការផ្សព្វផ្សាយ ដើម្បីលើកកម្ពស់ការយល់ដឹងនិងជំរុញឱ្យប្រជាជនទទួលយក និងបន្សាំខ្លួនជាមួយគោលការណ៍ផលិតភាពក្នុងការបំពេញការងារប្រចាំថ្ងៃ ។ ប្រព័ន្ធវាស់វែងនេះ រួមចំណែកដល់ការយល់ដឹងពីស្ថានភាពនៃផលិតភាពសេដ្ឋកិច្ចកម្ពុជា និងផ្ដល់នូវទិន្នន័យចម្រុះវិស័យជាភស្តុតាងបែបវិទ្យាសាស្ត្រ ដើម្បីគាំទ្រការធ្វើសេចក្តីសម្រេចនិងការរៀបចំយុទ្ធសាស្ត្រអន្តរាគមន៍នានា ។ **គ.ជ.ផ.ក.** នឹងបង្កើតឯកសារទស្សនាទាននិងយុទ្ធសាស្ត្រ សម្រាប់អនុវត្តប្រព័ន្ធវាស់វែងផលិតភាពសេដ្ឋកិច្ចជាតិនិងយន្តការចែករំលែកព័ត៌មានស្ដីពីផលិតភាពសេដ្ឋកិច្ចដាច់ដោយឡែកពីគ្នា ។

## ៥. សេចក្ដីសន្និដ្ឋាន

ផ្អែកលើចក្ខុវិស័យរយៈពេលវែងក្នុងការកសាងនិងលើកកម្ពស់ផលិតភាពសេដ្ឋកិច្ចជាតិ សំដៅជំរុញសន្ទុះកំណើនសេដ្ឋកិច្ចកម្ពុជា តាមរយៈកំណើនផលិតភាពសេដ្ឋកិច្ចនិងលើកកម្ពស់សុខុមាលភាពសង្គម ដើម្បីរួមចំណែកដល់ការសម្រេចបានចក្ខុវិស័យកម្ពុជាឆ្នាំ២០៥០, ក្របខណ្ឌគោលនយោបាយជាតិផលិតភាពសេដ្ឋកិច្ចកម្ពុជា ២០២២-២០៣៥ ត្រូវបានរៀបចំឡើងដោយមានចក្ខុវិស័យ គោលបំណង គោលដៅ យុទ្ធសាស្ត្រអាទិភាព គោលការណ៍អនុវត្ត និងវិធានការគោលនយោបាយគន្លឹះ ច្បាស់លាស់ជាជំហានៗនិងមានភាពប្រទាក់ក្រឡា សម្រាប់ជាផែនទីបង្ហាញផ្លូវក្នុងការជំរុញកំណើនផលិតភាពសេដ្ឋកិច្ចដើម្បីបង្កើនភាពប្រកួតប្រជែងយកឈ្នះរបស់កម្ពុជា ។ ផ្អែកលើបទពិសោធនិងឧត្តមានុវត្តន៍នៃបណ្ដាប្រទេសមួយចំនួនក្នុងពិភពលោក ព្រមទាំងដើម្បីជំរុញផលិតភាពសេដ្ឋកិច្ច ប្រកបដោយប្រសិទ្ធភាពប្រសិទ្ធផល ចីរភាព និងបរិយាបន្ន, រាជរដ្ឋាភិបាលកំណត់យកគោលការណ៍ អនុវត្តជាមូលដ្ឋានចំនួន ៣ រួមមាន កិច្ចសហប្រតិបត្តិការនៃគ្រប់តួអង្គសេដ្ឋកិច្ច ការបែងចែកដោយសមធម៌នូវផលប្រយោជន៍នៃផលិតភាព និងការបង្កើតការងារសម្រាប់រយៈពេលវែង ។

រាជរដ្ឋាភិបាលកម្ពុជា បានដាក់ចេញក្របខណ្ឌគោលនយោបាយជាតិផលិតភាពសេដ្ឋកិច្ច ក្នុងគោលបំណងជំរុញកំណើនសេដ្ឋកិច្ចនិងបង្កើនប្រាក់ចំណូលក្នុងប្រជាជនម្នាក់ៗ សំដៅបង្កើនសន្តិសុខសេដ្ឋកិច្ចនិងសុខុមាលភាពសង្គម ប្រកបដោយចីរភាពនិងបរិយាបន្ន ។ គោលបំណងនៃក្របខណ្ឌគោលនយោបាយនេះសម្រេចបានតាមរយៈគោលដៅយុទ្ធសាស្ត្រអាទិភាពចំនួន ៤ និងវិធានការគោលនយោបាយសរុប

ចំនួន ៨៤ ដោយត្រូវប្រើប្រាស់ពេលវេលាសរុបចំនួន ១៤ឆ្នាំ ។ ជាមួយគ្នានេះ រាជរដ្ឋាភិបាលបានបង្កើត គណៈកម្មាធិការជាតិផលិតភាពសេដ្ឋកិច្ចកម្ពុជា ដែលមានរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ជាប្រធាន និងមានសមាសភាពពីថ្នាក់ដឹកនាំក្រសួង-ស្ថាប័នពាក់ព័ន្ធ ដើម្បីដឹកនាំនិងសម្របសម្រួលអនុវត្ត ព្រមទាំង តាមដាន ត្រួតពិនិត្យជាប្រចាំ និងវាយតម្លៃវិធានការទាំងអស់ដែលបានដាក់ចេញក្នុងក្របខណ្ឌ គោលនយោបាយនេះ សំដៅធានាបាននូវការអនុវត្តប្រកបដោយការចូលរួមពីគ្រប់ក្រសួង-ស្ថាប័ន ពាក់ព័ន្ធ ការទទួលខុសត្រូវ ស័ក្តិសិទ្ធភាព គណនេយ្យភាព និងភាពជោគជ័យខ្ពស់ ។ ជារួម ក្របខណ្ឌ គោលនយោបាយនេះមានយន្តការអនុវត្តច្បាស់លាស់ និងមានថ្នាក់ដឹកនាំកំពូលរបស់ស្ថាប័នដឹកនាំ និងសម្របសម្រួល ដើម្បីធានាបានជោគជ័យខ្ពស់ក្នុងការអនុវត្តជាក់ស្តែង ។ ក្របខណ្ឌគោលនយោបាយនេះ ត្រូវចាត់ទុកថាជា **ឯកសាររស់** ដែលអាចនឹងត្រូវ កែសម្រួលជាយថាហេតុ ដើម្បីសម្របទៅនឹងបរិការណ៍ ជាក់ស្តែងនិងការវិវត្តសង្គម-សេដ្ឋកិច្ច ទាំងនៅក្នុងប្រទេស តំបន់ និងសកលលោក ។

## ឧបសម្ព័ន្ធ ៖ តារាងម៉ាទ្រីសវិធានការគោលនយោបាយ

| ល.រ | អនុកត្តាកំណត់ផលិតភាព | វិធានការគោលនយោបាយគន្លឹះ | ស្ថាប័នទទួលបន្ទុក | ស្ថាប័នគាំទ្រ | ក្របខណ្ឌពេលវេលា |
|---|---|---|---|---|---|
| **វិធានការគោលនយោបាយទី ១៖ ការកែលម្អការអប់រំ និង ការបណ្តុះបណ្តាលបច្ចេកទេសវិជ្ជាជីវៈ៖ អភិវឌ្ឍមូលធនមនុស្ស និង បង្កើនផលិតភាពកម្លាំងពលកម្ម** | | | | | |
| ១ | **(១). ការអភិវឌ្ឍមូលធនមនុស្ស**៖ការអភិវឌ្ឍទេពកោសល្យឆ្ពោះទៅសម្រេចបានចំណេះដឹងដែលមានតម្លៃខ្ពស់ | កែលម្អកម្មវិធីអប់រំ ដោយផ្តោតលើការកសាងនិងពង្រឹងសមត្ថភាពវិភាគស៊ីជម្រៅនិងសមត្ថភាពលើជំនាញទន់ ព្រមទាំងលើកកម្ពស់ចំណេះដឹងផ្នែកវិទ្យាសាស្ត្រអនុវត្តន៍ | ក្រសួងអប់រំ យុវជន និងកីឡា | - គណៈកម្មាធិការជាតិផលិតភាពសេដ្ឋកិច្ចកម្ពុជា<br>- ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ<br>- ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍<br>- ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍<br>- ក្រសួង-ស្ថាប័នពាក់ព័ន្ធ | ២០២២-២០២៧ |
| ២ | | រៀបចំយន្តការសិក្សានិងវាយតម្លៃ ព្រមទាំងពិគ្រោះយោបល់ជាមួយសហគ្រាសនិងគ្រឹះស្ថានអប់រំ ទាំងសាធារណៈនិងឯកជនក្នុងគោលដៅធានាឱ្យបានសង្គតិភាពនៃកម្មវិធីអប់រំជាមួយនឹងកម្មវិធីបណ្តុះបណ្តាលបច្ចេកទេសវិជ្ជាជីវៈ ដើម្បីបំពេញតម្រូវការនៃការអភិវឌ្ឍសេដ្ឋកិច្ចនិងទីផ្សារជាក់ស្តែង | ក្រសួងអប់រំ យុវជន និងកីឡា | - ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ<br>- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ<br>- ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍<br>- ក្រសួងពាណិជ្ជកម្ម<br>- ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍<br>- ក្រសួង-ស្ថាប័នពាក់ព័ន្ធ | ២០២២-២០២៧ |
| ៣ | | រៀបចំយុទ្ធសាស្ត្រកាត់បន្ថយការបោះបង់ការសិក្សានៅកម្រិតមធ្យមសិក្សានិងលើកទឹកចិត្តឱ្យសិស្សានុសិស្សបន្តសិក្សារហូតដល់កម្រិតមធ្យមសិក្សាទុតិយភូមិ ឬ ខ្ពស់ជាងនេះ | ក្រសួងអប់រំ យុវជន និងកីឡា | - ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ<br>- ក្រសួងសុខាភិបាល<br>- ក្រសួងមហាផ្ទៃ | ២០២២-២០២៧ |

| | | | | | |
|---|---|---|---|---|---|
| | | | | - ក្រសួង-ស្ថាប័នពាក់ព័ន្ធ | |
| ៤ | | រៀបចំយន្តការសិក្សា តាមដាន និងវាយតម្លៃលើវឌ្ឍនភាពនិងគុណភាពវិស័យអប់រំ ដោយផ្តោតលើសមិទ្ធផលនិងវិបាកនៃការវិនិយោគក្នុងវិស័យនេះ | ក្រសួងអប់រំ យុវជន និងកីឡា | - ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ<br>- ក្រសួងផែនការ<br>- គណៈកម្មាធិការជាតិផលិតភាពសេដ្ឋកិច្ចកម្ពុជា | ២០២២-២០២៧ |
| ៥ | | ពន្លឿនការរៀបចំយុទ្ធសាស្ត្រពង្រឹងសមត្ថភាពក្នុងការទទួលយកការបន្សាំ ការធ្វើនវានុវត្តន៍ និងការធ្វើបរិវត្តកម្មនៅក្នុងកម្មវិធីអប់រំផ្នែកវិទ្យាសាស្ត្រ បច្ចេកវិទ្យា វិស្វកម្ម និងគណិតវិទ្យា | ក្រសួងអប់រំ យុវជន និងកីឡា | - ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ<br>- ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍<br>- ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍<br>- ក្រសួង-ស្ថាប័នពាក់ព័ន្ធ | ២០២២-២០៣០ |
| ៦ | | បញ្ចូលទស្សនាទានផលិតភាពនិងវប្បធម៌ផលិតភាពនៅក្នុងកម្មវិធីអប់រំ ព្រមទាំងផ្សព្វផ្សាយអំពីសារៈសំខាន់នៃការបង្កើតផលិតភាពក្នុងការសិក្សានិងការងារ | ក្រសួងអប់រំ យុវជន និងកីឡា | - ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ<br>- គណៈកម្មាធិការជាតិផលិតភាពសេដ្ឋកិច្ចកម្ពុជា<br>- មជ្ឈមណ្ឌលផលិតភាពជាតិកម្ពុជា<br>- ក្រសួង-ស្ថាប័នពាក់ព័ន្ធ | ២០២២-២០៣៥ |
| ៧ | | រៀបចំយន្តការនិងគោលការណ៍ណែនាំ បង្កើតបរិយាកាសសិក្សាដែលមានអំណោយផលនិងបង្កើនប្រសិទ្ធភាពក្នុងការផ្សព្វផ្សាយ សម្រាប់ការបញ្ជ្រាបគុណតម្លៃនៃការសិក្សានិងការបណ្តុះស្មារតីភាពជាម្ចាស់ ដើម្បីទាក់ទាញនិងលើកទឹកចិត្តឱ្យមានការចូលរួមបណ្តុះវប្បធម៌នៃការអប់រំបណ្តុះបណ្តាលឱ្យកាន់តែប្រសើរឡើង | ក្រសួងអប់រំ យុវជន និងកីឡា | - ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ<br>- ក្រសួងព័ត៌មាន<br>- ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ | ២០២២-២០៣០ |

| | | | | | |
|---|---|---|---|---|---|
| ៨ | | រៀបចំនិងដាក់ឱ្យអនុវត្តផែនការយុទ្ធសាស្ត្រអភិវឌ្ឍមូលធនមនុស្ស ក្នុងបរិបទបដិវត្តន៍ឧស្សាហកម្មទី៤ និងក្របខណ្ឌប្រព័ន្ធអេកូឡូស៊ី នៃការអភិវឌ្ឍមូលធនមនុស្ស | ក្រសួងអប់រំ យុវជន និងកីឡា | - ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍<br>- ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ<br>- ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍<br>- ក្រសួង-ស្ថាប័នពាក់ព័ន្ធ | ២០២២-២០២៧ |
| ៩ | | រៀបចំផែនការពង្រឹងនិងពង្រីកវិសាលភាពនៃការអប់រំនៅតាមទីជនបទនិងតំបន់ដាច់ស្រយាល | ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | - ក្រសួងអប់រំ យុវជន និងកីឡា<br>- ក្រសួងអភិវឌ្ឍន៍ជនបទ<br>- គណៈកម្មាធិការជាតិផលិតភាពសេដ្ឋកិច្ចកម្ពុជា | ២០២២-២០៣៥ |
| ១០ | **(២). ការអភិវឌ្ឍមូលធនមនុស្សកម្រិតឧត្តមសិក្សា÷** ការលើកកម្ពស់ចំណេះដឹង និងជំនាញដែលមានតម្លៃបន្ថែមខ្ពស់ | រៀបចំផែនការនិងយុទ្ធសាស្ត្រលើកទឹកចិត្តនិងទាក់ទាញឥស្សរជន និងអ្នកស្រាវជ្រាវជាន់ខ្ពស់ ដែលមានគុណវុឌ្ឍិនិងចំណេះដឹងអប់រំខ្ពស់ ព្រមទាំងមានបទពិសោធការងារជាក់ស្តែង ដើម្បីចូលរួមក្នុងការបណ្តុះបណ្តាលនៅតាមគ្រឹះស្ថានឧត្តមសិក្សា | ក្រសួងអប់រំ យុវជន និងកីឡា | - ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ<br>- ក្រសួង-ស្ថាប័នពាក់ព័ន្ធ | ២០២២-២០២៧ |
| ១១ | | រៀបចំផែនការវិនិយោគបន្ថែមដល់គ្រឹះស្ថានឧត្តមសិក្សា ដែលមានគុណភាពខ្ពស់ក្នុងការបណ្តុះបណ្តាលជំនាញសមស្របតាមតម្រូវការទីផ្សារ | ក្រសួងអប់រំ យុវជន និងកីឡា | - គណៈកម្មាធិការជាតិផលិតភាពសេដ្ឋកិច្ចកម្ពុជា<br>- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ<br>- ក្រសួង-ស្ថាប័នពាក់ព័ន្ធ | ២០២២-២០៣០ |
| ១២ | | ធ្វើទំនើបកម្មហេដ្ឋារចនាសម្ព័ន្ធពាក់ព័ន្ធនឹងការបណ្តុះបណ្តាលមុខវិជ្ជាវិទ្យាសាស្ត្រអនុវត្តន៍និងបច្ចេកវិទ្យា នៅតាមគ្រឹះស្ថានឧត្តមសិក្សា | ក្រសួងអប់រំ យុវជន និងកីឡា | - ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ<br>- ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ<br>- ក្រសួង-ស្ថាប័នពាក់ព័ន្ធ | ២០២២-២០៣៥ |
| ១៣ | | លើកទឹកចិត្តឱ្យគ្រឹះស្ថានឧត្តមសិក្សាលើកកម្ពស់ការផ្តល់ការបណ្តុះបណ្តាលមុខវិជ្ជាវិទ្យាសាស្ត្រអនុវត្តន៍ បច្ចេកវិទ្យា និងសេដ្ឋកិច្ចបៃតងសមស្របតាមតម្រូវការនៃទីផ្សារការងារជាក់ស្តែង | ក្រសួងអប់រំ យុវជន និងកីឡា | - ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ<br>- ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ<br>- ក្រសួង-ស្ថាប័នពាក់ព័ន្ធ | ២០២២-២០២៧ |

| | | | | | |
|---|---|---|---|---|---|
| ១៤ | | សិក្សានិងពិនិត្យលើលទ្ធភាពបង្កើនកម្មវិធីអាហារូបករណ៍សម្រាប់ជំរុញការកសាងជំនាញដែលជាតម្រូវការទីផ្សារនិងជាទិសដៅអភិវឌ្ឍសង្គម-សេដ្ឋកិច្ចរបស់រាជរដ្ឋាភិបាល | ក្រសួងអប់រំ យុវជន និងកីឡា | - ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ<br>- ក្រសួង-ស្ថាប័នពាក់ព័ន្ធ | ២០២២-២០២៧ |
| ១៥ | | រៀបចំយុទ្ធនាការជំរុញឱ្យសិស្សានុសិស្សចាប់យកជំនាញក្នុងវិទ្យាសាស្ត្រអនុវត្តន៍នៅកម្រិតឧត្តមសិក្សាសមស្របនឹងតម្រូវការទីផ្សារនិងទិសដៅនៃការអភិវឌ្ឍសេដ្ឋកិច្ចជាតិ | ក្រសួងអប់រំ យុវជន និងកីឡា | - ក្រសួងពត៌មាន<br>- ក្រសួង-ស្ថាប័នពាក់ព័ន្ធ | ២០២២-២០២៧ |
| ១៦ | | បង្កើតឱ្យមានកម្មវិធីប្រឹក្សាយោបល់ដល់សិស្សានុសិស្សក្នុងការជ្រើសរើសអាជីពនិងមុខជំនាញនៅតាមវិទ្យាល័យ និងគ្រឹះស្ថានឧត្តមសិក្សា | ក្រសួងអប់រំ យុវជន និងកីឡា | ក្រសួង-ស្ថាប័នពាក់ព័ន្ធ | ២០២២-២០២៧ |
| ១៧ | | រៀបចំផែនការធ្វើបច្ចុប្បន្នកម្មលើកម្មវិធីបណ្តុះបណ្តាលបច្ចេកទេស និងវិទ្យាសាស្ត្រ ដែលបម្រើឱ្យវិស័យឧស្សាហកម្មនិងវិស័យដទៃទៀត ដែលមានតម្លៃបន្ថែមខ្ពស់ ស្របតាមការប្រែប្រួលនៃទីផ្សារការងារក្នុងស្រុកនិងទិសដៅនៃការអភិវឌ្ឍវិស័យឧស្សាហកម្មជាតិ | ក្រសួងអប់រំ យុវជន និងកីឡា | - ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ<br>- ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ<br>- ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍<br>- ក្រសួង-ស្ថាប័នពាក់ព័ន្ធ | ២០២២-២០៣០ |
| ១៨ | | រៀបចំយន្តការនិងក្របខណ្ឌ ដើម្បីជំរុញនិងលើកកម្ពស់ការចូលរៀនក្នុងចំណោមនិស្សិតក្រីក្រ និស្សិតនារី និងនិស្សិតរស់នៅក្នុងតំបន់ដាច់ស្រយាល | ក្រសួងអប់រំ យុវជន និងកីឡា | - ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ<br>- ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ<br>- ក្រសួង-ស្ថាប័នពាក់ព័ន្ធ | ២០២២-២០២៧ |
| ១៩ | | រៀបចំយន្តការពិនិត្យ តាមដាន និងវាយតម្លៃ ដើម្បីធានាស្តង់ដារនៃកម្មវិធីសិក្សានៅកម្រិតឧត្តមសិក្សា សមស្របនឹងស្តង់ដារតំបន់និងអន្តរជាតិ | ក្រសួងអប់រំ យុវជន និងកីឡា | - ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ<br>- ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ<br>- ក្រសួង-ស្ថាប័នពាក់ព័ន្ធ | ២០២២-២០២៧ |

| | | | | | |
|---|---|---|---|---|---|
| ២០ | | រៀបចំយន្តការលើកទឹកចិត្តដល់គ្រឹះស្ថានឧត្តមសិក្សា សម្រាប់ជំរុញការអភិវឌ្ឍការស្រាវជ្រាវ បង្កើនសមត្ថភាពបង្រៀននិងស្រាវជ្រាវ ព្រមទាំងពង្រឹងការគ្រប់គ្រងនិងអភិបាលកិច្ចល្អនៃគ្រឹះស្ថានឧត្តមសិក្សា | ក្រសួងអប់រំ យុវជន និងកីឡា | - ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ<br>- ក្រសួង-ស្ថាប័នពាក់ព័ន្ធ | ២០២២-២០៣០ |
| ២១ | **(៣). ការបង្កើនផលិតភាពកម្លាំងពលកម្មជាតិ÷** ការអភិវឌ្ឍចំណេះដឹង ជំនាញវិជ្ជាជីវៈ និងឯកទេសកម្មដើម្បីសម្រេចបានការងារនិងមុខរបរដែលមានតម្លៃខ្ពស់ | រៀបចំផែនការជំរុញការបែងចែកកម្លាំងពលកម្មឱ្យសមស្របទៅតាមជំនាញវិជ្ជាជីវៈ និងឯកទេសកម្មដើម្បីសម្រេចបានប្រសិទ្ធផល ប្រសិទ្ធភាព និងផលិតភាពពលកម្មខ្ពស់ជាអតិបរមា | ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ | - ក្រសួងមុខងារសាធារណៈ<br>- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ<br>- ក្រសួងអប់រំ យុវជន និងកីឡា<br>- ក្រសួង-ស្ថាប័នពាក់ព័ន្ធ | ២០២២-២០២៤ |
| ២២ | | រៀបចំក្របខណ្ឌ ឬ យន្តការ ជំរុញនិងលើកទឹកចិត្តដល់សហគ្រាសនិងគ្រឹះស្ថានបណ្តុះបណ្តាលលើចំណេះដឹងបច្ចេកទេសនិងជំនាញវិជ្ជាជីវៈ ដូចជា រ៉ូបូទិក, ការវិភាគទិន្នន័យ, ការរចនានិងការអភិវឌ្ឍផលិតផល, វិស្វកម្មមេកានិក, ការសរសេរកម្មវិធី, បច្ចេកទេសគ្រប់គ្រងបណ្តាញកុំព្យូទ័រ, បច្ចេកទេស និងវិស្វកម្មយានយន្ត | ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ | - ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ<br>- ក្រសួងអប់រំ យុវជន និងកីឡា<br>- ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍<br>- ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ | ២០២២-២០៣៥ |
| ២៣ | | រៀបចំផែនការនិងយុទ្ធនាការលើកកម្ពស់ការគាំទ្រជាសាធារណៈលើការចាប់យកអាជីព ដែលផ្អែកលើជំនាញវិជ្ជាជីវៈនិងបច្ចេកទេស ដើម្បីលើកទឹកចិត្តឱ្យប្រជាជនទូទៅចូលរួមក្នុងកម្មវិធីបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈទាំងនេះ | ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ | - គណៈកម្មាធិការជាតិផលិតភាពសេដ្ឋកិច្ចកម្ពុជា<br>- ក្រសួងពត៌មាន<br>- ក្រសួង-ស្ថាប័នពាក់ព័ន្ធ | ២០២២-២០២៧ |
| ២៤ | | រៀបចំយុទ្ធសាស្ត្រលើកកម្ពស់គុណតម្លៃនិងពង្រឹងគុណភាព TVET សំដៅបង្កើនសមត្ថភាព និងផលិតភាពសេដ្ឋកិច្ចក្នុងសកម្មភាពដែលមានតម្លៃបន្ថែមខ្ពស់, | ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ | - ក្រសួងអប់រំ យុវជន និងកីឡា<br>- គណៈកម្មាធិការជាតិផលិតភាពសេដ្ឋកិច្ចកម្ពុជា<br>- ក្រសួង-ស្ថាប័នពាក់ព័ន្ធ | ២០២២-២០៣០ |

| | | | | | |
|---|---|---|---|---|---|
| ២៥ | | កំណត់យុទ្ធសាស្ត្រវិនិយោគនិងគ្រប់គ្រងលើការអភិវឌ្ឍកម្លាំងពលកម្មជាតិ ដើម្បីបង្កើនគុណភាពនិងសមត្ថភាពកម្លាំងពលកម្ម សម្រាប់ទ្រទ្រង់សេដ្ឋកិច្ចដោយផ្អែកលើជំនាញបច្ចេកទេសនិងវិជ្ជាជីវៈ | ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | - ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ<br>- ក្រសួងអប់រំ យុវជន និងកីឡា<br>- គណៈកម្មាធិការជាតិផលិតភាពសេដ្ឋកិច្ចកម្ពុជា<br>- ក្រសួង-ស្ថាប័នពាក់ព័ន្ធ | ២០២២-២០៣០ |
| ២៦ | | រៀបចំគោលការណ៍ណែនាំដល់រោងចក្រ សហគ្រាស និងក្រុមហ៊ុន ស្តីពីការផ្តល់បរិស្ថានការងារគាំទ្រផលិតភាពនិងសុវត្ថិភាពឧស្សាហកម្ម ដើម្បីជំរុញប្រសិទ្ធភាពផលិតកម្មនិងភាពប្រកួតប្រជែងខ្ពស់ | ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និង នវានុវត្តន៍ | - ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ<br>- គណៈកម្មាធិការជាតិផលិតភាពសេដ្ឋកិច្ចកម្ពុជា<br>- ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ<br>- ក្រសួងបរិស្ថាន<br>- ក្រសួងស្ថាប័ន-ពាក់ព័ន្ធ | ២០២២-២០២៤ |
| ២៧ | | រៀបចំគោលការណ៍ណែនាំដល់រោងចក្រ សហគ្រាស និងក្រុមហ៊ុន ស្តីពីការអភិវឌ្ឍចំណេះដឹង ជំនាញបច្ចេកទេសនិងវិជ្ជាជីវៈ និងឯកទេសកម្ម សម្រាប់កម្លាំងពលកម្មជាតិដើម្បីជំរុញការងារដែលផ្តល់តម្លៃបន្ថែមខ្ពស់ | ក្រសួងការងារ និង បណ្តុះបណ្តាលវិជ្ជាជីវៈ | - ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ<br>- គណៈកម្មាធិការជាតិផលិតភាពសេដ្ឋកិច្ចកម្ពុជា<br>- ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍<br>- ក្រសួង-ស្ថាប័នពាក់ព័ន្ធ | ២០២២-២០២៧ |
| ២៨ | | រៀបចំផែនការធ្វើសមាហរណកម្មពលករទេសន្តប្រវេសន៍ខ្មែរទៅក្នុងទីផ្សារការងារនិងសង្គម ដើម្បីកំណើនផលិតភាពសេដ្ឋកិច្ចកម្ពុជា | ក្រសួងការងារ និង បណ្តុះបណ្តាលវិជ្ជាជីវៈ | - ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ<br>- ក្រសួងមហាផ្ទៃ<br>- ក្រសួងផែនការ<br>- ក្រសួង-ស្ថាប័នពាក់ព័ន្ធ | ២០២២-២០២៧ |
| ២៩ | | រៀបចំយន្តការតាមដាននិងវាយតម្លៃ លើគុណភាពកម្មវិធីអប់រំ និងបណ្តុះបណ្តាលបច្ចេកទេសវិជ្ជាជីវៈ ផ្អែកលើគោលការណ៍ប្រសិទ្ធភាព ប្រសិទ្ធផល ភាពប្រកួតប្រជែង និងការបង្កើតគុណតម្លៃ | ក្រសួងការងារ និង បណ្តុះបណ្តាលវិជ្ជាជីវៈ | - ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ<br>- ក្រសួងអប់រំ យុវជន និងកីឡា<br>- ក្រសួងផែនការ | ២០២២-២០២៧ |

| | | | | | |
|---|---|---|---|---|---|
| | | | | - គណៈកម្មាធិការជាតិផលិតភាពសេដ្ឋកិច្ចកម្ពុជា | |
| ៣០ | | រៀបចំយន្តការសហប្រតិបត្តិការរវាងស្ថាប័នសាធារណៈ ស្ថាប័នឯកជន ស្ថាប័នស្រាវជ្រាវ និងគ្រឹះស្ថានសិក្សាក្នុងការតម្រង់ទិសកម្មវិធីអប់រំ បណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ សំដៅជំរុញល្បឿនពិពិធកម្មសេដ្ឋកិច្ចកម្ពុជា | គណៈកម្មាធិការជាតិផលិតភាពសេដ្ឋកិច្ចកម្ពុជា | - ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ<br>- ក្រសួងអប់រំ យុវជន និងកីឡា<br>- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ<br>- ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍<br>- ក្រសួងពាណិជ្ជកម្ម<br>- ក្រសួង-ស្ថាប័នពាក់ព័ន្ធ | ២០២២-២០៣៥ |
| **វិធានការគោលនយោបាយទី ២÷ ការជំរុញផ្នែកបច្ចេកវិទ្យា និង នវានុវត្តន៍÷ អភិវឌ្ឍជំនាញបច្ចេកវិទ្យា, គាំទ្រលើកទឹកចិត្តសហគ្រាសលើបច្ចេកវិទ្យា និង នវានុវត្តន៍ និង ពង្រឹងប្រសិទ្ធភាពនៃកិច្ចសហប្រតិបត្តិការរវាងស្ថាប័នគាំទ្របច្ចេកវិទ្យា និង នវានុវត្តន៍** | | | | | |
| ៣១ | **(១). អភិវឌ្ឍជំនាញបច្ចេកវិទ្យា ដើម្បីទ្រទ្រង់នវានុវត្តន៍ សំដៅបង្កើតគុណតម្លៃសម្រាប់សង្គម និងសេដ្ឋកិច្ច÷** ត្រៀមខ្លួនសម្រាប់ការធ្វើនវានុវត្តន៍សកម្មភាពនានា ក្នុងសង្គម-សេដ្ឋកិច្ច | រៀបចំនិងជំរុញការបណ្តុះបណ្តាលលើអក្ខរកម្មបច្ចេកវិទ្យានិងការប្រើប្រាស់បច្ចេកវិទ្យាឌីជីថលដើម្បីលើកកម្ពស់ប្រសិទ្ធភាព ប្រសិទ្ធផល និងផលិតភាពការងារ | ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ | - ក្រសួងមុខងារសាធារណៈ<br>- ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ<br>- ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍<br>- ក្រសួង-ស្ថាប័នពាក់ព័ន្ធ | ២០២២-២០៣៥ |
| ៣២ | | រៀបចំនិងកែលម្អកម្មវិធីបណ្តុះបណ្តាលចំណេះដឹងផ្នែកបច្ចេកវិទ្យា និងនវានុវត្តន៍ សំដៅសម្រួលដល់ការចាប់យកបច្ចេកវិទ្យាថ្មីនិងទាញយកផលប្រយោជន៍ពីបច្ចេកវិទ្យាទាំងនោះ | ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ | - ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ<br>- ក្រសួងអប់រំ យុវជន និងកីឡា<br>- ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ<br>- ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍<br>- ក្រសួងផែនការ<br>- ក្រសួង-ស្ថាប័នពាក់ព័ន្ធ | ២០២២-២០៣៥ |

| | | | | | |
|---|---|---|---|---|---|
| ៣៣ | | រៀបចំកម្មវិធីបណ្តុះបណ្តាលលើការបង្កើតកម្មវិធីឌីជីថល ទាំងក្នុងស្ថាប័នសាធារណៈនិងឯកជន | ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ | - ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ<br>- ក្រសួងអប់រំ យុវជន និងកីឡា<br>- ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ<br>- ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍<br>- ក្រសួង-ស្ថាប័នពាក់ព័ន្ធ | ២០២២-២០៣០ |
| ៣៤ | | រៀបចំផែនការពង្រឹង និងពង្រីកវិសាលភាពនិងគុណភាពនៃការអភិវឌ្ឍជំនាញក្នុងការផ្តល់សេវាកម្ម តាមប្រព័ន្ធឌីជីថលសម្រាប់វិស័យឯកជន | ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ | - ក្រសួងមុខងារសាធារណៈ<br>- ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ<br>- ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ | ២០២២-២០៣៥ |
| ៣៥ | **(២). គាំទ្រ និង លើកទឹកចិត្តសហគ្រាសលើបច្ចេកវិទ្យា និងនវានុវត្តន៍÷** បង្កើនសកម្មភាពនវានុវត្តន៍ក្នុងវិស័យឯកជន | បង្កើតក្របខណ្ឌជំរុញការវិនិយោគនិងការចូលរួមរបស់វិស័យឯកជនក្នុងគម្រោងវិនិយោគដែលមានបច្ចេកវិទ្យាទំនើប | ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | - ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍<br>- ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍<br>- ក្រសួងពាណិជ្ជកម្ម<br>- ក្រសួង-ស្ថាប័នពាក់ព័ន្ធ | ២០២២-២០៣០ |
| ៣៦ | | រៀបចំកម្មវិធីជំរុញឱ្យវិស័យឯកជនចូលរួមក្នុងសកម្មភាពសិក្សាស្រាវជ្រាវ ការអភិវឌ្ឍ និងនវានុវត្តន៍ ដើម្បីបង្កើនផលិតភាពសេដ្ឋកិច្ច | ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ | - ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ<br>- ក្រសួងអប់រំ យុវជន និងកីឡា<br>- ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ<br>- ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍<br>- ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | ២០២២-២០៣០ |

| | | | | | |
|---|---|---|---|---|---|
| | | | | - ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍<br>- ក្រសួងពាណិជ្ជកម្ម<br>- គណៈកម្មាធិការជាតិផលិតភាពសេដ្ឋកិច្ចកម្ពុជា<br>- ក្រសួង-ស្ថាប័នពាក់ព័ន្ធ | |
| ៣៧ | | រៀបចំក្របខណ្ឌពង្រឹងគុណភាពនិងឯកទេសកម្មលើការស្រាវជ្រាវ និងការអភិវឌ្ឍ ដើម្បីជំរុញការ អភិវឌ្ឍផលិតផលថ្មីនិងនវានុវត្តកម្មលើដំណើរការអនុវត្តការងារ | ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ | - ក្រសួងមុខងារសាធារណៈ<br>- ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍<br>- ក្រសួងអប់រំ យុវជន និងកីឡា<br>- ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ<br>- ក្រសួងពាណិជ្ជកម្ម<br>- គណៈកម្មាធិការជាតិផលិតភាពសេដ្ឋកិច្ចកម្ពុជា<br>- ក្រសួង-ស្ថាប័នពាក់ព័ន្ធ | ២០២២-២០៣៥ |
| ៣៨ | **(៣). ពង្រឹងប្រសិទ្ធភាពនៃកិច្ចសហប្រតិបត្តិការរវាងស្ថាប័ន ដើម្បីគាំទ្របច្ចេកវិទ្យា និង នវានុវត្តន៍÷** បង្កើតឱកាសសហប្រតិបត្តិការរវាងគ្រប់ភាគីពាក់ព័ន្ធនវានុវត្តន៍ | រៀបចំយន្តការនិងកម្មវិធីចែករំលែកចំណេះដឹង ជំនាញវិជ្ជាជីវៈ ជំនាញបច្ចេកទេស ឯកទេសកម្ម ព័ត៌មាន និងទិន្នន័យរវាងក្រសួង-ស្ថាប័នវិស័យឯកជន គ្រឹះស្ថានអប់រំ និងស្ថាប័នស្រាវជ្រាវ ទាំងរដ្ឋនិងឯកជន ដើម្បីបង្កើតជាឱកាសទំនាក់ទំនងរវាងស្ថាប័នទាំងនោះជាប្រចាំ | ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ | - ក្រសួងមហាផ្ទៃ<br>- ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍<br>- ក្រសួងផែនការ<br>- ក្រសួងពាណិជ្ជកម្ម<br>- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ<br>- ក្រសួងមុខងារសាធារណៈ<br>- ក្រសួងអប់រំ យុវជន និងកីឡា<br>- ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ<br>- ក្រសួង-ស្ថាប័នពាក់ព័ន្ធ | ២០២២-២០៣៥ |

| | | | | | |
|---|---|---|---|---|---|
| ៣៩ | | រៀបចំយន្តការសិក្សាស្រាវជ្រាវរួម រវាងក្រសួង-ស្ថាប័ន វិស័យឯកជន គ្រឹះស្ថានអប់រំ និងស្ថាប័នស្រាវជ្រាវ ទាំងរដ្ឋនិងឯកជន ស្របតាមអភិក្រម **"ជីវភាពនៃប្រព័ន្ធតួអង្គតែមួយ"** | គណៈកម្មាធិការជាតិផលិតភាពសេដ្ឋកិច្ចកម្ពុជា | - ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍<br>- ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍<br>- ស្ថាប័នស្រាវជ្រាវ<br>- ក្រសួង-ស្ថាប័នពាក់ព័ន្ធ | ២០២២-២០៣៥ |
| ៤០ | | គាំទ្រនិងរៀបចំកម្មវិធីនានា សំដៅពង្រឹងកិច្ចសហប្រតិបត្តិការរវាងវិស័យសាធារណៈនិងឯកជន ក្នុងការផ្លាស់ប្តូរបទពិសោធការសិក្សាស្រាវជ្រាវ និងអភិវឌ្ឍន៍ផលិតផលថ្មីៗ | ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ | - ក្រសួងមុខងារសាធារណៈ<br>- ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍<br>- ក្រសួងអប់រំ យុវជន និងកីឡា<br>- ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ<br>- ក្រសួងពាណិជ្ជកម្ម<br>- គណៈកម្មាធិការជាតិផលិតភាពសេដ្ឋកិច្ចកម្ពុជា<br>- ក្រសួង-ស្ថាប័នពាក់ព័ន្ធ | ២០២២-២០៣៥ |
| ៤១ | | ជំរុញការចូលរួមយ៉ាងសកម្ម និងកិច្ចសហប្រតិបត្តិការក្នុងស្មារតីបុរេសកម្មរវាងវិស័យសារធារណៈ និងឯកជនក្នុងការចាប់យកនិងប្រើប្រាស់បច្ចេកវិទ្យាទំនើបនិងធ្វើនវានុវត្តន៍ | ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ | - ក្រសួងមហាផ្ទៃ<br>- ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍<br>- ក្រសួងផែនការ<br>- ក្រសួងពាណិជ្ជកម្ម<br>- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ<br>- ក្រសួងមុខងារសាធារណៈ<br>- ក្រសួងអប់រំ យុវជន និងកីឡា<br>- ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ<br>- ក្រសួង-ស្ថាប័នពាក់ព័ន្ធ | ២០២២-២០៣៥ |

| | | | | | |
|---|---|---|---|---|---|
| ៤២ | | លើកកម្ពស់ការគាំទ្រសេដ្ឋកិច្ចឌីជីថលនិងនវានុវត្តន៍ ដើម្បីជំរុញការតភ្ជាប់រវាងនវានុវត្តន៍សេដ្ឋកិច្ចឌីជីថលនិងផលិតភាពសេដ្ឋកិច្ច | ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | - ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍<br>- ក្រសួងអប់រំ យុវជន និងកីឡា<br>- ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ<br>- ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍<br>- ក្រសួងពាណិជ្ជកម្ម<br>- គណៈកម្មាធិការជាតិផលិតភាពសេដ្ឋកិច្ចកម្ពុជា<br>- ក្រសួង-ស្ថាប័នពាក់ព័ន្ធ | ២០២២-២០៣៥ |
| **វិធានការគោលនយោបាយទី ៣÷ ការអភិវឌ្ឍសមត្ថភាពស្ថាប័នសាធារណៈ÷ អភិបាលកិច្ចល្អ, បទប្បញ្ញត្តិទីផ្សារ និង ការលើកកម្ពស់ស្ថាប័នទីផ្សារការងារ** | | | | | |
| ៤៣ | **(១). អភិបាលកិច្ចល្អ÷** ធានាឱ្យបាននូវគុណភាព ប្រសិទ្ធផល និង ប្រសិទ្ធភាពនៃការផ្តល់សេវាសាធារណៈ | កែលម្អយន្តការតាមដាននិងធ្វើការវាយតម្លៃជាប្រចាំក្នុងការផ្តល់សេវាសាធារណៈ ជាពិសេសដើម្បីកាត់បន្ថយចំណាយថវិកានិងពេល ព្រមទាំងនីតិវិធីមិនចាំបាច់ | ក្រសួងមុខងារសាធារណៈ | - ក្រសួងមហាផ្ទៃ<br>- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ<br>- ក្រសួងផែនការ<br>- គណៈកម្មាធិការជាតិផលិតភាពសេដ្ឋកិច្ចកម្ពុជា<br>- ក្រសួង-ស្ថាប័នពាក់ព័ន្ធ | ២០២២-២០៣៥ |
| ៤៤ | | ជំរុញទម្លាប់ធ្វើវិចារណកម្មលើវិធានការកែទម្រង់នានា នៅតាមក្រសួង-ស្ថាប័នសាធារណៈ សំដៅលើកកម្ពស់ការឱ្យតម្លៃលើផលប្រយោជន៍សង្គមជាតិទាំងមូលក្នុងរយៈពេលវែង | ក្រសួងមុខងារសាធារណៈ | - គណៈកម្មាធិការជាតិផលិតភាពសេដ្ឋកិច្ចកម្ពុជា<br>- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ<br>- ក្រសួងមហាផ្ទៃ<br>- ក្រសួង-ស្ថាប័នពាក់ព័ន្ធ | ២០២២-២០២៧ |
| ៤៥ | | លើកកម្ពស់ស្មារតីសហប្រតិបត្តិការអន្តរក្រសួង-ស្ថាប័ន ឱ្យបានសមស្របទៅនឹងតម្រូវការការងារនៅតាមក្រសួង-ស្ថាប័នសាធារណៈ | ក្រសួងមុខងារសាធារណៈ | - គណៈកម្មាធិការជាតិផលិតភាពសេដ្ឋកិច្ចកម្ពុជា<br>- ក្រសួង-ស្ថាប័នពាក់ព័ន្ធ | ២០២២-២០២៧ |

| | | | | | |
|---|---|---|---|---|---|
| ៤៦ | | ពង្រីកវិសាលភាពនៃការអនុវត្តអភិបាលកិច្ចឌីជីថល ស្របតាមគោលនយោបាយរដ្ឋាភិបាលឌីជីថលកម្ពុជា ២០២២-២០៣៥ | ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ | - ក្រសួងមហាផ្ទៃ<br>- ក្រសួងមុខងារសាធារណៈ<br>- ក្រសួង-ស្ថាប័នពាក់ព័ន្ធ | ២០២២-២០៣៥ |
| ៤៧ | | បន្តជំរុញការរៀបចំនិងអនុវត្តផែនការកែទម្រង់ការផ្តល់សេវាសាធារណៈនៅតាមក្រសួង-ស្ថាប័នសាធារណៈនានា ក្នុងគោលដៅធានាគុណភាព និងភាពជឿទុកចិត្តខ្ពស់ | ក្រសួងមុខងារសាធារណៈ | - ក្រសួងមហាផ្ទៃ<br>- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ<br>- ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍<br>- ក្រសួង-ស្ថាប័នពាក់ព័ន្ធ | ២០២២-២០៣៥ |
| ៤៨ | | បង្កើតនិងជំរុញយុទ្ធនាការផ្តល់សេវាសាធារណៈ ផ្អែកលើគោលការណ៍ "*ប្រសិទ្ធភាព ប្រសិទ្ធផល និងគុណតម្លៃ*" | ក្រសួងមុខងារសាធារណៈ | - ក្រសួងមហាផ្ទៃ<br>- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ<br>- គណៈកម្មាធិការជាតិផលិតភាពសេដ្ឋកិច្ចកម្ពុជា<br>- ក្រសួងព័ត៌មាន<br>- ក្រសួង-ស្ថាប័នពាក់ព័ន្ធ | ២០២២-២០៣០ |
| ៤៩ | **(២). បទប្បញ្ញត្តិទីផ្សារ÷** ធានាបាននូវប្រសិទ្ធភាពនៃអភិបាលកិច្ចទីផ្សារ | រៀបចំនិងដាក់ចេញក្របខណ្ឌអនុវត្តអភិបាលកិច្ចទីផ្សារ ផ្អែកលើគោលការណ៍សេដ្ឋកិច្ចទីផ្សារ ដែលផ្តល់ផលប្រយោជន៍ដល់គ្រប់តួអង្គសេដ្ឋកិច្ច ប្រកបដោយសមធម៌ | ក្រសួងពាណិជ្ជកម្ម | - ក្រសួងមហាផ្ទៃ<br>- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ<br>- ក្រសួងមុខងារសាធារណៈ<br>- ក្រសួង-ស្ថាប័នពាក់ព័ន្ធ | ២០២២-២០៣៥ |
| ៥០ | | ពិនិត្យឡើងវិញលើបទប្បញ្ញត្តិសំខាន់ៗពាក់ព័ន្ធនឹងការវិនិយោគ សំដៅលើកកម្ពស់ប្រសិទ្ធភាព នៃច្បាប់ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា ក្នុងការទាក់ទាញគម្រោងវិនិយោគ ដែលមានបច្ចេកវិទ្យាខ្ពស់ តម្លៃបន្ថែមខ្ពស់ និងនវានុវត្តន៍ប្រកបដោយភាពច្នៃប្រតិដ្ឋខ្ពស់ | ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា | - ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ<br>- ក្រសួងពាណិជ្ជកម្ម<br>- ក្រសួងរ៉ែ និងថាមពល<br>- ក្រសួងសាធារណការ និងដឹកជញ្ជូន | ២០២២-២០៣០ |

| | | | | | |
|---|---|---|---|---|---|
| ៥១ | | ពង្រឹងប្រសិទ្ធភាពនៃការអនុវត្តច្បាប់ពាក់ព័ន្ធនឹងបទប្បញ្ញត្តិទីផ្សារ ដូចជាច្បាប់ស្ដីពីការប្រកួតប្រជែង និងច្បាប់ស្ដីពីកិច្ចការពារអ្នកប្រើប្រាស់ | ក្រសួងពាណិជ្ជកម្ម | - ក្រសួងមហាផ្ទៃ<br>- ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍<br>- ក្រសួងការងារ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈ<br>- ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា<br>- ក្រសួង-ស្ថាប័នពាក់ព័ន្ធ | ២០២២-២០៣៥ |
| ៥២ | | បង្កើតនិងដាក់ឱ្យប្រើប្រាស់នូវបណ្ដុំទិន្នន័យ សម្រាប់ផ្ដល់ព័ត៌មាននិងទិន្នន័យទីផ្សារឱ្យមានសង្គតិភាព ភាពជឿជាក់ និងតម្លាភាពខ្ពស់ | ក្រសួងពាណិជ្ជកម្ម | - ក្រសួងមហាផ្ទៃ<br>- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ<br>- ក្រសួងផែនការ<br>- ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍<br>- ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍<br>- ក្រសួង-ស្ថាប័នពាក់ព័ន្ធ | ២០២២-២០២៧ |
| ៥៣ | | កែលម្អយន្តការតាមដាននិងវាយតម្លៃលើការអនុវត្តអភិបាលកិច្ចទីផ្សារ ដោយផ្ដោតលើវិបាក ប្រសិទ្ធផល ប្រសិទ្ធភាព និងគុណតម្លៃ | ក្រសួងពាណិជ្ជកម្ម | - ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ<br>- ក្រសួងផែនការ<br>- ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍<br>- ក្រសួងមុខងារសាធារណៈ<br>- គណៈកម្មាធិការជាតិផលិតភាពសេដ្ឋកិច្ចកម្ពុជា<br>- ក្រសួង-ស្ថាប័នពាក់ព័ន្ធ | ២០២២-២០៣៥ |

| | | | | | |
|---|---|---|---|---|---|
| ៥៤ | **(៣). លើកកម្ពស់ស្ថាប័នទីផ្សារការងារ÷** ផ្តល់ទំនុកចិត្តដល់និយោជិត និងនិយោជកក្នុងការលើកកម្ពស់ផលិតភាព | កាត់បន្ថយឱ្យនៅកម្រិតអប្បបរមានូវភាពមិនស៊ីសង្វាក់គ្នារវាងតម្រូវការទីផ្សារការងារ និងការផ្គត់ផ្គង់ជំនាញ តាមរយៈការធ្វើបច្ចុប្បន្នភាពជាប្រចាំលើទិន្នន័យអំពីតម្រូវការនិងការផ្គត់ផ្គង់កម្លាំងពលកម្មជាតិតាមវិស័យ, កិច្ចសហការរវាងនិយោជកនិងគ្រឹះស្ថានអប់រំបណ្តុះបណ្តាល និងការលើកកម្ពស់ប្រសិទ្ធភាពនៃការផ្តល់សេវាកម្មផ្គូផ្គងការងារ | ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ | - ក្រសួងផែនការ<br>- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ<br>- ក្រសួងអប់រំ យុវជន និងកីឡា<br>- ក្រសួងពាណិជ្ជកម្ម<br>- ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា<br>- ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍<br>- ក្រសួង-ស្ថាប័នពាក់ព័ន្ធ | ២០២២-២០៣០ |
| ៥៥ | | លើកកម្ពស់វប្បធម៌គុណាធិបតេយ្យ សំដៅបង្កើនភាពបត់បែននៃទីផ្សារការងារ ដើម្បីជំរុញនិងលើកទឹកចិត្តឱ្យមានកិច្ចខិតខំប្រឹងប្រែងអភិវឌ្ឍសមត្ថភាពនិងផលិតភាពរបស់ខ្លួនបន្ថែមទៀតជាប្រចាំ | ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ | - ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ<br>- ក្រសួងមុខងារសាធារណៈ<br>- ក្រសួងអប់រំ យុវជន និងកីឡា<br>- ក្រសួង-ស្ថាប័នពាក់ព័ន្ធ | ២០២២-២០៣៥ |
| ៥៦ | | ជំរុញការវិនិយោគបន្ថែមទៅលើការអប់រំនិងការបណ្តុះបណ្តាល សំដៅពង្រឹងសមត្ថភាពរបស់កម្លាំងពលកម្មក្នុងការចាប់យកជំនាញថ្មីៗ និងបង្កើនចល័តភាពការងារ ដើម្បីឱ្យកម្លាំងពលកម្មអាចសម្របខ្លួនតាមការវិវត្តនៃតម្រូវការទីផ្សារការងារ | ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ | - ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ<br>- ក្រសួងពាណិជ្ជកម្ម<br>- ក្រសួងអប់រំ យុវជន និងកីឡា<br>- ក្រសួង-ស្ថាប័នពាក់ព័ន្ធ | ២០២២-២០៣៥ |
| ៥៧ | | បន្តរៀបចំនិងពង្រឹងការអនុវត្តកម្មវិធីគាំពារសង្គមដល់និយោជិត ដូចជាការធានារ៉ាប់រងលើការបាត់បង់ការងារ ការថែទាំសុខភាព និងរបបសន្តិសុខសង្គមផ្នែកប្រាក់សោធន | ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ | - ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ<br>- ក្រុមប្រឹក្សាជាតិគាំពារសង្គម<br>- ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា<br>- ក្រសួងសុខាភិបាល | ២០២២-២០៣៥ |

| | | | | | |
|---|---|---|---|---|---|
| | | | | - បេឡាជាតិសន្តិសុខសង្គម<br>- ក្រសួង-ស្ថាប័នពាក់ព័ន្ធ | |
| ៥៨ | | រៀបចំក្របខណ្ឌលើកទឹកចិត្ត ដើម្បីទាក់ទាញអ្នកមានទេពកោសល្យជាពិសេសតាមរយៈការជំរុញមាតុភូមិនិវត្តន៍នៃសិស្សនិស្សិតទទួលការអប់រំនៅក្រៅប្រទេសនិងកម្លាំងពលកម្ម ដែលមានបទពិសោធ និងជំនាញវិជ្ជាជីវៈខ្ពស់ | ក្រសួងមុខងារសាធារណៈ | - ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ<br>- ក្រសួងអប់រំ យុវជន និងកីឡា<br>- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ<br>- ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ<br>- ក្រសួង-ស្ថាប័នពាក់ព័ន្ធ | ២០២២-២០៣០ |
| ៥៩ | | រៀបចំផែនការវិនិយោគបន្ថែមលើហេដ្ឋារចនាសម្ព័ន្ធទិន្នន័យ ចងក្រងទិន្នន័យ និងធ្វើការព្យាករតម្រូវការកម្លាំងពលកម្មតាមវិស័យតាមរយៈការធ្វើបច្ចុប្បន្នភាពជាប្រចាំ | ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ | - ក្រសួងផែនការ<br>- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ<br>- ក្រសួងពាណិជ្ជកម្ម<br>- ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា<br>- ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍<br>- ក្រសួង-ស្ថាប័នពាក់ព័ន្ធ | ២០២២-២០២៧ |
| ៦០ | | កែលម្អយន្តការអភិបាលកិច្ចលើលក្ខខណ្ឌការងារ សំដៅធានាសុខុមាលភាព និងផាសុកភាពនិយោជិត | ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ | - ក្រសួងពាណិជ្ជកម្ម<br>- ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា<br>- ក្រសួង-ស្ថាប័នពាក់ព័ន្ធ | ២០២២-២០២៧ |
| ៦១ | | រៀបចំយុទ្ធនាការជំរុញឱ្យមានការប្រើប្រាស់សេវាប្រឹក្សាយោបល់ពាក់ព័ន្ធនឹងការស្វែងរកការងារ, ការត្រៀមខ្លួនចូលទីផ្សារការងារ, | ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ | - ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ<br>- ក្រសួងពាណិជ្ជកម្ម<br>- ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា | ២០២២-២០៣០ |

| | | | | | |
|---|---|---|---|---|---|
| | | ការផ្លាស់ប្តូរអាជីព និងការបណ្តុះបណ្តាលបច្ចេកទេសជំនាញវិជ្ជាជីវៈ ស្របតាមតម្រូវការរបស់ទីផ្សារការងារជាក់ស្តែង | | - ក្រសួងអប់រំ យុវជន និងកីឡា<br>- ក្រសួង-ស្ថាប័នពាក់ព័ន្ធ | |
| ៦២ | | បង្កើតជាកម្មវិធី ឬ ឱកាសទំនាក់ទំនងជាប្រចាំរវាងនិយោជក និយោជិត និងភាគីពាក់ព័ន្ធនានា ក្នុងវិស័យអាទិភាព ដើម្បីឱ្យភាគីនីមួយៗយល់ច្បាស់ពីតម្រូវការទីផ្សារនិងឱកាសនានា | ក្រសួងការងារ និង បណ្តុះបណ្តាលវិជ្ជាជីវៈ | - ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ<br>- ក្រសួងពាណិជ្ជកម្ម<br>- ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា<br>- ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍<br>- ក្រសួង-ស្ថាប័នពាក់ព័ន្ធ | ២០២២-២០៣៥ |
| **វិធានការគោលនយោបាយទី ៤÷ ការអភិវឌ្ឍប្រព័ន្ធហេដ្ឋារចនាសម្ព័ន្ធ÷ ប្រព័ន្ធដឹកជញ្ជូន, ប្រព័ន្ធភស្តុភារកម្ម, ប្រព័ន្ធទឹកស្អាត, ប្រព័ន្ធថាមពល និង ប្រព័ន្ធហេដ្ឋារចនាសម្ព័ន្ធឌីជីថល** | | | | | |
| ៦៣ | **(១). ប្រព័ន្ធដឹកជញ្ជូន÷** កែលម្អប្រព័ន្ធដឹកជញ្ជូន ប្រកបដោយសុវត្ថិភាពនិងគុណភាពខ្ពស់ | រៀបចំផែនការធ្វើទំនើបកម្មនិងលើកកម្ពស់សមត្ថភាពប្រព័ន្ធដឹកជញ្ជូន ឱ្យសមស្របទៅនឹងតម្រូវការអភិវឌ្ឍសេដ្ឋកិច្ចទាំងបច្ចុប្បន្ននិងអនាគត សំដៅបង្កើនប្រសិទ្ធផលនិងប្រសិទ្ធភាពនៃសេដ្ឋកិច្ចដឹកជញ្ជូន | ក្រសួងសាធារណការ និងដឹកជញ្ជូន | - ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ<br>- ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍<br>- ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់<br>- ក្រសួងអភិវឌ្ឍន៍ជនបទ<br>- ក្រសួង-ស្ថាប័នពាក់ព័ន្ធ | ២០២២-២០៣៥ |
| ៦៤ | | រៀបចំយន្តការគ្រប់គ្រង តាមដាននិងវាយតម្លៃ និងកែលម្អការអនុវត្តយន្តការសម្របសម្រួល និងសហប្រតិបត្តិការអន្តរក្រសួង-ស្ថាប័នពាក់ព័ន្ធនឹងគុណភាពនៃប្រព័ន្ធដឹកជញ្ជូន ដើម្បីជំរុញបន្ថែមការអភិវឌ្ឍនិងធានាប្រសិទ្ធផលនៃសេដ្ឋកិច្ចដឹកជញ្ជូន | ក្រសួងសាធារណការ និងដឹកជញ្ជូន | - គណៈកម្មាធិការជាតិផលិតភាពសេដ្ឋកិច្ចកម្ពុជា<br>- ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ<br>- ក្រសួង-ស្ថាប័នពាក់ព័ន្ធ | ២០២២-២០២៧ |

| | | | | | |
|---|---|---|---|---|---|
| ៦៥ | | រៀបចំនិងកែលម្អយុទ្ធសាស្ត្រដោះស្រាយបញ្ហាកកស្ទះ ដើម្បីធានាបានស័ក្តិសិទ្ធភាពនៃរំហូរចរាចរណ៍និងការដឹកជញ្ជូន | ក្រសួងមហាផ្ទៃ | - ក្រសួងសាធារណការ និងដឹកជញ្ជូន<br>- ក្រសួង-ស្ថាប័នពាក់ព័ន្ធ | ២០២២-២០៣៥ |
| ៦៦ | **(២). ប្រព័ន្ធភស្តុភារកម្ម÷** លើកកម្ពស់ប្រសិទ្ធភាព ប្រសិទ្ធផល និង ភាពប្រកួតប្រជែង នៃប្រព័ន្ធភស្តុភារកម្ម | រៀបចំក្របខណ្ឌគតិយុត្តនិងគោលការណ៍ណែនាំ ដើម្បីបង្កើនស័ក្តិសិទ្ធភាព និងគុណភាពនៃប្រព័ន្ធភស្តុភារកម្មសម្រាប់ទ្រទ្រង់ផលិតភាពសេដ្ឋកិច្ច | ក្រសួងសាធារណការ និងដឹកជញ្ជូន | - ក្រសួងមហាផ្ទៃ<br>- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ<br>- ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍<br>- ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍<br>- ក្រសួងពាណិជ្ជកម្ម<br>- ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា<br>- ក្រសួង-ស្ថាប័នពាក់ព័ន្ធ | ២០២២-២០២៧ |
| ៦៧ | | ពិនិត្យឡើងវិញ និងកែលម្អនីតិវិធីគយនិងរដ្ឋបាលពាក់ព័ន្ធនឹងការអនុវត្តច្រកចេញចូលតែមួយ សំដៅធានាភាពរលូនពីដើមខ្សែដល់ចុងខ្សែ និងកាត់បន្ថយចំណាយ ដើម្បីជំរុញភាពប្រកួតប្រជែង និងសម្រួលដល់ប្រតិបត្តិការនានា | ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | - ក្រសួងពាណិជ្ជកម្ម<br>- ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍<br>- ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា<br>- ក្រសួងមុខងារសាធារណៈ<br>- ក្រសួង-ស្ថាប័នពាក់ព័ន្ធ | ២០២២-២០៣៥ |
| ៦៨ | | ជំរុញយន្តការភាពជាដៃគូរវាងរដ្ឋនិងឯកជន ក្នុងការវិនិយោគលើវិស័យភស្តុភារកម្ម ដូចជាការបង្កើតមជ្ឈមណ្ឌលភស្តុភារកម្ម ដើម្បីលើកកម្ពស់ភាពប្រកួតប្រជែងក្នុងវិស័យនេះ | ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | - ក្រសួងសាធារណការ និងដឹកជញ្ជូន<br>- ក្រសួងពាណិជ្ជកម្ម<br>- ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍<br>- ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា | ២០២២-២០៣៥ |

| | | | | | |
|---|---|---|---|---|---|
| | | | | - ក្រសួង-ស្ថាប័នពាក់ព័ន្ធ | |
| ៦៩ | | កែលម្អយន្តការតាមដាននិងវាយតម្លៃជាប្រចាំលើស័ក្តិសិទ្ធភាព ប្រតិបត្តិការ និងគុណភាពនៃការផ្តល់សេវាភស្តុភារកម្ម | ក្រសួងសាធារណការ និងដឹកជញ្ជូន | - ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ<br>- ក្រសួងផែនការ<br>- ក្រសួងពាណិជ្ជកម្ម<br>- គណៈកម្មាធិការជាតិផលិតភាពសេដ្ឋកិច្ចកម្ពុជា<br>- ក្រសួង-ស្ថាប័នពាក់ព័ន្ធ | ២០២២-២០៣០ |
| ៧០ | **(៣). ប្រព័ន្ធទឹកស្អាត÷** ធានាបានការផ្គត់ផ្គង់ និងបែងចែកទឹកស្អាត ប្រកបដោយប្រសិទ្ធផល និងប្រសិទ្ធភាពខ្ពស់ | កែលម្អបច្ចេកវិទ្យាគ្រប់គ្រងទឹកស្អាត ដើម្បីធានាប្រសិទ្ធផល ប្រសិទ្ធភាព និងគុណភាពនៃការផលិតនិងផ្គត់ផ្គង់ទឹកស្អាត សំដៅបំពេញតម្រូវការនៃការអភិវឌ្ឍសង្គម-សេដ្ឋកិច្ចជាក់ស្តែង | ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ | - ក្រសួងអភិវឌ្ឍន៍ជនបទ<br>- ក្រសួង-ស្ថាប័នពាក់ព័ន្ធ | ២០២២-២០៣៥ |
| ៧១ | | ជំរុញការវិនិយោគតាមយន្តការភាពជាដៃគូរវាងរដ្ឋនិងឯកជន ក្នុងប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាត ដើម្បីពង្រឹងនិងពង្រីកវិសាលភាព ក្នុងការទទួលបានទឹកស្អាត នៅតាមទីជនបទនិងតំបន់ដាច់ស្រយាល | ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ | - ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ<br>- ក្រសួងអភិវឌ្ឍន៍ជនបទ<br>- ក្រសួង-ស្ថាប័នពាក់ព័ន្ធ | ២០២២-២០៣៥ |
| ៧២ | | សិក្សានិងរៀបចំផែនការវិនិយោគនិងអភិវឌ្ឍលើស្ថានីយ៍ទឹកស្អាត ដើម្បីបង្កើនសមត្ថភាពផលិត ផ្គត់ផ្គង់ និងចែកចាយទឹកស្អាត ដើម្បីបំពេញតម្រូវការជាក់ស្តែង ស្របតាមដំណើរការអភិវឌ្ឍសង្គម-សេដ្ឋកិច្ច | ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ | - ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ<br>- ក្រសួងអភិវឌ្ឍន៍ជនបទ<br>- ក្រសួង-ស្ថាប័នពាក់ព័ន្ធ | ២០២២-២០៣៥ |
| ៧៣ | **(៤). ប្រព័ន្ធថាមពល÷** បង្កើនសមត្ថភាពក្នុងការផលិតនិងផ្គត់ផ្គង់ថាមពល និងអគ្គិសនី | រៀបចំយុទ្ធសាស្ត្រសន្តិសុខថាមពលសម្រាប់រយៈពេលវែង ដើម្បីទ្រទ្រង់តម្រូវការបរិវត្តកម្មសេដ្ឋកិច្ច និងធានាទំនុកចិត្តពីវិនិយោគិនលើការវិនិយោគដែលមានតម្លៃបន្ថែមខ្ពស់ | ក្រសួងរ៉ែ និងថាមពល | - ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ<br>- ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍<br>- ក្រសួងបរិស្ថាន | ២០២២-២០៣៥ |

| | | | | | |
|---|---|---|---|---|---|
| | | | | - ក្រសួង-ស្ថាប័នពាក់ព័ន្ធ | |
| ៧៤ | | រៀបចំផែនការបង្កើនការវិនិយោគលើផលិតកម្មថាមពល ជាពិសេសថាមពលកកើតឡើងវិញ សំដៅកាត់បន្ថយថ្លៃថាមពល ធានាសន្តិសុខថាមពល និងពង្រឹងពង្រីកសមត្ថភាពផ្គត់ផ្គង់ និងចែកចាយថាមពល | ក្រសួងរ៉ែ និងថាមពល | - ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ<br>- ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍<br>- ក្រសួងបរិស្ថាន<br>- ក្រសួង-ស្ថាប័នពាក់ព័ន្ធ | ២០២២-២០៣៥ |
| ៧៥ | | រៀបចំគម្រោងវិនិយោគលើការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធតភ្ជាប់ និងចែកចាយថាមពល ដើម្បីធានាស្ថិរភាពនៃការផ្គត់ផ្គង់ថាមពល និងពង្រីកវិសាលភាពនៃការផ្គត់ផ្គង់នៅក្រៅទីប្រជុំជននិងជនបទ តាមអាទិភាពនៃតម្រូវការនិងភាពចាំបាច់ជាក់ស្តែង | ក្រសួងរ៉ែ និងថាមពល | - ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ<br>- ក្រសួងអភិវឌ្ឍន៍ជនបទ<br>- អាជ្ញាធរអគ្គិសនីកម្ពុជា<br>- អគ្គិសនីកម្ពុជា | ២០២២-២០៣០ |
| ៧៦ | | ពិនិត្យលើប្រសិទ្ធភាពនៃការផ្គត់ផ្គង់ថាមពលប្រកបដោយតម្លាភាព គណនេយ្យភាព ការទទួលខុសត្រូវខ្ពស់ និងទាន់ពេល | ក្រសួងរ៉ែ និងថាមពល | - អាជ្ញាធរអគ្គិសនីកម្ពុជា<br>- អគ្គិសនីកម្ពុជា<br>- ក្រសួង-ស្ថាប័នពាក់ព័ន្ធ | ២០២២-២០៣០ |
| ៧៧ | | បង្កើតយន្តការសិក្សា តាមដាន ត្រួតពិនិត្យ និងវាយតម្លៃលើភាពសមស្របនៃការផ្គត់ផ្គង់ និងចែកចាយថាមពលក្នុងការជំរុញឧស្សាហូបនីយកម្ម និងលើកកម្ពស់សកម្មភាពសេដ្ឋកិច្ច | ក្រសួងរ៉ែ និងថាមពល | - ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ<br>- ក្រសួងផែនការ<br>- គណៈកម្មាធិការជាតិផលិតភាពសេដ្ឋកិច្ចកម្ពុជា<br>- អាជ្ញាធរអគ្គិសនីកម្ពុជា<br>- អគ្គិសនីកម្ពុជា<br>- ក្រសួង-ស្ថាប័នពាក់ព័ន្ធ | ២០២២-២០២៧ |

| | | | | | |
|---|---|---|---|---|---|
| ៧៨ | **(៥). ប្រព័ន្ធហេដ្ឋារចនាសម្ព័ន្ធឌីជីថល÷** ពង្រឹងហេដ្ឋារចនាសម្ព័ន្ធឌីជីថល ដើម្បីបង្កើនសមត្ថភាព គុណភាព និងវិសាលភាពគ្របដណ្តប់នៃប្រព័ន្ធហេដ្ឋារចនាសម្ព័ន្ធឌីជីថល | រៀបចំនិងអនុវត្តផែនការជំរុញនិងពន្លឿនការធ្វើបរិវត្តកម្មឌីជីថលនៅតាមក្រសួង-ស្ថាប័នសាធារណៈស្របតាមគន្លងប្រក្រតីភាពថ្មី | ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ | - ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ<br>- ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍<br>- ក្រសួងអប់រំ យុវជន និងកីឡា<br>- ក្រសួងមហាផ្ទៃ<br>- ក្រសួងពាណិជ្ជកម្ម<br>- ក្រសួងអភិវឌ្ឍន៍ជនបទ<br>- ក្រសួង-ស្ថាប័នពាក់ព័ន្ធ | ២០២២-២០៣៥ |
| ៧៩ | | រៀបចំក្របខណ្ឌលើកទឹកចិត្តបង្កើនការវិនិយោគលើប្រព័ន្ធឌីជីថលដល់សហគ្រាសធុនតូចនិងមធ្យម | ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | - ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍<br>- ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍<br>- ក្រសួងពាណិជ្ជកម្ម<br>- ក្រសួង-ស្ថាប័នពាក់ព័ន្ធ | ២០២២-២០៣០ |
| ៨០ | | រៀបចំក្របខណ្ឌជំរុញការវិនិយោគលើហេដ្ឋារចនាសម្ព័ន្ធឌីជីថល ដើម្បីឆ្លើយតបនឹងបរិវត្តកម្មសេដ្ឋកិច្ចនិងបដិវត្តន៍ឧស្សាហកម្មទី៤ | ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | - ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍<br>- ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍<br>- ក្រសួង-ស្ថាប័នពាក់ព័ន្ធ | ២០២២-២០៣៥ |
| ៨១ | | បង្កើតយន្តការថ្នាក់ជាតិសម្រាប់តាមដាន វាស់វែង និងវាយតម្លៃលើភាពសមស្របនិងប្រសិទ្ធភាព នៃការប្រើប្រាស់ប្រព័ន្ធឌីជីថលដើម្បីជំរុញផលិតភាពសេដ្ឋកិច្ច | ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ | - ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ<br>- ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍<br>- ក្រសួងផែនការ | ២០២២-២០៣៥ |

| | | | | | |
|---|---|---|---|---|---|
| | | | | - គណៈកម្មាធិការជាតិផលិតភាពសេដ្ឋកិច្ចកម្ពុជា<br>- ក្រសួង-ស្ថាប័នពាក់ព័ន្ធ | |
| ៨២ | | រៀបចំផែនការបំពាក់បច្ចេកវិទ្យានិងប្រព័ន្ធឌីជីថល សម្រាប់ការអប់រំ និងបណ្តុះបណ្តាល ប្រកបដោយបរិយាបន្ន | ក្រសួងអប់រំ យុវជន និងកីឡា | - ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍<br>- ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍<br>- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ<br>- ក្រសួង-ស្ថាប័នពាក់ព័ន្ធ | ២០២២-២០៣០ |
| ៨៣ | | រៀបចំបណ្ណាល័យឌីជីថលនិងការគ្រប់គ្រងសន្និធិចំណេះដឹង | ក្រសួងអប់រំ យុវជន និងកីឡា | - ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍<br>- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ<br>- ក្រសួង-ស្ថាប័នពាក់ព័ន្ធ | ២០២២-២០៣០ |
| ៨៤ | | បង្កើតយន្តការសហប្រតិបត្តិការអន្តរក្រសួង-ស្ថាប័ន ដើម្បីផ្តល់ការគាំទ្រផ្នែកបច្ចេកវិទ្យាទៅវិញទៅមក | ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ | - ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ<br>- ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍<br>- ក្រសួងអប់រំ យុវជន និងកីឡា<br>- ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ<br>- ក្រសួងមុខងារសាធារណៈ<br>- គណៈកម្មាធិការជាតិផលិតភាពសេដ្ឋកិច្ចកម្ពុជា<br>- ក្រសួង-ស្ថាប័នពាក់ព័ន្ធ | ២០២២-២០២៧ |

ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
គណៈកម្មាធិការជាតិផលិតភាពសេដ្ឋកិច្ចកម្ពុជា
© ២០២២